ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៧នាទី**

**សវនាការលើកទី៤៥៣**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-Dec-2016, 14:52
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន  ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោកស្រី ដូរីន ជិន *(Ms. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គឹមសួន

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JAQUIN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា កាស៊ូមិ ណាកាហ្គាវ៉ា (2-TCE-82) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ កញ្ញា ការ៉ូមិ ណាកាហ្គាវ៉ា** (2-TCE-82)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ១៤

សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី ........ ទំព័រ ២៧

សួរដោយលោក វីល្លៀម ស្មីត ផ្ដើមពី........ ទំព័រ ៤១

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ........ ទំព័រ ៧២

# កិច្ចដំណើរការនីតិវិធី

[០៩:០៧:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ និងថ្ងៃស្អែកអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មអ្នកជំនាញ 2-TCE-82 ពាក់ព័ន្ធនឹងអង្គហេតុការចេញបទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ អញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់ថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយអ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCE-82។ អ្នកជំនាញបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ អ្នកជំនាញមានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:០៨:៥២]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខ-

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាពខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ បានកំណត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះ វិលមុខ ពេលអង្គុយយូរបន្តិច និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:១០:៤៧]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

មុននឹងចាប់ផ្តើមសក្ខីកម្មអ្នកជំនាញ 2-TCE-82 អង្គជំនុំជម្រះនឹងស្តាប់សារណាផ្ទាល់មាត់របស់ភាគីពាក់ព័ន្ធនឹងបញ្ហាចំនួនពីរ។ បញ្ហាទី១ លើកការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាចំនួនប្រាំបួន ពីក្នុងសំណុំរឿង០៣ និង០៤។ ឯកសារ E319/59។ កាលពីម្សិលមិញនេះ មេធាវីការពារក្តីលោក នួន ជា បានជូនដំណឹងមកអង្គជំនុំជម្រះតាមរយៈអ៊ីម៉ែលថា ខ្លួនមានបំណងស្នើសុំធ្វើសារណាផ្ទាល់មាត់លើការដាក់បង្ហាញឯកសារចំនួនទាំងប្រាំបួននេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះមានបំណងស្តាប់សារណាផ្ទាល់របស់ភាគីនានា មុនចាប់ផ្តើមស្តាប់សក្ខីកម្មអ្នកជំនាញ។

ជាដំបូង អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីធ្វើការសារណាឆ្លើយតបទៅនឹងសំណើនេះ។ សូមអញ្ជើញ!

**លោកស្រី ដូរីន ជិន៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ ហើយខ្ញុំនឹងបញ្ជាក់ដោយសង្ខេប ពីម្សិលមិញល្ងាចប្រហែលជាម៉ោងដប់ប្រាំ សែសិប<បី>នាទី យើងបានទទួលដំណឹងពីការដាក់បង្ហាញឯកសារប្រាំបួនឯកសារ<ថ្មីមកពីសំណុំរឿង០០៣ និង០០៤> គឺឯកសារ E319/59។ <ដូច្នេះគឺមានឯកសារប្រាំបួន> ហើយយើងមិនមានលទ្ធផលបើកមើលឯកសារទាំងនោះទេ។ ហើយយើងយល់<តាមរយៈ>ឧបសម្ព័ន្ធ<ដែលពណ៌នាអំពីឯកសារនោះថា ឯកសារទាំង>នោះ <បានចុះកាលបរិច្ឆេទ>ខែវិច្ឆិកា ឆ្នាំ២០១៣, <ខែវិច្ឆិកា ឆ្នាំ២០១៤, ខែតុលា ឆ្នាំ២០១៥ និងខែមីនា និងមិថុនា ឆ្នាំ២០១៦>។ <តាមរយៈឧបសម្ព័ន្ធដែលយើងអាចមើលបាននោះ យើងឃើញថា> ឯកសារប្រាំ<ក្នុងចំណោមឯកសារទាំងអស់នោះ> មានភស្តុតាងដោះបន្ទុកច្រើន គឺឯកសារ២ និង៦ ដល់៩។ ឯកសារពីរត្រូវបានដាក់បង្ហាញ គឺទាក់ទងទៅនឹង<សំណើសុំតាម>វិធាន៨៧(៤) គឺថាឯកសារ<E319/58 ហើយមានឯកសារ>ទី៤ និងទី៥។ ហើយមិនមានផ្តល់យុត្តិកម្មសម្រាប់ការដាក់បង្ហាញឯកសារ<ពីរទៀតដែលនៅសល់>នោះទេ <គឺឯកសារលេខ១ និងលេខ៣>។

[០៩:១៣:១៣]

អ្វីដែលយើងអាចបញ្ជាក់នេះ គឺថាជាឧបសម្ព័ន្ធសង្ខេបនេះ គឺយើងមិនអាចមើលបានទេ។ គឺថាចំនួនប្រាំមួយពាក់ព័ន្ធទៅនឹងការចាត់ចែងគ្រប់គ្រងពីការរៀបអាពាហ៍ពិពាហ៍។ <ដូច្នេះ យើងគ្រាន់តែចង់ដាក់សារណាសង្ខេបមួយចំនួន ទាក់ទងទៅនឹងឯកសារទាំងអស់នេះ។> ចំណុចទី១នោះ គឺថាយើងសង្កេតឃើញថាសហព្រះរាជអាជ្ញាចង្អុលបង្ហាញថា គឺខ្លួនបានសុំការស្វែងរកការអនុញ្ញាត<បង្ហាញឯកសារនេះ> គឺនៅក្នុងខែមិថុនា និងខែសីហា ឆ្នាំ២០១៦ ពី<ការិយាល័យ>សហចៅក្រមស៊ើបអង្កេត។ <ហើយបន្ទាប់មកការិយាល័យសហចៅក្រមស៊ើបអង្កេត>បានអនុញ្ញាត<ឲ្យបង្ហាញឯកសារនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ប៉ុន្តែឯកសារចំនួនពីរ បានត្រូវបង្ហាញតាំងពីខែធ្នូ> ឆ្នាំ២០១៥។ <ដូច្នេះឯកសារណាដែលយើងស្នើសុំនោះ គឺទាក់ទងទៅនឹងពេលវេលា ដែល>សហព្រះរាជអាជ្ញា<បង្ហាញ>ភស្តុតាងដោះបន្ទុក <ដែលឯកសារនោះចុះកាលបរិច្ឆេទតាំងពីឆ្នាំ២០១៣ ហើយគាត់បង្ហាញ>តែប៉ុន្មានម៉ោង<ប៉ុណ្ណោះ> មុនពេលដែលអ្នកជំនាញ 2-TCE-82 <មកបង្ហាញខ្លួន>។ អ៊ីចឹង គឺថាយើង<យល់

ឃើញថា> សហព្រះរាជអាជ្ញា<មានកាតព្វកិច្ច>ត្រូវផ្តល់ដំណឹង ឬក៏ដាក់បង្ហាញ<ឯកសារដែលមានសក្តានុពលដោះបន្ទុក>ហ្នឹង <តាំងពីឱកាសដំបូងមកម្ល៉េះ>។ <ដូចយើងនិយាយ>អ៊ីចឹង គឺថាឯកសារ<ដាក់បង្ហាញមួយចំនួននោះ មានចុះកាលបរិច្ឆេទ>តាំងពីឆ្នាំ២០១៣ ឯណោះ។ ដូច្នេះ <តាមទស្សនវិស័យរបស់>យើង <ការណ៍នេះបង្ហាញឲ្យឃើញថាជាការរំលោភទៅលើកាតព្វកិច្ច>បង្ហាញឯកសារ<របស់សហព្រះរាជអាជ្ញា។ ដូច្នេះអ្វីដែលយើងចង់ដឹងគឺ ហេតុអ្វីបានជាសហព្រះរាជអាជ្ញាទើបតែបង្ហាញឯកសារ>នៅពេលនេះ? លើសពីនេះទៅទៀត ទោះបីជាសហព្រះរាជអាជ្ញា<>ទទួលបានការអនុញ្ញាតដើម្បីបង្ហាញឯកសារនៅថ្ងៃទី<៣១> សីហា<ក៏ដោយ ក៏ខ្លួនបានរង់ចាំរហូតដល់ថ្ងៃ>មុនពេលវត្តមានរបស់អ្នកជំនាញ <2-TCE-82 ទើបខ្លួនបង្ហាញឯកសារ>ទាក់ទងទៅនឹងបញ្ហាការ បទបញ្ជានៃការរៀបចំអាពាហ៍ពិពាហ៍។ <ជាថ្មីម្តងទៀត> អ្វីដែលយើងចង់ដឹងថា គឺមូលហេតុអ្វី<បានជាមានរឿងនេះកើតឡើង។ តាមទស្សនវិស័យរបស់យើងគឺថា សម្រាប់វគ្គនេះយើងបាត់បង់ឱកាសក្នុងការ>សួរទៅសាក្សីអ្នកជំនាញពីបញ្ហានេះគឺទាក់ទងនឹងឯកសារ<ដោះបន្ទុក>ដែលដាក់ថ្មីនេះ។ អ៊ីចឹង<ខ្ញុំនឹងកត់សម្គាល់ថា យោងទៅតាមឧបសម្ព័ន្ធសង្ខេបនេះ> គឺភស្តុតាងដែលបង្ហាញនេះ<ត្រូវបានបង្កើតឡើងដោយ> អ៊ិន.ជី.អូ ដដែល ដែលៗចេញរបាយការណ៍ពីរនៅក្នុងសំណុំរឿងដែលបង្ហាញពីមូលដ្ឋានដ៏សំខាន់នៃការចាត់តាំងអ្នកជំនាញមកធ្វើសក្ខីកម្មនេះ។

[០៩:១៥:២៨]

ចំណុចមួយទៀត ខ្ញុំសូមបញ្ជាក់ពីបរិបទ គឺថាដូចដែលយើងបានដឹងហើយ <ប៉ុន្តែយើងគួរតែនិយាយម្តងទៀត>ថា មេធាវីការពារក្តី គឺថាទទួលបាននូវការដាក់បង្ហាញឯកសារនេះដ៏លើសលប់ច្រើនពេក <ជាមួយនឹងសំណើសុំសារណាសម្រាប់ភស្តុតាងថ្មី ដែលមានរយៈពេលជិត២ឆ្នាំមកដល់ពេលនេះ> នៅពេលដែលយើងចំណាយពេលទាំងស្រុងនៅក្នុងសវនាការ។ <វាជាការកត់សម្គាល់ដ៏មានតម្លៃផងដែរ ខ្ញុំគិតថា កាល>ពីសប្តាហ៍មុននេះ ពេលដែលយើង<ធ្វើ>សំណើ<ដោយផ្ទាល់មាត់>តាមវិធាន៨៧(៤) <និងវិធាន៩៣> ទាក់ទងទៅនឹងអ្នកជំនាញនោះគឺថា សហព្រះរាជអាជ្ញាបានរិះគន់យ៉ាងខ្លាំងថា យើងធ្វើសំណើហ្នឹងយឺតពេលខ្លាំងណាស់។

អ៊ីចឹងគឺថា យើងសូមបញ្ជាក់ដោយសង្ខេបថា យើងចង់ដឹងមូលហេតុអ្វីបានសហព្រះរាជអាជ្ញាដាក់បង្ហាញឯកសារ ជាពិសេសឯកសារ<លេខ>១ ឯកសារ<លេខ>៣ ដែលមិន<មានហេតុផលបង្ហាញថាបានទទួលការអនុញ្ញាត>សោះ។ ចំណុចទី២ យើងចង់ដឹងថា ដូចដែលបញ្ជាក់ខាងដើម ឯក-

សារ<ដែលបង្ហាញនេះ> គឺថាត្រូវបានដាក់ចូលក្នុងសំណុំរឿងជាយូរមកហើយ។ <ពួកគេបានបរាជ័យក្នុងការពន្យល់ថា>ហេតុអ្វីក៏មិនដាក់ពីមុនដើម្បីឱ្យយើងមានឱកាសនឹងពិនិត្យមើល ហើយនិងតទល់បាន។ ចំណុចទីបញ្ចប់ ទោះបីជាយើងបានមើលឯកសារហ្នឹងក៏ដោយ យើងក៏ចង់កោះហៅសាក្សីអ្នកជំនាញនៅពេលក្រោយទៀតទាក់ទងទៅនឹងឯកសារដែលបានបង្ហាញថ្មីនេះ។ សូមអរគុណ។

[០៩:១៦:៥៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវីការពារលោក នួន ជា។ ជាបន្តសូមអញ្ជើញលោកមេធាវីក្រុមការពារក្តីលោក ខៀវ សំផន ដើម្បីធ្វើការឆ្លើយតបទៅលើសំណើនេះ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេះ**

ជម្រាបសួរលោកប្រធាន លោកប្រធានមិនសុំឱ្យខ្ញុំឆ្លើយតបទៅនឹង<សំណើរបស់>ព្រះរាជអាជ្ញា<ដែលស្នើសុំឱ្យទទួលយកឯកសារមួយចំនួន>ទេ ព្រោះថាយើងអត់ទាន់បានពិគ្រោះឯកសារហ្នឹងផង ប៉ុន្តែខ្ញុំអាចធ្វើការកត់សម្គាល់ទៅលើមេធាវីលោក នួន ជា បានលើកឡើងអម្បាញ់មិញ។

ជាការពិតណាស់ យើងសង្កេតឃើញដូចក្រុមមេធាវី នួន ជា ដែរ កាលពីម្សិលមិញ យើងឃើញមានការ<បង្ហាញ>ឯកសារ<ទាំងអស់នេះ។> ហើយបើទាក់ទងនឹងកាលប្បវត្តិវិញនោះ គឺថាយើងមាន<ឯកសារមួយចំនួន ជាពិសេសគឺមាន>ឯកសារពីរ<ដូចដែលសហការីខ្ញុំបានលើកឡើងហើយ ដែលឯកសារនោះត្រូវបានដាក់ស្នើសុំជាមួយ>នឹងរបាយការណ៍ <>ដែលធ្វើ<ដោយនរណាម្នាក់>នៅក្នុងអង្គការមិនមែនរដ្ឋាភិបាល<ជាមួយគ្នានឹង>អ្នកជំនាញ<ដែលនឹងមកបង្ហាញខ្លួននៅទីនេះ>។ ហើយក៏មានលើកឡើងផងដែរ បើអាចឯកសារហ្នឹងមិនត្រឹមតែមានតាំងពីឆ្នាំ -- ទី១៧ ធ្នូ ២០១៥ នោះទេលើសពីហ្នឹងទៅទៀតនោះ គឺថានៅក្នុងសំណើថ្ងៃទី២៥ កក្កដា ឆ្នាំ២០១៦ គឺឯកសារ E319/52 <--សហព្រះរាជអាជ្ញាបានយោងទៅលើឯកសារទាំងនោះរួចហើយ ពាក់ព័ន្ធទៅនឹងរបាយការណ៍ដូចគ្នានោះ។ ហើយមនុស្សដូចគ្នាត្រូវបានគេសម្ភាស> ទោះបីជា<យ៉ាងណា> យើងមិនយល់ហេតុអីបាន<ជាការបង្ហាញឯកសារនេះត្រូវបានធ្វើឡើងដោយ>យឺតយ៉ាវ <ព្រោះថា>ឯកសារ<ទាំងនោះ>មានតាំងពីថ្ងៃទី១៧ ធ្នូ ឆ្នាំ២០១៥ <ហើយនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ ឯកសារទាំងនោះត្រូវបាន>អនុញ្ញាត<ឱ្យបង្ហាញ>។ ហើយនៅពេលដែលព្រះរាជអាជ្ញាបានធ្វើសំណើរបស់ខ្លួន គឺថាឯកសារ E319/52 <គឺគេបានយោងទៅនឹងវត្តមាននៃ>ឯកសារ<ទាំងអស់នេះ> ពីព្រោះ<គេត្រូវធ្វើសំណើ>សុំឱ្យទទួល

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យកឯកសារ<ភស្តុតាង ដែល>នៅ<ក្នុង>ប្រភេទឯកសារដូចគ្នា។ អ៊ីចឹង<ខ្ញុំមិនយល់ថា>ហេតុអីបានគាត់ចាំរហូតដល់ពេល<>មួយថ្ងៃមុនពេលអ្នកជំនាញនោះមក<>ផ្ដល់សក្ខីកម្ម <ទើបគេដាក់សារណានេះ>នេះ។ <នេះជាអ្វីដែលខ្ញុំចង់បន្ថែម ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា>ឯកសារ២៧ <មកពីឯកសារលេខ> <E319/52> <ឧបសម្ព័ន្ធនៃសំណើ>ហ្នឹង <បានចុះកាលបរិច្ឆេទខែកក្កដា ឆ្នាំ២០១៦។ ឯកសារទាំងអស់នេះចេញមកពី>បញ្ជីដូចគ្នា <នឹង>ឯកសារ<ដែលសហព្រះរាជអាជ្ញាបានបង្ហាញ>យើង<កាលពី>ម្សិលមិញហ្នឹង។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។

ជាបន្តផ្ដល់វេទិកាទៅសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការឆ្លើយតប ប្រសិនបើមាន។

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខាងមេធាវីនាំមុខអត់មានអ្វីកត់សម្គាល់ទេលោកប្រធាន។

[០៩:២០:០០]

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅទៀត ផ្ដល់វេទិកាទៅសហព្រះរាជអាជ្ញាធ្វើការឆ្លើយតប។

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជាបឋម ពាក់ព័ន្ធទៅនឹងការដាក់បង្ហាញឯកសារទាំងនេះ ការអនុញ្ញាតឲ្យបង្ហាញឯកសារភាគច្រើន គឺត្រូវផ្ដល់ដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៣១ ខែសីហា កន្លងទៅនេះឯង។ ជាលទ្ធផលនោះគឺថា យើងបានពិនិត្យមើលឯកសារទាំងនោះមានឯកសារបួន ដែលទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវដែលធ្វើឡើងដោយ រ៉ូសែល ប្រាហ្វ ដែលគេធ្វើរបាយការណ៍ទាក់ទងទៅអំពើហិង្សាផ្លូវភេទ ប្រឆាំងនឹងជនជាតិភាគតិច។ ហើយឯកសារពីទី៦ ដល់៩ ទាក់ទងទៅនឹងចម្លើយរបស់សាក្សីថា គេមិនត្រូវបានបង្ខំឲ្យរៀបការនោះទេ។ អាហ្នឹង <ហើយជាមូលហេតុដែល>យើងដាក់បង្ហាញ<វានោះ។> យើងក៏បានដាក់បង្ហាញរួមជាមួយនឹងឯក-សារ២៣ ទៀត<ដែលបានពីការសិក្សារបស់គាត់>នោះដែរ។ ក្នុងការសិក្សារបស់គាត់នោះដែលៗថាមនុស្ស២៣ ត្រូវបានបង្ខំឲ្យរៀបការ ហើយនិងតាមវិធាន៨៧(៤) យើងដាក់សំណើសុំ ដាក់បង្ហាញដាក់ជាភស្តុតាង<នៅថ្ងៃទី០១ ខែកញ្ញា>។ <វាសមហេតុផលបើសហព្រះរាជអាជ្ញាស្នើសុំដាក់ភស្តុតាង

តាមវិធាន៨៧(៤) ក្នុងការដាក់>ភស្តុតាងដាក់បន្ទុកទាក់ទងទៅនឹងការរៀបការដោយបង្ខំ ដែលយកចេញអំពីការសិក្សានៅក្នុងរបាយការណ៍នេះ<> មិនមែនសម្រាប់សាក្សីនោះទេ គឺរបាយការណ៍មួយទៀត<នៅចំពោះមុខអង្គជំនុំជម្រះនេះ>។ អ៊ីចឹងគឺថាធ្វើឲ្យមានយុត្តិធម៌ ដើម្បីឲ្យផ្តល់នូវលទ្ធផលនៃការស្រាវជ្រាវបួនផ្សេងទៀត។ ហើយយើងស្នើសុំដើម្បីបង្ហាញទៅមេធាវីការពារផងដែរ គឺក្នុងចំណោមឯកសារទាំងបួននោះមិនបានបញ្ជាក់ថាអ្នកទាំងបួននេះត្រូវបានបង្ខំឲ្យរៀបការនោះទេ ដែលថាមិនអាចនឹង មិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសក្ខីកម្មរបស់អ្នកជំនាញនៅថ្ងៃនេះនោះទេ។ <ទាក់ទងទៅនឹងការតវ៉ារបស់មេធាវីការពារក្តីចំពោះ>ឯកសារ<លេខ>១ និង<លេខ>៣ <>ដែលថាមិនមាន<ហេតុផលក្នុងការបង្ហាញឯកសារ>ហ្នឹង <បើលោកចៅក្រមពិនិត្យមើល>ឧបសម្ព័ន្ធ<> <E319/59.2> ហ្នឹងគឺ<នឹងឃើញ>ថា ឯកសារពីរ<នេះ>គឺដែលថាចេញពីសាក្សីពីរ ហើយសហព្រះរាជអាជ្ញាបានស្នើសុំពីដំបូងនៃរឿងក្តីនេះ គឺថាអង្គជំនុំជម្រះបានណែនាំឲ្យយើងគោរពកាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសារ។ អ៊ីចឹងយើងបានដឹងអំពីកាតព្វកិច្ច<ក្នុង>ការដាក់បង្ហាញឯកសារដែលដោះបន្ទុកនេះ។ <ហើយអង្គជំនុំជម្រះបានចេញសេចក្តីសម្រេច>នៅក្នុងឯកសារ <E363> គឺថាដែល<ជាការបង្ហាញឯកសារសម្រេចនៅ>ថ្ងៃទី២២ តុលា ឆ្នាំ២០១៥ <ដែលយើងបន្តមានកាតព្វកិច្ច>ដាក់បង្ហាញ<ឯកសារដោះបន្ទុកភ្លាមៗក្រោយពេលបញ្ចប់>ដំណើរការសវនាការ។

[០៩:២៣:២៥]

<ហើយមេធាវីការពារក្តីអាចសប្បាយចិត្ត ដោយ>ឯកសារ<ត្រូវបានដាក់>នៅក្នុងរឿងក្តី០០៣ និង ០០៤ <ហើយគេទទួលបាន>ការអនុញ្ញាត<ដោយសហចៅក្រមស៊ើបអង្កេតថា>នឹងមានឯកសារសម្ភារៈ ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការយើងនឹងដាក់បង្ហាញនូវដំណាក់ការមួយៗ។ នេះហើយគឺជាលក្ខណៈដែលថាយើងត្រូវធ្វើសវនាការក្នុងពេលដែលមានកិច្ចស៊ើបសួរដំណាល ក្នុងពេលដំណាលគ្នានោះ។ <ហើយយើងសូមបញ្ជាក់ថា វាគឺដាច់ខាតស្ថិតនៅក្រោមមូលដ្ឋាននៃ>ការអនុញ្ញាត<ដែលផ្តល់ឲ្យ>នៅថ្ងៃទី៣១ ខែសីហា សម្រាប់ឯកសារភាគច្រើន ហើយយើងនឹងពិនិត្យមើលតាមហ្នឹង និងដាក់បង្ហាញ។

<នៅពេលទទួលបាន>ការអនុញ្ញាតទាក់ទងទៅនឹងរបាយការណ៍របស់ រ៉ូសែល ប្រាហ្វ នោះ គឺ<ជាលទ្ធផលនៃការ>ស្នើតាមវិធាន៨៧(៤)ជាភស្តុតាងដោះបន្ទុក។ គាត់បានមានចម្លើយដែលផ្តល់ទៅសហចៅក្រមស៊ើបអង្កេតឃើញមានអត្ថបទស្រាវជ្រាវគឺថា ឯកសារ៤ និង ៥ ហើយការអនុញ្ញាត

ចំពោះការបង្ហាញឯកសារទាំងនោះត្រូវបានផ្ដល់នៅក្នុងខែធ្នូឆ្នាំទៅ។

លោក លោកស្រីចៅក្រមចងចាំហើយថា មេធាវីការពារក្ដីបានតវ៉ាយ៉ាងខ្លាំងអំពីការដាក់បង្ហាញឯកសារច្រើនពេកតាំងពីដំបូងនៃកិច្ចដំណើរការម្ល៉េះ។ គឺថាក្រុមទាំងពីរហ្នឹងក៏តវ៉ាថាពួកគេទទួលព័ត៌មានច្រើនពេកដែលពិបាករៀបចំ។ ដូចដែលលោក លោកស្រីចៅក្រមជ្រាបហើយ គឺថាសហព្រះរាជអាជ្ញាក៏មានការងារច្រើនតាំងពីដំបូងនៃកិច្ចដំណើរការសវនាការដែរ គឺថាយើងត្រូវពិនិត្យមើលថា តើឯកសារសម្ភារៈណាដែលទាក់ទងទៅនឹងភស្តុតាង ឬហេតុការណ៍ដែលនឹងត្រូវយកមកធ្វើសវនាការនោះ គឺថាយើងនឹងត្រូវបង្ហាញឲ្យមេធាវីការពារក្ដីដឹង។

[០៩:២៥:២០]

<ជាលទ្ធផលនៃដំណោះស្រាយដ៏ធំ ដើម្បីបំពេញ>កាតព្វកិច្ចរបស់យើង<ក្នុងការបង្ហាញភស្តុ-តាងដោះបន្ទុក ដែលយើងបានអនុម័តនោះ ដូចលោក លោកស្រីចៅក្រមនៅចាំហើយ មេធាវីការពារក្ដីបានតវ៉ាថា ពួកគេបានទទួល>ឯកសារហ្នឹងវាច្រើនលើសលប់ពេកទេ។ <លោក លោកស្រីចៅក្រមនឹងមិនភ្លេចទេ ក្រុម>មេធាវី នួន ជា ថាយើងមិនចង់បានឯកសារបន្ថែមអ្វីច្រើនទៀតទេ។ <ប៉ុន្តែយ៉ាងនោះក្ដី យើងនៅតែបំពេញ>កាតព្វកិច្ចក្នុងការដាក់បង្ហាញឯកសាររបស់យើង។ អ៊ីចឹងនៅថ្ងៃទី២២ តុលា ឆ្នាំ២០១៥ គឺថា E363 នោះគឺអង្គជំនុំជម្រះបានកម្រិតនូវនីតិវិធីតឹងរ៉ឹងមួយគឺថា ដែលជំរុញឲ្យសហព្រះរាជអាជ្ញាផ្ដោតអារម្មណ៍លើការដាក់បង្ហាញឯកសារ <ជាពិសេស>គឺថាជាការដាក់បង្ហាញឯកសារដោះបន្ទុក <មិនមែនអ្វីៗដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬហេតុការណ៍ដែលកំពុងជំនុំជម្រះនោះទេ ប៉ុន្តែគឺ>ឯកសារទាំងឡាយណាដែលពិនិត្យមើលទៅគឺថា ពិនិត្យជាឯកសារដោះបន្ទុកនោះឯង។ ហេតុដូច្នេះនៅពេលដែលមានសេចក្ដីសម្រេចនោះហើយ ទោះបីជារបាយការណ៍របស់ រ៉ូសែល ប្រាហ្វ បាននៅក្នុងសំណុំរឿងហើយ <ហើយ>យើង<បានទទួល>ការអនុញ្ញាត<ឲ្យបង្ហាញឯកសារនោះ> គឺក្នុងឆ្នាំ២០១៥<ក៏ដោយ ក៏ក្រោយពីបង្រួមកាតព្វកិច្ចក្នុងការបង្ហាញឯកសាររួចមក ដែលលោក លោកស្រីបានដាក់ឲ្យសហព្រះរាជអាជ្ញានោះ> នៅដំណាក់កាលនោះ យើងបានគិតថាអាចនឹងសមស្របទៅតាមលក្ខណៈវិនិច្ឆ័យដែលអង្គជំនុំជម្រះបានកំណត់។ ហើយរបាយការណ៍ ហើយនិងទម្រង់សិក្សាស្រាវជ្រាវនោះ គឺថាមិនមែនជាភស្តុតាងដោះបន្ទុកទេ គឺវាទាក់ទងទៅនឹងព័ត៌មានក្នុងការរៀបចំរបាយការណ៍តែប៉ុណ្ណោះ។ <វាមិនមានព័ត៌មានដោះបន្ទុកនោះទេ។> ហើយនៅក្នុងរបបមួយដែលកម្រិតបែបនេះ ដែលសហព្រះរាជអាជ្ញាគិតថា សម្រេចថាឯកសារទាំងនោះមិនត្រូវដាក់បង្ហាញទេ គឺឯកសារ៤ និង៥ នៅ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្នុងឧបសម្ព័ន្ធ។

[០៩:២៧:២៦]

នៅពេលដែលយើងបានធ្វើការពិនិត្យនូវព័ត៌មាន ឬក៏សម្ភារៈរបស់របាយការណ៍ រ៉ូសែល នោះគឺថា<ដូចយើងបានបញ្ជាក់មុននេះអ៊ីចឹង> ក្នុងចំណោមការសិក្សា៤៧នោះ ដែលគាំទ្ររបាយការណ៍ហ្នឹង គឺយើងបានដាក់បង្ហាញតែ<២៣ឯកសារទេ> តាមវិធាន៨៧(៤) <ដែល>យើងយល់ថាជាភស្តុតាងដោះបន្ទុក។ ហើយយើងបានយល់ថា ជាពេលសមស្រប<ក្នុងការដាក់>ឯកសារ<>សិក្សាស្រាវជ្រាវ<បួនទៀត>ដែលនៅក្នុងងនោះអ្នកផ្តល់សម្ភាសមិនត្រូវបានបង្ខំឲ្យរៀបការនោះទេ។ <គឺយើងធ្វើតាមមូលដ្ឋាននេះ។> បន្ទាប់មកសេចក្តីសម្រេចក៏បាន<សម្រេចថា បើយើង>ដាក់បង្ហាញនូវឯកសារទាំងហ្នឹងគឺថាអាចមានសារប្រយោជន៍<ដល់>មេធាវីការពារក្តី ដើម្បីឲ្យគេបានពិនិត្យមើលវិធីសាស្ត្រ។ អ៊ីចឹងហើយយើងខ្ញុំក៏បានសម្រេចថានឹងដាក់បង្ហាញឯកសារបួននេះ។ ចំពោះរបាយការណ៍របស់រ៉ូសែល ប្រាហ្ វ ហ្នឹងនៅក្នុង<ឯកសារលេខ>៤ <និងលេខ>៥ <>មិន<>មានភស្តុតាងដោះបន្ទុកទេ ប៉ុន្តែវាមានសារប្រយោជន៍ដល់មេធាវីការពារក្តី។

លោកស្រីចៅក្រម ពាក់ព័ន្ធទៅនឹងសក្ខីកម្មថ្ងៃនេះគឺថា យើងបានឯកសារហើយ។ ខ្ញុំនឹងសង្ខេបដោយខ្លី។ <លោក លោកស្រីចៅក្រមបានឃើញឯកសារនោះហើយ ហើយខ្ញុំគិតច្បាស់ណាស់>សាក្សី<នេះ>អាចនឹងផ្តល់សក្ខីកម្មបញ្ជាក់ពីភស្តុតាង ឬក៏ជាសម្ភារៈនោះ ទាំងនោះបាន។ អ៊ីចឹងសូមរំឭកអង្គជំនុំជម្រះថា <នៅពេល>មេធាវីការពារក្តី នួន ជា បានលើកឡើងពីការយកចិត្តទុកដាក់ឲ្យគ្រប់គ្រាន់<នោះ> គឺពួកគាត់<កាលពីសប្តាហ៍មុន>បានស្នើសុំឲ្យមានឯកសារស្ទើរតែ២.២០០ទំព័រ ដែលឲ្យអ្នកជំនាញផ្តល់<ក្នុងរយៈពេល៧ថ្ងៃ ហើយពួកគាត់ដឹង>ថា <អ្នកជំនាញបានមកផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះនេះនៅ>ថ្ងៃទី០៣ ខែមិថុនា<>។ <ចំណុចចុងក្រោយ ទាក់ទងទៅនឹងសារណារបស់ក្រុមលោក នួន ជា ដែលផ្អែកទៅលើ>របាយការណ៍ រ៉ូសែល ប្រាហ្ វ <ឬផ្អែកលើ>ផ្អែក<>មូលដ្ឋាននៃការកោះអញ្ជើញសាក្សីជំនាញនេះ <គឺ>មិនត្រឹមត្រូវទេ។ <សាក្សីអ្នកជំនាញនេះត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម ដូចដែលយើងបានឃើញនៅក្នុង>សេចក្តីសម្រេច<អ៊ីចឹង គឺ>ផ្អែកលើរបាយការណ៍របស់គាត់ទេ <មិនមែនលើ>មូលដ្ឋាន<របស់បុគ្គលម្នាក់ផ្សេងទៀតដែលធ្វើរបាយការណ៍ឡើយ>។ បាទ សូមអរគុណ។

[០៩:២៩:៥៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមឱ្យភាគីផ្តោតអារម្មណ៍ទៅលើអ្វីដែលខ្ញុំគិតថាវាមានបញ្ហាបច្ចេកទេសច្រើន គឺមានឯកសារដែលមានការពាក់ព័ន្ធសំខាន់ទាក់ទងទៅនឹងការតាំងសំណួរទៅអ្នកជំនាញនេះ។ <ឥឡូវនេះ គ្រាន់តែ>ព័ត៌មានមួយ<ផ្នែក យើងត្រូវការពេលវេលា>៤៨ម៉ោង <រវាងការបង្ហាញឯកសារ និងការអនុញ្ញាតឱ្យ>ភាគី<>អាចពិនិត្យមើលបាន <ដូច្នេះច្បាស់ណាស់ថា វាគ្មានប្រយោជន៍អីទេ>។ <>ការ<>ដាក់បង្ហាញឯកសារនៅម៉ោងបួន<>មួយថ្ងៃមុន<អ្នកជំនាញផ្តល់សក្ខីកម្ម>នោះ <ច្បាស់ជាគ្មានប្រយោជន៍អ្វីទេ។ ត្រូវដាក់ឱ្យបានសមរម្យ>។ អ៊ីចឹងយើងរំពឹងឱ្យមានការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ផ្អែកលើការតវ៉ារបស់ភាគីម្ខាងទៀត គឺមេធាវីការពារក្តីនោះ។

**លោក វីល្លៀម ស្មីត៖**

លោកស្រីចៅក្រម គឺថាពេលវេលាហ្នឹង<គ្រាន់តែជាការចៃដន្យប៉ុណ្ណោះ។> ការអនុញ្ញាត<បង្ហាញឯកសារទាំង>នោះ <បានមកដល់>នៅថ្ងៃទី៣១ ខែសីហា។ អ៊ីចឹង គឺថាមានរយៈពេល<១២>ថ្ងៃ។ <ការ>ស្នើតាមវិធាន៨៧(៤) <ដែលលោកស្រីចៅក្រមបានសួរនោះ ប្រហែលជាមានការលើកលែងមួយចំនួន> គឺថាអាចនៅថ្ងៃទី០១ កញ្ញា<>។ អ៊ីចឹង គឺថាសហព្រះរាជអាជ្ញា បាន<ផ្តល់>អាទិភាព<ដល់>ឯកសារ<ស្រាវជ្រាវទាំង>២៣ <ហើយ>យើងបានដាក់បង្ហាញតាមវិធាន៨៧(៤) ហើយវាមានរបាយការណ៍អ្នកជំនាញបួនទៀតដែលយើងត្រូវតែដាក់បង្ហាញដែរ។ គិតថាចំណុចមួយចុងក្រោយ លោកស្រីចៅក្រម សហព្រះរាជអាជ្ញា គឺថាៗមានការលំបាក ក៏ពិបាកដូចខាងមេធាវីការពារក្តីនោះដែរ។ <ករណីរបស់ព្រះរាជអាជ្ញា> គឺថា<មិនមែនមនុស្ស>គ្រប់ៗគ្នាដែលបានរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សុទ្ធតែត្រូវបានបង្ខំ<នោះទេ។ វាមិនមែនជាករណីនោះទេ។> ប៉ុន្តែ<អ្វីដែលជាករណីរបស់ព្រះរាជអាជ្ញានោះគឺថា មានការ>បង្ខំ<ឱ្យរៀបការជាប្រព័ន្ធ។ អង្គហេតុដែល>របាយការណ៍បួននេះ គឺថាបញ្ជាក់ថា មនុស្សបួននាក់និយាយថា ពួកគេមិនត្រូវបានគេបង្ខំឱ្យរៀបការទេ <គឺមិនមែនជាឯកសារដោះបន្ទុកដោយផ្ទាល់សម្រាប់ករណីនេះទេ>។ ប៉ុន្តែ<វាមានសារៈសំខាន់ ដែលឯកសារនេះត្រូវបានបង្ហាញ>។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

[០៩:៣២:២៨]

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកប្រធាន។ អ៊ឺចឹង ខ្ញុំផ្តល់សេចក្តីសង្ខេតដោយខ្លី។ អ្វីដែលបានឮពីសហព្រះរាជអាជ្ញានោះ គឺថាយើង<នៅតែ>មិនច្បាស់ ហេតុអ្វីបានមានការដាក់បង្ហាញឯកសារ<ទើបតែធ្វើ>នៅពេលនេះ ពីព្រោះថា ដោយសារឯកសារ និង ការអនុញ្ញាតនុំងតាំងពីខែវិច្ឆិកា ឆ្នាំ២០១៣។ <ចំណុចមួយទៀតគឺ តាមរយៈ>អ្វីដែលយើងយល់<ពីសារណាផ្ទាល់មាត់> ដែល<ធ្វើនៅក្នុងសវនាការនេះដោយ>សហព្រះរាជអាជ្ញា<>ពីអាទិត្យមុននោះ គឺថា<សហព្រះរាជអាជ្ញា>បានបញ្ជាក់យ៉ាងច្បាស់ថា <ទោះជាឧបសគ្គយ៉ាងណាក៏ដោយ គឺ>ខ្លួនមានឯកសារភស្តុតាងសម្ភារៈ<ដែលចាំបាច់ត្រូវបង្ហាញដល់យើងខ្ញុំ។> យើងយល់ថា ឯកសារទាំងអស់ដែលបានមានកាលបរិច្ឆេទពីមុននោះ យើងមានការពិភាក្សាគឺថានៅក្នុងខែសីហា ឆ្នាំ<២០១៦>។ បើសិនបើមានភាពពាក់ព័ន្ធ ត្រូវតែដាក់បង្ហាញ ហើយយើងនឹង<>ទៅមុខទៀត <ហើយឯកសារដែលត្រូវបង្ហាញនៅពេលអនាគត>យើង<គួរតែ>ទទួល<បាន> គឺ<អាច>ជាឯកសារដែលបាន<បង្កើតឡើង>បន្ទាប់ពីកាលបរិច្ឆេទនោះ។ ប៉ុន្តែមកដល់ពេលនេះ គឺថាយើងយល់បែបនោះ គឺជាការមិនត្រឹមត្រូវទេ។ <ដូច្នេះ>គឺថាយើង<ដូចជាបាត់បង់មិនបាន>ទទួល<នូវ>ការបង្ហាញឯកសារ<នាពេលអនាគត ដែលពាក់ព័ន្ធនឹងវគ្គសវនាការដែលកំពុងបន្តនេះ>។ អ៊ឺចឹង គឺថាចំណុចមួយទៀត គឺវិធាន៨៣ <និង>វិធាន<៩៣ ដែលយើងស្នើសុំដោយយោងទៅលើ>អ្នកជំនាញ<ដែលនឹងចូលមកនាពេលខាងមុខនោះ> គឺសហព្រះរាជអាជ្ញាជាអ្នកកត់សម្គាល់<>ថា <សវ-នាការ>ផ្នែកនេះ គឺត្រូវបានដាក់បញ្ចូលនៅក្នុងរឿងក្តី០០២/០២ ហ្នឹងជាយូរហើយ ដូច្នេះគាត់ដឹងថាឯកសារណាខ្លះដែលពាក់ព័ន្ធ<ដែលត្រូវតែស្នើសុំ>នោះ។ អ៊ឺចឹង គឺថាវិធាននេះត្រូវអនុវត្តស្មើគ្នាចំពោះសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីផងដែរ។ សូមអរគុណ។

[០៩:៣៤:០៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះស្តាប់បានហើយលើបញ្ហានេះ ហេតុដូច្នេះ សូមបញ្ចប់បញ្ហានេះត្រឹមនេះ។

បញ្ហាទី២ -- អរគុណភាគី។ បញ្ហាទី២ អង្គជំនុំជម្រះបានទទួលអ៊ីម៉ែលពីការិយាល័យសហព្រះរាជអាជ្ញាពាក់ព័ន្ធផែនទីចំនួនពីរ។ ផែនទីមួយក្នុងចំណោមផែនទីទាំងពីរនេះ គឺសហព្រះរាជអាជ្ញាមានបំណងប្រើប្រាស់ក្នុងការសួរដេញដោលទៅអ្នកជំនាញ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាមានបំណងស្នើសុំឱ្យទទួលយកផែនទីនេះជាភស្តុតាង។

អង្គជំនុំជម្រះមានបំណងស្តាប់នូវសារណាផ្ទាល់មាត់របស់ភាគីទៅលើសំណើសុំនេះ។

ជាដំបូង សូមផ្តល់វេទិកាទៅមេធាវីការពារលោក នួន ជា ធ្វើការឆ្លើយតបទៅលើសំណើសុំនេះ។ សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

[០៩:៣៥:០៥]

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកប្រធាន។ យើងមិនជំទាស់ទេ អ្វីដែលយើងចង់លើកឡើង គឺថា យើងតម្រូវឱ្យដាក់បញ្ជីទៅចំពោះមុខអ្នកជំនាញតាំងពីមុនមកម្ល៉េះ ហើយវាត្រូវការធនធានមនុស្សច្រើនដើម្បីឱ្យធ្វើកិច្ចការនេះ។ ដូច្នេះ យើងគិតថា សំណើសុំនេះហាក់ដូចជាយឺតយ៉ាវបន្តិចហើយ ក៏ប៉ុន្តែយើងខ្ញុំមិនជំទាស់ទៅនឹងសំណើសុំនេះទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។

សូមអញ្ជើញលោកមេធាវី ខៀវ សំផន ប្រសិនបើមាន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនច្បាស់អំពីបញ្ហានៃផែនទីនេះ។ ខ្ញុំដឹងថា <មូលដ្ឋានដែល> សហព្រះរាជអាជ្ញាគាត់ចង់ប្រើប្រាស់ផែនទីនេះ <-- សូមកែខ្ញុំ បើសិនជាខ្ញុំខុស -- គឺ>ឯកសារហ្នឹងមានលេខ E3/2959។ បើខ្ញុំយល់អំពីគោលការណ៍នៃផែនទីដែលមានការអត្ថាធិប្បាយនេះ គឺសហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ជាអ្នកចារនៅលើផែនទីដែលមាននៅក្នុងសំណុំរឿង<រួចហើយ>។ អ៊ីចឹងមិនមែនជាចំណាររបស់អ្នកជំនាញទេ។ បើជាចំណាររបស់សហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ យើងខ្ញុំជំទាស់ក្នុងការស្នើសុំឯកសារនេះដាក់ក្នុងសំណុំរឿង ពីព្រោះថា<យើង>មិនមែន<មកទីនេះដើម្បីបង្កើត>ភស្តុតាងទេ<>។ ក៏ប៉ុន្តែបើសិនជាអ្នកជំនាញគាត់ចារនោះ អាហ្នឹងមិនអីទេ យើងអាចទទួលយកជាភស្តុតាងបាន <ប៉ុន្តែគ្មានភាគីណាមួយអាចផ្តល់មតិយោបល់ដោយខ្លួនឯងទៅលើឯកសារនានា ដែលត្រូវទទួលយកជាភ័ស្តុតាងនោះទេ>។ អ៊ីចឹងខ្ញុំអត់ទាន់យល់ច្បាស់អំពីជំហររបស់សហព្រះរាជអាជ្ញា មិនដឹងថាតើគាត់ចង់ដាក់ឯកសារដែលមានចំណារហ្នឹង ជាចំណាររបស់អ្នកណា។ អ៊ីចឹងខ្ញុំបញ្ជាក់ម្តងទៀត បើចំណារហ្នឹងជារបស់សហព្រះរាជអាជ្ញារបស់ខ្លួន ជារបស់ព្រះរាជាអាជ្ញា យើងខ្ញុំជំទាស់មិនឱ្យដាក់ឯកសារនេះក្នុងសំណុំរឿងទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៣៧:០១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថាយើងប្រហែលឲ្យ ផ្តល់ឱកាសឲ្យសហព្រះរាជអាជ្ញាធ្វើសំណើនេះជាផ្លូវការ។ បុគ្គលិកបានជម្រាបមកថា ឯកសារដែលបានស្នើសុំឲ្យដាក់បង្ហាញនេះគឺថា មានហើយ អាចយកមកប្រើប្រាស់បានហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា សូមលោកលើកឲ្យបានខ្លី។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំយល់ឃើញថា ផែនទីនេះ<មិនទាន់មាននៅក្នុងសំណុំរឿងទេ> គឺឯកសារ <E3/2959> <ជាសៀវភៅរបស់អ្នកជំនាញ។ មូលហេតុដែលយើងស្នើសុំឲ្យដាក់ផែនទីនេះ គឺ>វាអាចប្រហែលជាជួយទៅឲ្យសាក្សីពន្យល់អំពីទីតាំងផ្សេងៗ ដែលគាត់បានធ្វើការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។ បាទ អ្នកជំនាញ គឺប្រហែលជាវាក៏អាចឲ្យអ្នកជំនាញធ្វើការបង្ហាញមានលក្ខណៈងាយស្រួលផងដែរបាទ <ដូច្នេះហើយយើងអាចយល់ភ័ស្តុតាងរបស់គាត់កាន់តែច្បាស់>។ <ពាក់ព័ន្ធទៅនឹងចំណារនៅលើ>ផែនទីនេះ គឺភាគច្រើនគ្របដណ្តប់ទៅលើតំបន់ដែលអ្នកជំនាញរូបនេះក៏ដូចជាអ្នកជំនាញដទៃទៀត បានចេញជារបាយការណ៍ហើយដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះហើយដែលអ្នកជំនាញទាំងនោះធ្វើការសិក្សាស្រាវជ្រាវ ទាក់ទងទៅនឹងអំពើហិង្សាផ្លូវភេទនេះ។ ហើយអ្វីដែលយើងខ្ញុំស្នើសុំដែលមាននៅក្នុងរបាយការណ៍នោះគឺ ផែនទី<ដែលមានការកត់សម្គាល់នៅលើនោះ> ដែលជាលទ្ធផលបានមកពីការសិក្សាស្រាវជ្រាវនេះ។ <ដូច្នេះវាមិនមែនជាសារណាមួយ>ដែល<ព្រះរាជអាជ្ញាគ្រាន់តែដាក់ស៊កនៅចន្លោះកណ្តាលនោះទេ -- >គឺថា វាមានទិន្នន័យ មាន*ដេតា* ចេញមកពីរបាយការណ៍របស់អ្នកជំនាញ<ផ្សេងទៀត>ផងដែរ<ដើម្បីជួយដល់ការពិភាក្សា>។ ដូច្នេះ ផែនទីដែលមានចំណារ<>នេះ <យើងពិតជារីករាយដែលត្រូវបានយកមកប្រើដើម្បីបង្ហាញពីគោលបំណងប៉ុន្តែ>ផែនទីចម្បង<ដែលនិយាយពីគមនាគមន៍នៅកម្ពុជានោះ យើង>អាចស្នើសុំឲ្យដាក់ធ្វើជាភស្តុតាងដើម្បីឲ្យយើងបានស្វែងយល់អំពីភស្តុតាងនៅក្នុងសំណុំរឿងនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ សូមអញ្ជើញមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើមាន

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បំណងឆ្លើយតប។

[០៩:៣៩:៤៦]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ យើងខ្ញុំមិនមានមតិយោបល់អ្វីទៅលើផែនទីនេះទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤១:១៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺពាក់ព័ន្ធទៅនឹងសំណួរមួយខ្លីទេ។ គឺពាក់ព័ន្ធទៅនឹងការរៀបចំនេះ។ តើលោកត្រូវការផែនទីនេះ មុនពេលឈប់សម្រាក ឬក៏ក្រោយពេលឈប់សម្រាក?

**លោក វីល្លៀម ស្មីត៖**

អ៊ីចឹង យើងខ្ញុំអាចរង់ចាំបាន។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៀតយើងបន្តសវនាការ។ មន្ត្រីរដ្ឋបាលតុលាការអញ្ជើញអ្នកជំនាញ 2-TCE-82 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(អ្នកជំនាញចូលក្នុងបន្ទប់សវនាការ)*

[០៩:៤៣:២៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្ដីអ្នកជំនាញ តើកញ្ញាមានឈ្មោះអ្វីដែរ?

**កញ្ញា កាស៊ូមិ ណាកាហ្គាវ៉ា៖**

**ឆ៖** ខ្ញុំឈ្មោះ កាស៊ូមិ ណាកាហ្គាវ៉ា។

**ស៖** តើកញ្ញា កើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ?

**ធ៖** ខ្ញុំកើតនៅក្នុងឆ្នាំ១៩៧២ ខែមិថុនា ទី១១។

**ស៖** តើកញ្ញាមានសញ្ជាតិអ្វីដែរ?

**ធ៖** ខ្ញុំជាជនជាតិជប៉ុន។

**ស៖** អរគុណកញ្ញា។ ហើយសព្វថ្ងៃ កញ្ញាមានលំនៅអចិន្ត្រៃយ៍នៅទីកន្លែងណាដែរ?

**ធ៖** និវេសនដ្ឋានប្រចាំការរបស់ខ្ញុំ គឺថានៅប្រទេសជប៉ុន នៅទីក្រុងកូបេ។

**ស៖** អរគុណកញ្ញា។ តើសព្វថ្ងៃកញ្ញាប្រកបមុខរបរអ្វីដែរ?

**ធ៖** ខ្ញុំបង្រៀននៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៅក្នុងទីក្រុងភ្នំពេញ។

**ស៖** តើកញ្ញាប្រតិបត្តិសាសនាអ្វីដែរ?

**ធ៖** ខ្ញុំមិនមានកាន់សាសនាអ្វីទេ។

[០៩:៤៥:០៥]

**ស៖** អរគុណកញ្ញា។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលម្សិលមិញថា តាមសមត្ថភាពដែលកញ្ញាបានដឹង គឺកញ្ញាមិនមានចំណងញាតិលោហិត ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ។ តើពិតមែនដែរឬទេ?

**ធ៖** ត្រឹមត្រូវហើយ។

**ស៖** អរគុណកញ្ញា។ កញ្ញា កាស៊ូមិ ដោយអនុវត្តអនុលោមតាមវិធាន៣១(២) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងនាមកញ្ញាជាអ្នកជំនាញ ដែលត្រូវនឹងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។តម្រូវឲ្យកញ្ញាធ្វើសម្បថ ឬក៏ធ្វើសច្ចាប្រណិធានជាមុនសិនតាមជំនឿសាសនាមុននឹងផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ។

ក្រឡាបញ្ជីសវនាការ កញ្ញា ម៉ាឌីលេណា សូមណែនាំអំពីនីតិវិធីសម្បថដល់អ្នកជំនាញនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអញ្ជើញ!

[០៩:៤៦:១៧]

**ក្រឡាបញ្ជី៖**

អរុណសួស្តីលោកស្រី កាស៊ូមិ សូមអញ្ជើញក្រោកឈរ និងថាតាមខ្ញុំ។

**កញ្ញា កាស៊ូមិ ណាកាហ្កាវ៉ា៖**

ខ្ញុំសូមស្បថជាឱឡារិកថានៅចំពោះមុខអង្គជំនុំជម្រះដោយអស់ពីដួងចិត្ត។ ខ្ញុំសូមស្បថថា ខ្ញុំនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងដោយស្មោះ ជាសម្ងាត់ និងឲ្យអស់ពីលទ្ធភាពរបស់ខ្ញុំ។

**ក្រឡាបញ្ជី៖**

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះនិងភាគីសូមថ្លែងអំណរគុណចំពោះកញ្ញាដែលបានផ្តល់សក្ខីកម្មនៅទីនេះ ជួយដល់អង្គជំនុំជម្រះក្នុងដំណើរការស្វែងរកការពិត ពាក់ព័ន្ធនឹងបញ្ហានានាដែលមានសារៈសំខាន់ចំពោះសវនាការនេះ និងសម្រាប់ប្រជាជនកម្ពុជា។

ជាបន្តទៀត អង្គជំនុំជម្រះសូមសួរទៅអ្នកជំនាញ ពាក់ព័ន្ធនឹងប្រវត្តិនៃការសិក្សា និងស្នាដៃនិពន្ធមួយចំនួន។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** កញ្ញា កាស៊ូមិ តើកញ្ញាអាចប្រាប់ដល់អង្គជំនុំជម្រះបានទេថា តើកញ្ញាទទួលបានការអប់រំដល់កម្រិតណាដែរ?

[០៩:៤៧:២១]

**កញ្ញា កាស៊ូមិ ណាកាហ្កាវ៉ា៖**

**ឆ៖** សូមអរគុណលោកប្រធាន។ ប្រវត្តិសិក្សារៀនសូត្ររបស់ខ្ញុំនៅក្នុងប្រទេសជប៉ុន។ ក្រោយខ្ញុំបញ្ចប់ការសិក្សានៅថ្នាក់មធ្យមសិក្សា ខ្ញុំបានចូលទៅសាកលវិទ្យាល័យនៅកងគីននោះ គឺនៅក្នុងឆ្នាំ១៩៨១ ហើយខ្ញុំបញ្ចប់នៅក្នុងឆ្នាំ១៩៨៥។ ហើយខ្ញុំបានសិក្សារៀនសូត្រអំពីរបប ប៉ុល ពត។ <បរិញ្ញាបត្ររបស់ខ្ញុំគឺ>អំពីប្រវត្តិ ប៉ុល ពត ថាតើ ប៉ុល ពត ចូលកាន់អំណាចដោយរបៀបណា? តាម<រយៈទស្សនៈ>នយោបាយនេះ ក៏ដូចជាការយល់ឃើញរបស់អន្តរជាតិនាពេលនោះ។ ហើយខ្ញុំបានបន្តយកសញ្ញាបត្រអនុបណ្ឌិតនៅសាកលវិទ្យាល័យអូសាកានៅក្នុងឆ្នាំ១៩៨៦ ហើយដែលខ្ញុំ -- នៅក្នុងឆ្នាំ២០០០ (សូមកែតម្រូវ) ហើយនៅពេលនោះ គឺខ្ញុំសិក្សា និង ស៊ើបអង្កេតអំពីគោលនយោបាយការបរទេសជប៉ុនចំពោះប្រទេសកម្ពុជា <ជាពិសេសគឺក្នុងវិស័យវប្បធម៌>។ ហើយខ្ញុំទទួលបានសញ្ញាបត្រអនុបណ្ឌិតនៅសាកលវិទ្យាល័យអូសាកានេះក្នុងឆ្នាំ២០០០ ផ្នែកខាងវិទ្យាសាស្ត្រនយោបាយ។

**សៈ** អរគុណកញ្ញា។ តើកញ្ញាបានចូលមកប្រទេសកម្ពុជាតាំងពីឆ្នាំណាដែរ ហើយមានគោលបំណងអ្វីដែរ?

**ឆៈ** លើកទី១ ខ្ញុំបានមកជាទេសចរនៅក្នុងឆ្នាំ១៩៩៥ ប៉ុន្តែក្នុងឆ្នាំ១៩៩៧ ខ្ញុំមកកម្ពុជាដើម្បីធ្វើការក្នុងនាមជាជំនួយការពិសេសឲ្យស្ថានទូតជប៉ុននៅក្នុងទីក្រុងភ្នំពេញ ដែលត្រូវបានជ្រើសរើសដោយក្រសួងការបរទេសជប៉ុន។ ខ្ញុំធ្វើការអស់រយៈពេល២ឆ្នាំជាមួយស្ថានទូតជប៉ុន រហូតដល់ខែមីនា ឆ្នាំ១៩៩៩។

[០៩:៤៩:៣៤]

**សៈ** អរគុណកញ្ញា។ តើកញ្ញាចេះអាន ចេះសរសេរ ស្តាប់ ឬចេះនិយាយភាសាខ្មែរបានស្ទាត់ជំនាញដែរឬទេ?

**ឆៈ** សូមអរគុណលោកប្រធាន ក្នុងសួរសំណួរនេះ ខ្ញុំសប្បាយចិត្តណាស់ ខ្ញុំក៏សប្បាយចិត្តក្នុងការនិយាយភាសាខ្មែរ ខ្ញុំចេះអានភាសាខ្មែរ ប៉ុន្តែបើសរសេរវិញគឺថា សរសេរអត់បានល្អទេ។

**សៈ** អរគុណកញ្ញា។ រហូតមកដល់ពេលនេះ តើកញ្ញាបានធ្វើការសិក្សា និងស្រាវជ្រាវអំពីអ្វីខ្លះដែលពាក់ព័ន្ធនឹងប្រទេសកម្ពុជា ជាពិសេសទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆៈ** សូមអរគុណលោកប្រធាន។ ដោយសារថាខ្ញុំជាអ្នកជំនាញខាងផ្នែកយេនឌ័រ ខ្ញុំធ្វើការសិក្សាស្រាវជ្រាវជាច្រើនអំពីយេនឌ័រ និងស្ត្រីនៅក្នុងប្រទេសកម្ពុជា ហើយបានបោះពុម្ពផ្សាយជាច្រើនទៅលើប្រធានបទនេះ។ ខ្ញុំបានធ្វើការជាមួយនឹងអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ជាពិសេសជាមួយក្រសួងកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឋានៈខ្ញុំជាកុងសុលតង់។ ហើយខ្ញុំបានសិក្សាជាច្រើនអំពីស្ត្រីក៏ដូចជាបុរសកម្ពុជា មិនមែនសិក្សាតែនៅថ្នាក់មូលដ្ឋានទេ ក៏ចូលរួមពាក់ព័ន្ធយ៉ាងខ្លាំងពាក់ព័ន្ធទៅនឹងរៀបចំគោលនយោបាយសម្រាប់ប្រទេសកម្ពុជាផងដែរ។ ទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យ ឬក៏ហៅថាខ្មែរក្រហមនេះវិញ ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវមួយចំនួនកន្លងមកនេះ ដែលទាំងអស់នេះគឺពាក់ព័ន្ធទៅនឹងប្រធានបទសម្រាប់សវនាការថ្ងៃនេះ គឺការរៀបការដោយបង្ខំ។

[០៩:៥១:២៦]

ទី១ គឺក្នុងឆ្នាំ២០០៦ នៅពេលដែលខ្ញុំធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលកម្ពុជាហៅថា “អង្គការការពារក្តីកម្ពុជា” ប៉ុន្តែពេលនោះខ្ញុំជាអ្នកគ្រប់គ្រងគម្រោងមួយដែលត្រូវដឹកនាំការសិក្សាស្រាវជ្រាវ

អំពីអំពើហិង្សានៅក្នុងគ្រួសារ -- អំពើហិង្សាផ្លូវភេទនៅក្នុងអំឡុងរបបខ្មែរក្រហម។ ហើយការសិក្សានេះត្រូវបានរៀបចំចងក្រងជាឯកសារជាច្រើនអំពីអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ក៏ដូចជាការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលយើងចេញផ្សាយនៅឆ្នាំ២០០៦។

ការសិក្សាទី២ គឺនៅក្នុងឆ្នាំ២០០៨ ទៅលើប្រធានបទដដែលនេះទេ ក៏ប៉ុន្តែវាផ្តោតពិសេសទៅលើអំពើហិង្សាផ្លូវភេទនិងការរៀបការដោយបង្ខំ។ ខ្ញុំធ្វើការសិក្សាស្រាវជ្រាវជាមួយសិស្សរបស់ខ្ញុំដែលខ្ញុំមានសិស្សពេលនោះមកពីសកលវិទ្យាល័យបញ្ញាសាស្ត្រ ២០០នាក់ ហើយយើងធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះឯង។ ហើយនៅក្នុងឆ្នាំ២០១៤ ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវមួយទៀត និយាយអំពីអំពើហិង្សា<ផ្លូវភេទ>ប្រឆាំងទៅនឹងជនជាតិភាគតិចនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំចងក្រងឯកសារជាច្រើនពាក់ព័ន្ធទៅនឹងអំពើហិង្សាផ្លូវភេទ ហើយនិងការរៀបការដោយបង្ខំដែលពាក់ព័ន្ធទៅនឹងជនជាតិភាគតិចមកពីជាតិសាសន៍ទាំងអស់នៅក្នុងប្រទេសកម្ពុជា។

[០៩:៥៣:១៤]

ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវមួយទៀត ខ្ញុំដាក់ចំណងជើងថាហៅថា *"ម៉ាឌ័រហ្វូត អេតវរ"* ដែលខ្ញុំធ្វើការសិក្សាស្រាវជ្រាវអំពី<ការមានផ្ទៃពោះក្នុង>អំឡុង<របប>ខ្មែរក្រហម ហើយខ្ញុំបានចងក្រងឯកសាររឿងរាវជាច្រើនអំពីការរៀបការ ក៏ដូចជាការរំលោភសេពសន្ថវៈ ឬក៏ការមានផ្ទៃពោះនៅក្នុងសម័យខ្មែរក្រហម។ ក្រោយមកគឺថា<១>ឆ្នាំកន្លងទៅហើយនេះ គិតមកដល់ពេលនេះ គឺថាខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវមួយទៀត អំពី "កុមារភាពនៅក្នុងពេលសង្គ្រាម" ដែលខ្ញុំធ្វើការស៊ើបអង្កេតអំពីជីវិតរបស់កុមារៗ នៅក្នុងសម័យខ្មែរក្រហម ចង់ដឹងថាតើកុមារៗនេះគេត្រូវបានគេបដិសេធកុមារភាពវ័យ ភាពជាកុមារ ភាពរបស់ខ្លួនដោយរបៀបណា? ដែលក្នុងពេលនោះក៏ផ្តោតទៅលើថា ហេតុអីបានជាកុមារីតូចៗក៏ត្រូវគេបង្ខំឲ្យរៀបការផងដែរ។ បាទ ទាំងអស់នេះឯង គឺជាអ្វីដែលខ្ញុំបានធ្វើសិក្សាស្រាវជ្រាវកន្លងមកនៅក្នុងប្រទេសកម្ពុជា។

[០៩:៥៤:៣៣]

**ស៖** ហេតុអ្វីបានកញ្ញាចាប់អារម្មណ៍ក្នុងការសិក្សាស្រាវជ្រាវអំពីបញ្ហានេះ?

**ឆ៖** សូមអរគុណលោកប្រធានដែលបានសួរសំណួរ។ លេខទី១ គឺខ្ញុំចង់ដឹងថាហេតុអីរឿងនេះវាកើតឡើង។ នៅពេលដែលខ្ញុំជាសិស្សនៅក្នុងសកលវិទ្យាល័យ គឺថាមានព័ត៌មានច្របូកច្របល់គ្នាមែន

ទែន អំពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំមិនអាចស្វែងយល់ឲ្យដឹងថាហេតុអីរឿងហ្នឹងវាកើតឡើង ហេតុអីខ្មែរក្រហមឡើងកាន់អំណាចបាន? ហើយហេតុអ្វីបានជាប្រជាជនត្រូវបានគេសម្លាប់ ឬក៏ស្លាប់ច្រើនម្ល៉េះក្នុងសម័យខ្មែរក្រហម? ហើយគឺថាខ្ញុំមានភាពអន្ទះអន្ទែងមែនទែនចង់ដឹង ថាហេតុអ្វីក៏មានរឿងនេះកើតឡើង? ប៉ុន្តែដោយសារតែខ្ញុំជាអ្នកជំនាញផ្នែកខាង យេនឌ័រ អ៊ីចឹងចាប់អារម្មណ៍ជាពិសេសចង់ដឹងថា តើស្ត្រីនេះទទួលរងប៉ះពាល់ដោយសារសង្គ្រាមដោយរបៀបណា? ហើយជាក្នុងការអនុវត្តជាក់ស្តែង តើស្ត្រីនេះវាត្រូវប៉ះពាល់ដោយរបៀបណានៅក្នុងរបបនោះ? ហើយនៅពេលខ្ញុំបង្រៀននៅក្នុងថ្នាក់រៀន សិស្សរបស់ខ្ញុំអត់ដឹងអ្វីទាំងអស់។ ពួកគេអត់បានដឹងអំពីអំពើហិង្សាផ្លូវភេទទេ ពួកគេអត់បានដឹងអំពីការបង្ខំឲ្យរៀបការនៅក្នុងសម័យខ្មែរក្រហមទេ។ អ៊ីចឹងហើយខ្ញុំគិតថា ខ្ញុំនេះអាចចែករំលែកចំណេះដឹងដោយប្រមូលព័ត៌មាន និងភស្តុតាងនានាពាក់ព័ន្ធទៅនឹងថាតើហេតុអ្វីក៏រឿងនេះកើតឡើង ជាពិសេស<អំពីទស្សនៈរបស់>ស្ត្រីនេះតែម្តង ដោយសារថាយើងអត់មានភស្តុតាងណាប្រមូលចងក្រងជាប្រវត្តិសាស្ត្រទេ។ ភាគច្រើននោះគឺថាភស្តុតាង ឬក៏ឯកសារមួយចំនួនសរសេរភាគច្រើនដោយជនរងគ្រោះដោយបុរសពីសម័យខ្មែរក្រហម អត់មានសរសេរដោយស្ត្រីទេ។ អ៊ីចឹងហើយខ្ញុំចំណាប់អារម្មណ៍រឿងនេះឯង។

[០៩:៥៦:៣៤]

**ស៖** អរគុណកញ្ញា។ តើកញ្ញាចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវអំពីរបាយការណ៍មួយដែលមានចំណងជើងថា "អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងរបបខ្មែរក្រហម ឆ្នាំ៧៥ ដល់ ៧៩ រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ" នៅពេលណាដែរ? ហើយបោះពុម្ពដំបូងនៅក្នុងឆ្នាំណាដែរ?

**ឆ៖** សូមអរគុណលោកប្រធាន។ ខ្ញុំចាប់ផ្តើមមានគំនិតនេះគឺនៅក្នុងឆ្នាំ២០០៥ ហើយលំបាកមែនទែនរកអ្នកឧបត្ថម្ភថវិកា។ ទើបតែដល់ឆ្នាំ២០០៦នេះទេ ដែលខ្ញុំអាចបង្កើតជាក្រុមមួយបាន ធ្វើការសិក្សាស្រាវជ្រាវចំណុះឲ្យអង្គការការពារក្តីនៅកម្ពុជា។ ហើយក្រោយការសិក្សាស្រាវជ្រាវរួចមក វាជាការសិក្សាស្រាវជ្រាវមួយវាឈឺចាប់មែនទែនសម្រាប់ខ្ញុំ ដោយសារថាខ្ញុំបានស្តាប់អំពីរឿងរ៉ាវកម្សត់ៗទាំងអស់នេះពីអ្នករស់រានមានជីវិតដែលជួបប្រទះ មានបញ្ហាផ្លូវចិត្តរបស់ខ្លួន។ អ៊ីចឹងខ្ញុំផ្អាកមួយរយៈមក ហើយខ្ញុំក៏សរសេរជាឯកសារដោយយកភស្តុតាងទាំងអស់នេះសរសេរទៅជាភាសាជប៉ុន។ អ៊ីចឹងការបោះពុម្ពផ្សាយលើកដំបូង គឺបោះពុម្ពផ្សាយជាភាសាជប៉ុនទេ។ នេះគ្រាន់តែជាការគិតគូត្រួសៗរបស់

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

01364740


ខ្ញុំដំបូង ដើម្បីគិតថា តើខ្ញុំត្រូវសរសេរសៀវភៅដោយរបៀបណា។ ហើយក្រោយមក ខ្ញុំក៏បោះពុម្ពៗផ្សាយចេញនៅខែកក្កដា ឆ្នាំ២០០៧។ នេះជាលើកទី១ ហើយនេះជាសៀវភៅលើកទី១ ដែលសរសេរជាភាសាអង់គ្លេស ដែលខ្ញុំបានប្រមូលរឿងរ៉ាវទាំងអស់នោះ ហើយដែលខ្ញុំចង់ប្រើប្រាស់រឿងទាំងអស់នេះនៅក្នុងសៀវភៅនេះឯង។ ហើយខ្ញុំសុំការអនុញ្ញាតលោកប្រធានបន្ថែមផង។ ខ្ញុំយកឯកសារនៅក្នុងសៀវភៅនេះមកសរសេរក្នុងសៀវភៅមួយទៀត ប្រហែលជាលោក លោកស្រីចៅក្រមមានសៀវភៅនេះហើយ។ នេះជាព័ត៌មានបន្ថែមទៅលើ<ការស្រាវជ្រាវ>របស់ខ្ញុំ <នៅ>ឆ្នាំ២០០៨។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើសិនណា លើកសៀវភៅណាយកមកនិយាយបន្ថែម សុំបញ្ជាក់ចំណងជើងផងលោកស្រី។

[០៩:៥៩:០៥]

**កញ្ញា កាស៊្វមិ ណាកាហ្គាវ៉ា៖**

**ឆ៖** សុំអត់ទោស សុំៗទោស។ ការបោះពុម្ពផ្សាយលើកទី១ ដែលប្រធានសួរនោះគឺឆ្នាំពីរពាន់ -- ខែកក្កដា ឆ្នាំ២០០៧ មានចំណងជើងថា "*យេនឌ័រ បេស វ៉ាយអូឡេនស៍*" ក្នុងសម័យខ្មែរ<ក្រហម> រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យនៅរស់រានពីរបប៧៥ទៅដល់៧៩ នោះ។ ហើយខ្ញុំក៏បានប្រើប្រាស់ព័ត៌មានដូចគ្នាចេញពីសៀវភៅមួយក្បាលនេះយកមកបោះពុម្ពសៀវភៅមួយទៀតនៅក្នុងខែធ្នូ ឆ្នាំ២០០៨ ដែលមានចំណងជើងថា *"យេនឌ័រ បេស វ៉ាយអូឡេនស៍"* គឺក្នុងសម័យខ្មែរក្រហមទៅលើអ្នករស់រានមានជីវិតពីឆ្នាំ៧៥ ដល់៧៩ ជាការបោះពុម្ពលើកទី២។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

**ស៖** អរគុណលោកស្រី។ តើរបាយការណ៍នេះ កញ្ញាបានសិក្សាស្រាវជ្រាវពីបញ្ហាអ្វីខ្លះ? កញ្ញាអាចរៀបរាប់សង្ខេបៗខ្លីៗបានទេ?

[១០:០០:១២]

**ឆ៖** សូមអរគុណលោកប្រធាន។ ដើមគំនិតដំបូងនោះ គឺថាខ្ញុំចង់ប្រមូលរឿងរ៉ាវទាំងអស់ដែលទាក់ទងទៅនឹងអំពើហិង្សាផ្លូវភេទនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំមិនមានគំនិតអ្វីច្បាស់លាស់ថាតើវាប្រភេទណានោះទេ ក៏ប៉ុន្តែតាមរយៈកិច្ចសម្ភាសន៍របស់ខ្ញុំជាមួយប្រជាជនរស់នៅក្នុងភ្នំពេញ <ជាពិសេស>សកម្មជន<និងបញ្ញវន្ត ខ្ញុំដឹង>ថាពួកគេត្រូវបានរំលោភ។ នេះជាគោល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បំណងចម្បងរបស់ខ្ញុំហើយ។ ហើយតាមការសិក្សាស្រាវជ្រាវនេះ ក៏យើងក៏រកឃើញទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទ ដែលខ្ញុំចង់ចងក្រងជាឯកសារផងដែរ។

**ស៖** អរគុណកញ្ញា។ តើកញ្ញាបានប្រើប្រាស់វិធីសាស្ត្រអ្វីខ្លះក្នុងការសិក្សាស្រាវជ្រាវ ដើម្បីរៀបចំរបាយការណ៍នេះឡើង? តើប្រភពណាខ្លះ ដែលកញ្ញាយកមកធ្វើជាមូលដ្ឋានក្នុងរបាយការណ៍នេះ និងបានជួបសម្ភាសជាមួយបុគ្គលណាខ្លះ? មានចំនួនប៉ុន្មាននាក់ដែរ?

[១០:០១:២៣]

**ឆ៖** សូមអរគុណច្រើនលោកប្រធាន។ ការសិក្សាស្រាវជ្រាវមួយនេះ គឺធ្វើឡើងដោយគម្រោងការពារក្ដីនៅកម្ពុជា ដែលពេលនោះ ខ្ញុំគឺជាអ្នកគ្រប់គ្រងគម្រោង។ សម្រាប់គម្រោងនេះដែរ គឺយើងមានផ្នែកផ្ដល់ពិគ្រោះយោបល់មួយ។ អ៊ីចឹងយើងប្រើប្រាស់ធនធានរបស់យើងជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស។ អង្គការក្រៅរដ្ឋាភិបាលនេះ គឺមានអ្នកស្ម័គ្រចិត្តជាច្រើន ជាពិសេសយើងមានអ្នកស្ម័គ្រចិត្តមកតាំងពីក្រសួង -- មន្ទីរកិច្ចនារីតាមខេត្តមែនទែន ដែលជួយទៅដល់ស្ត្រីៗនៅតាមភូមិឃុំដែលនានា ដែលទទួលរងអំពើហិង្សាផ្លូវភេទក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ យើងខ្ញុំស្នើសុំឲ្យមានកិច្ចសហប្រតិបត្តិការជាមួយមន្ទីរកិច្ចការនារី។ អ៊ីចឹងយើងមានអ្នកស្ម័គ្រចិត្ត៥០នាក់ មកពីបណ្ដាខេត្តចំនួនប្រាំ គឺមន្ទីរសង្គមកិច្ច ហើយយើងបានបណ្ដុះបណ្ដាលអ្នកស្ម័គ្រចិត្ត១០នាក់ ក្នុងចំណោម៥០នាក់ហ្នឹងនៅក្នុងភ្នំពេញ គឺថាយើងបណ្ដុះបណ្ដាលការសិក្សាស្រាវជ្រាវល្អិតល្អន់ ទៅដល់អ្នកទាំង១០នាក់នេះ ក្នុងរយៈពេលពីរថ្ងៃ ឲ្យគាត់ទៅតាមភូមិ ដើម្បីធ្វើការសិក្សាស្រាវជ្រាវល្អិតល្អន់តែម្ដង។ អ៊ីចឹងក្រោយការសិក្សាស្រាវជ្រាវពីរថ្ងៃនេះ អ្នកដែលបានសិក្សា -- អ្នកស្ម័គ្រចិត្តទាំង១០នាក់ហ្នឹងត្រឡប់ទៅតាមបណ្ដាខេត្តរបស់ខ្លួនវិញ ហើយ<>បណ្ដុះបណ្ដាល៤០នាក់នេះបន្តទៅទៀត។ អ៊ីចឹងសរុបមកអ្នកស្ម័គ្រចិត្ត៥០នាក់នេះ ទទួលបានការបណ្ដុះបណ្ដាល។

[១០:០២:៥៨]

អ៊ីចឹង គាត់ប្រមូលបានភស្តុតាងពីមនុស្សចំនួន<១.៥០០>នាក់ ដកស្រង់បទពិសោធន៍របស់គាត់ពីសម័យខ្មែរក្រហម។ ហើយអ៊ីចឹងយើងមាន៣០០នាក់ ពីខេត្តនីមួយៗ ទាំងអស់ប្រាំខេត្ត តែមួយ -- (សូមកែតម្រូវ) គឺមាន១៥០០នាក់។ <ដូច្នេះទិន្នន័យទាំងអស់ត្រូវបានប្រមូលដោយការសរសេរដែររបស់អ្នកស្ម័គ្រចិត្ត។> ហើយអ្នកទាំងអស់នោះ ក៏ត្រឡប់មកកាន់ទីស្នាក់ការកណ្ដាលរបស់អង្គការការពារក្ដីកម្ពុជា។ នៅក្នុងចំណោមប្រជាជន១.៥០០នាក់នេះ <យើងពិនិត្យមើល>ថាតើអ្នកណាអាចរៀបរាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្តល់ភស្តុតាងមកដល់អ្នកសិក្សាស្រាវជ្រាវ អំពីអំពើហិង្សាលើផ្លូវភេទដែលខ្លួនជួបប្រទះ? យើងបានជ្រើសរើសយកប្រជាជនតែ១០០នាក់ទេ ក្នុងចំណោម១.៥០០នាក់ដែលយើងត្រូវធ្វើការសម្ភាសជាលើកដំបូងនោះ នៅក្នុងចង្កោមសំណួរនោះ យើងមានសំណួរជាច្រើន សួរថាតើលោកស្រីបានឃើញអំពើហិង្សាផ្លូវភេទក្នុងសម័យនោះទេ? តើលោកស្រីបានជួបប្រទះដោយផ្ទាល់ដែរឬទេ? ហើយសំណួរជាច្រើនទៀតថា <ជាសំណួរចុងក្រោយនោះគឺសួរថា "តើ>មានអ្នកសិក្សាស្រាវជ្រាវបរទេសសម្ភាសលោកស្រីអំពីអំពើហិង្សាផ្លូវក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីមានអ្វីត្រូវប្រាប់ដែរទេ? អ៊ីចឹងយោងតាមព័ត៌មានរបស់គាត់ យើងក៏បានជ្រើសរើសអ្នកទាំងអស់នេះ ឲ្យធ្វើការសម្ភាសជាផ្លូវការមែនទែនតែម្តង។

[១០:០៤:២៩]

អ៊ីចឹងដំបូងយើងជ្រើសរើស១.៥០០នាក់ ចេញពីខេត្តចំនួនប្រាំ ហើយក្នុងនេះយើងជ្រើសរើសយកតែ១០០នាក់ ពី១.៥០០នាក់ ឲ្យនិយាយអំពីរឿងរ៉ាវពិតប្រាកដរបស់ខ្លួន ហើយក្រុមរបស់ខ្ញុំមានរូបខ្ញុំផងដែរនោះ និងអ្នកសិក្សាស្រាវជ្រាវម្នាក់ទៀត ហើយមានអ្នកបកប្រែម្នាក់ផង យើងបានធ្វើការសម្ភាសនៅតាមបណ្តាខេត្តផ្សេងៗដាច់ៗពីគ្នា។ តាមការចងចាំរបស់ខ្ញុំនោះ ខ្ញុំជួបមនុស្សជាង៥០នាក់ ក្នុងឋានៈខ្ញុំជាអ្នកសិក្សាស្រាវជ្រាវផ្ទាល់តែម្តងនៅក្នុងគម្រោងមួយនេះ។

ហើយក្រោយយើងថតជាខ្សែអាត់សំឡេង នូវការសន្ទនាទាំងអស់របស់យើងនោះ គឺថាវាជាកិច្ចសម្ងាត់មែនទែន។ ហើយក្រោយពីយើងយកខ្សែអាត់ទាំងអស់នោះ ប្រមូលយកមក គឺយើងមានអ្នកកត់ត្រាប្រតិចារឹក។ អ៊ីចឹង ខ្សែអាត់ដំបូងហ្នឹង យើងសរសេរជាភាសាខ្មែរ ហើយយើងជួលអ្នកបកប្រែឲ្យបកប្រែនូវប្រតិចារឹកទាំងអស់នេះ។ ហើយលទ្ធផលចុងក្រោយនោះ គឺយើងត្រូវប្រើប្រាស់ភាសាអង់គ្លេសសម្រាប់ការសិក្សាស្រាវជ្រាវមួយនេះ។

[១០:០៥:៥០]

**ស៖** អរគុណកញ្ញា។ ចំណែករបាយការណ៍មួយទៀតរបស់កញ្ញា ដែលមានចំណងជើងថា "ខ្ញុំចង់និយាយប្រាប់អ្នករឿងរ៉ាវស្តីអំពីការរំលោភផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" ឯកសារ E3/3417។ តើកញ្ញាចាប់ផ្តើមសិក្សាស្រាវជ្រាវដើម្បីសរសេររបាយការណ៍នេះនៅពេលណា? ហើយបោះពុម្ពផ្សាយជាលើកដំបូងក្នុងឆ្នាំណាដែរ?

**ឆ៖** សូមអរគុណច្រើនលោកប្រធាន។ របាយការណ៍នេះ មិនមែនខ្ញុំជាអ្នកសរសេរនោះទេ គឺ

សរសេរដោយកញ្ញា ព្រីហ្ស៊ីត ដែលជាសមាជិកក្រុមសិក្សាស្រាវជ្រាវរបស់ខ្ញុំ។ គាត់ជាសហការីរបស់ខ្ញុំ។ យើងធ្វើការសិក្សាស្រាវជ្រាវជាមួយគ្នា ហើយគាត់ជាអ្នកចេញរបាយការណ៍នេះ ដោយយោងទៅលើប្រវត្តិសាវតាររបស់គាត់ជាមេធាវី <ដូច្នេះគាត់បានធ្វើការវិភាគផ្លូវច្បាប់ជាច្រើន> ហើយខ្ញុំអត់បានពិនិត្យមើលឯកសារនេះទេ។

**ស៖** អរគុណកញ្ញា។ តើរបាយការណ៍នេះ ផ្ដោតលើបញ្ហាអ្វីខ្លះ កញ្ញាអាចរៀបរាប់សង្ខេបខ្លីៗបានទេ?

**ឆ៖** ប្រហែលជាខ្ញុំខុសហើយមើលទៅ។ យើងខ្ញុំនឹងក៏បានចែករំលែកនូវគោលបំណងរួមគ្នាដូចថា យើងចង់ចងក្រងជាឯកសារនូវភស្តុតាងទាំងអស់ ពាក់ព័ន្ធទៅនឹងអំពើ<ហិង្សា>ផ្លូវភេទក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ គោលបំណងរបស់គាត់នោះ គឺប្រមូលភស្តុតាងទាំងអស់ ប៉ុន្តែបន្ថែមលើនេះទៅទៀត ដោយសារថាកញ្ញានេះ ជាអ្នកហាត់ការនៅគម្រោងការពារក្ដីនៅកម្ពុជា គាត់មកពីសាកលវិទ្យាល័យហារើត។ ខ្ញុំដឹងថា កញ្ញាហ្នឹង ក៏ចង់យកទឡ្ហីករណ៍ផ្លូវច្បាប់យកមកប្រើប្រាស់ផងដែរពាក់ព័ន្ធទៅនឹងអំពើហិង្សាផ្លូវភេទក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

[១០:០៨:១៤]

**ស៖** តើរបាយការណ៍នេះ យោងទៅលើប្រភពណាខ្លះ? ហើយកញ្ញាជួបសម្ភាសជាមួយបុគ្គលណាខ្លះ? ប្រហែលជាប៉ុន្មាននាក់?

**ឆ៖** លោកប្រធាន តើលោកប្រធានឲ្យខ្ញុំជម្រាបអំពីរបាយការណ៍នេះ ឬក៏យ៉ាងណា? ចាស គឺថាប្រភពនោះគឺ ភស្តុតាងពីអ្នករស់រានមានជីវិតនោះ គឺដូចគ្នាទេ។ យើងប្រើភស្តុតាងតែមួយ គឺពីក្នុងចំណោមខ្សែអាត់សំឡេង<របស់មនុស្ស>ទាំង<១០០នាក់>ហ្នឹង <ព្រមទាំងប្រតិចារឹក និងការបកប្រែផង។ ដូច្នេះយើងបានប្រើភ័ស្តុតាងដូចគ្នា។> ប៉ុន្តែ<ចំពោះបទសម្ភាសន៍>ជាមួយអ្នកជំនាញវិញ ឬក៏ឯកសារយោង ខ្ញុំគិតថា កញ្ញានោះគាត់យោងទៅលើតុលាការអន្តរជាតិជាច្រើន ហើយ<និងឯកសារជាច្រើនផ្សេងទៀត ដែល>យើងចែករំលែកពី<កម្ពុជា>អំពីកម្ពុជាប្រជាធិបតេយ្យនេះជាមួយកញ្ញាផងដែរ។

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា។

សូមអញ្ជើញលោកចៅក្រម លោកស្រីចៅក្រម ហ្វេនស៍។ សូមអញ្ជើញលោកចៅក្រម ឡាវែន៍!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01364744



[១០:០៩:៣៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។ មុននឹងយើងចេញសេចក្ដីសម្រេចទាក់ទងទៅនឹងភាពទទួលយកបាននៃផែនទីដែលស្នើដោយសហព្រះរាជអាជ្ញា ខ្ញុំសូមការបំភ្លឺមួយចំនួន<ពីខាងសហព្រះរាជអាជ្ញា>។ បើសិនជាខ្ញុំយល់មិនច្រឡំទេ លោកសហព្រះរាជអាជ្ញា គឺលោកសុំឱ្យទទួលយកផែនទីចំនួនប្រាំមួយ។ ហើយផែនទីទាំងប្រាំមួយនេះ គឺផែនទី១នោះ គឺទាក់ទងទៅនឹងបណ្ដាញផ្លូវនៅប្រទេសកម្ពុជាដែលមិនមានការបញ្ជាក់អីច្បាស់លាស់ទេ ហើយផែនទីប្រាំ<ផ្សេងទៀត> គឺជាផែនទីដែលមានការចង្អុលបង្ហាញអំពីតំបន់ភូមិសាស្ត្រ ដែលមានគំនូសបង្ហាញពណ៌ទឹកក្រូច ពណ៌ក្រហមអីជាដើម។ អ៊ីចឹងបើសិនជាខ្ញុំយល់មិនច្រឡំទេ គឺមានផែនទីប្រាំ ហើយផែនទីនីមួយៗនៃផែនទីទាំងប្រាំហ្នឹង គឺវាផ្ដោតទៅលើការសិក្សាស្រាវជ្រាវពិសេសមួយ គឺថាជួនគឺការស្រាវជ្រាវដែលធ្វើដោយអ្នកជំនាញដែលមានវត្តមាននៅទីនេះ ហើយដែលជួននោះគឺធ្វើដោយអ្នកស្រាវជ្រាវផ្សេងទៀត។ <អ្វីដែល>ខ្ញុំមិនសូវយល់ច្បាស់<នៅក្នុងសារណារបស់លោកនោះ គឺដូចតទៅ៖> តើការចង្អុលបង្ហាញទាក់ទងទៅនឹងទីតាំងភូមិសាស្ត្រហ្នឹងវាមានន័យយ៉ាងម៉េចដែរ? តើ<ការចង្អុលបង្ហាញ>ទីតាំង<ភូមិសាស្ត្រទាំងអស់នេះពាក់ព័ន្ធទៅនឹងភូមិភាគដែលត្រូវបានដឹកនាំ>ធ្វើការស្រាវជ្រាវនោះ ឬក៏ៗទីតាំងទាំងអស់នេះវាចង្អុលបង្ហាញអំពីកន្លែងដែលមានការរំលោភបំពានលើផ្លូវភេទ ហើយក្រោយមកគឺគេរៀបរាប់ពីរឿងការរំលោភបំពាននុ៎ង។ អ៊ីចឹងខ្ញុំសួរថា តើការសិក្សាស្រាវជ្រាវទាំងអស់ហ្នឹង ដែលៗធ្វើជាមូលដ្ឋាននៃការចារលើផែនទីហ្នឹង <-- តើ>ការសិក្សាស្រាវជ្រាវទាំងអស់ហ្នឹងត្រូវបានទទួលយកដោយអង្គជំនុំជម្រះហើយឬនៅ ហើយវានៅក្នុងសំណុំរឿងហើយឬនៅ? <ដូច្នេះយើងត្រូវដឹងពីគោលបំណងនៃ>ផែនទី<នេះឱ្យបាន>ជាក់លាក់។ <ហើយតើផែនទីទាំងអស់នេះ>ដែលលោកសហព្រះរាជអាជ្ញាចង់ប្រើដើម្បីចោទសំណួរទៅកាន់អ្នកជំនាញរូបនេះ?

[១០:១១:៥៨]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ មូលដ្ឋានសំខាន់នៃសំណើនេះគឺភស្តុតាងដែលបញ្ជាក់ថា គឺមិនមានចំណារទេគឺផែនទីបណ្ដាញផ្លូវ <ដែលត្រូវទទួលដាក់ចូលទៅក្នុងសំណុំរឿង។ មួយនោះអត់មានចំណារទេ។ នោះជាមូលដ្ឋាននៃការស្នើសុំ>។ រីឯផែនទីដែលមានចំណារដែលបង្ហាញពីតំបន់ជាភូមិភាគ ភូមិ

សាស្ត្រដែលមានខេត្តនានា ជាកន្លែងដែលអ្នកធ្វើរបាយការណ៍នោះបានស្វែងរកព័ត៌មានពីតំបន់ទាំងនោះជាមូលដ្ឋាននៃរបាយការណ៍។ ហើយយើងមិនច្បាស់ទេក្នុងករណីខ្លះ ថាតើខេត្តទាំងឡាយដែលគេបានស្វែងរកព័ត៌មានដែលគេបានធ្វើការស្រាវជ្រាវនោះ ពិតជា ដែលថានៅក្នុងរបាយការណ៍ទាំងអស់នោះគេបានទទួលជារបាយការណ៍នៃការរៀបការដោយបង្ខំនៅក្នុងខេត្តនោះទេ។ ហើយរបាយការណ៍ទាំងអស់ស្ថិតនៅក្នុងសំណុំរឿង។ ហើយខ្ញុំមានច្បាប់ចម្លងនៃផែនទីទាំងនេះនៅក្នុងដៃសម្រាប់ជូនលោកស្រីចៅក្រម ហើយនៅក្នុងចំណុចនេះយើងបានឃើញឯកសារហ្នឹងជា E3 ដែលពាក់ព័ន្ធទៅនឹង<ចំណារ> ទាំងនោះ។

គោលបំណងសំខាន់ <គឺ>ដើម្បីឱ្យយើងអាចប្រើផែនទី<ជាមួយសាក្សី>អ្នកជំនាញនេះ <នៅពេលយើង>ពិភាក្សា<អំពី>របាយការណ៍ជាក់លាក់មួយ ហើយនិងទីតាំងនៃការធ្វើការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាផ្លូវភេទ <ហើយជាពិសេសគឺពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ។> យើងនឹងសូមបង្ហាញនៅលើអេក្រង់ ហើយនិងខ្ញុំនឹងបង្ហាញប្រាប់អ្នកជំនាញទៅទំព័រណាមួយជាក់លាក់ដែលគាត់បានធ្វើការសិក្សាស្រាវជ្រាវ ដើម្បីឱ្យសាធារណជនអាចតាមភស្តុតាងបាន។

[១០:១៣:៥៥]

<ប៉ុន្តែ>គោលបំណង<ចម្បងគឺ>ការដាក់ផែនទី ដែលបានបញ្ជាក់នៅក្នុងជាភស្តុតាងហ្នឹង <ហើយទី២ យ៉ាងហោចណាស់>យើង<អាចបង្ហាញ>ចំណារនៅលើផែនទីនៅលើអេក្រង់ដើម្បីឱ្យអ្នកជំនាញបញ្ជាក់បង្ហាញ។ អ៊ីចឹងគឺថា យើង<អាចធ្វើបានក្នុងន័យបង្ហាញពីគោលបំណង ឬក៏ទី២ បើសិនជាលោក លោកស្រីចៅក្រម ចង់>ដាក់<ឯកសារទាំអនោះ>ទៅជាភស្តុតាង <ក្រោយពីស្តាប់សក្ខីកម្មរបស់គាត់នោះ នោះយើងពិតជារីករាយនឹងធ្វើដូច្នោះ។ ប៉ុន្តែមួយផ្នែកធំនោះគឺដើម្បីអាច>ប្រើផែនទីដែលមានចំណារ<>នោះ<នៅលើអេក្រង់ នៅពេលពិភាក្សាពីរបាយការណ៍ជាក់លាក់ជាមួយអ្នកជំនាញ>។ អ៊ីចឹងខ្ញុំមានច្បាប់ចម្លងមួយចំនួនដើម្បីជូន ហើយខ្ញុំអាចនឹងជូនក្រោយពេលសម្រាកនេះក៏បាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកសហព្រះរាជអាជ្ញា នៅក្នុង<អ៊ីម៉ែល>ដែលយើងបានទទួលនោះគឺថាមានផែនទីចំនួនប្រាំមួយ ដែលបានភ្ជាប់ជាមួយនោះ។ អ៊ីចឹងខ្ញុំដូចអត់សូវយល់ទេ ឥឡូវនេះលោកក៏សូមថាឱ្យទទួលតែផែនទីបួនយ៉ាងម៉េច លោកអាចពន្យល់ឱ្យបានច្បាស់លាស់ទេ តើសំណើជាក់លាក់របស់លោកនោះគឺ

សំណើសុំឱ្យទទួលផែនទីទាំងប្រាំមួយ ឬក៏តែបួនទេ?

**លោក វីណ្ឌៀម ស្មីត៖**

លោកចៅក្រម យើងស្នើសុំឱ្យទទួលយកផែនទីមួយ<ឱ្យដាក់ចូលជាភស្តុតាងនៅក្នុងវគ្គនេះ។> គឺជាផែនទីបណ្ដាញផ្លូវថ្នល់ដែលមិនមានចំណារទេ។ អ៊ីចឹងមានតែមួយទេពេលនេះលោកចៅក្រមបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារ លោក ខៀវ សំផន!

[១០:១៥:៤៦]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ បើតាមការបញ្ជាក់ដោយសហព្រះរាជអាជ្ញាហ្នឹង គឺថា បើសិនគោលបំណងនោះគ្រាន់តែទទួលយកភស្តុតាងផែនទីមួយដែលមិនមានចំណារនោះទេ គឺមេធាវី ខៀវ សំផន មិនមានការជំទាស់អ្វីទេ អាចទទួលបានប្រើប្រាស់បាន។ ក៏ប៉ុន្តែទាក់ទងទៅនឹងការមាន ផែនទីដែលមានចំណារហ្នឹងគឺថាយើងប្រកាន់គោលជំហរយើងដដែល គឺអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចមួយក្នុងករណីស្រដៀងគ្នានេះដែរ គឺថ្ងៃទី២១ មករា ឆ្នាំ២០១៥ គឺសវនាការ E1/249.1 គឺម៉ោង ០៩:១២:៥៨វិនាទីកាលនោះ គឺមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ចង់ដាក់ឯកសារចូលទៅជាភស្តុតាង គឺផែនទីមួយដែលគាត់បានចារខ្លួនឯង <យោងតាមសក្ខីកម្មរបស់>ដើមបណ្ដឹងរដ្ឋប្បវេណី<ដែលគេបានសម្ភាស> ហើយកាលនោះអង្គជំនុំជម្រះក៏ជំទាស់ បដិសេធមិនទទួលយកផែនទីហ្នឹងមកធ្វើជាភស្តុតាងទេ។ អ៊ីចឹងខ្ញុំគិតថាគួរតែគោរពតាមយុត្តិសាស្ត្រកន្លងមក។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី គិតចាប់ពីនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១០:១៧នាទី ដល់ម៉ោង ១០:៣៧ នាទី)*

[១០:៣៧:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះបន្តសវនាការ។ ជាបន្តទៀត អង្គជំនុំជម្រះជូនវេទិកាទៅចៅក្រម ហ្វេនស៍ ដើម្បី

សម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា។ សូមអញ្ជើញលោកចៅក្រម!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះដាក់ជូនក្នុងភស្តុតាងនូវផែនទីមួយដែលសហព្រះរាជអាជ្ញាបានបញ្ជាក់ស្នើសុំ ដែលជាផែនទីបណ្តាញផ្លូវថ្នល់កម្ពុជា គមនាគមន៍ <ហើយផែនទីនេះមិនមានចំណារទេ>។ ចំពោះផែនទីផ្សេងៗទៀត គឺអង្គជំនុំជម្រះអនុញ្ញាតឲ្យប្រើផែនទីដែលមានចំណារនៅក្នុងអំឡុងពេលសួរដេញដោលទៅអ្នកជំនាញ។ អ្វីដែលយើងយល់គឺថា គឺជាឧបករណ៍ដើម្បីបង្ហាញទីតាំងដែលបង្ហាញអំពីភាពជាតំណាងដែលប្រើនៅក្នុងការសិក្សាផ្សេងៗ។ ទាំងអស់នេះជាអ្វី នេះគឺថាភាពត្រឹមត្រូវដែលអង្គជំនុំជម្រះត្រូវពិនិត្យមើល។ គឺថាគាត់ជាអ្នកជំនាញ គឺមិនមានឥទ្ធិពលអ្វីទៅលើភាគីណានោះទេ។ អ៊ីចឹងគឺថា បើ<គេបង្ហាញផែនទីនេះទៅ>គាត់ <ហើយគាត់និយាយថា “ទេ វាមិនត្រឹមត្រូវទេ” គឺ>គាត់នឹងអាច<ប្រាប់យើង>ភ្លាមៗពីបញ្ហានេះ។ ចំពោះសំណើផ្សេងទៀត ដើម្បីសុំដាក់ចូលជាភស្តុតាងនោះ យើងនឹងរង់ចាំសំណើដែលនឹងដាក់នៅពេលតាមក្រោយ និងសម្រេចទៅតាមនោះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។

នៅក្នុងការសួរដេញដោលទៅអ្នកជំនាញរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ក្នុងការសួរដេញដោលទៅអ្នកជំនាញមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយតំណាងសហព្រះរាជអាជ្ញារួមជាមួយសហមេធាវីនាំមុខមានរយៈពេលបីវគ្គសវនាការ។ សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១០:៣៩:៣៣]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរភាគី សាធារណជន និងសូមជម្រាបសួរអ្នកជំនាញ។ ខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ។ ហើយនៅព្រឹកនេះខ្ញុំមានប្រធានបទសំខាន់មួយដើម្បីពិភាក្សាជាមួយនឹងអ្នកជំនាញ។ មុននេះលោកប្រធានអង្គជំនុំជម្រះបានពិភាក្សាពីចំណេះដឹង ជំនាញ និងបទពិសោធន៍របស់អ្នកជំនាញរួចហើយ។ ហើយមុននឹងចាប់ផ្តើមសួរសំណួរ ខ្ញុំចង់ជម្រាបទៅអ្នកជំនាញថា ខ្ញុំនឹងចាប់ផ្តើមដោយ

ប្រធានបទដែលនិយាយអំពីការៀបអាពាហ៍ពិពាហ៍នៅមុនរបបខ្មែរក្រហម ដោយសារចង់ឱ្យអង្គជំនុំជម្រះស្វែងយល់អំពីភាពខុសគ្នាបន្តិចរវាងការរៀបអាពាហ៍ពិពាហ៍មុនរបបខ្មែរក្រហម និងនៅក្នុងរបបរបស់ខ្មែរក្រហម។

**ស៖** អ៊ីចឹងសំណួរទី១ ដែលខ្ញុំចាប់ផ្តើមសួរទៅអ្នកជំនាញ គឺថាសូមឱ្យអ្នកជំនាញជួយពន្យល់អំពីការរៀបអាពាហ៍ពិពាហ៍នៅមុនរបបខ្មែរក្រហម។ តើនៅមុនពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងប្រទេសកម្ពុជាមានការអនុវត្ត ឬក៏មានទំនៀមទម្លាប់នៃការរៀបការដែរឬទេ? ហើយប្រសិនបើមាន តើការរៀបការនុ៎ងគឺធ្វើឡើងដោយមានអ្នកណាខ្លះចូលរួម? ជាឧទាហរណ៍មានតែខាងកូនប្រុសកូនស្រី ឬក៏មានទាំងសមាជិកគ្រួសារចូលរួមផងដែរ?

[១០:៤១:២០]

**កញ្ញា កាស៊ូមិ ណាកាហ្គាវ៉ា៖**

**ឆ៖** សូមអរគុណចំពោះសំណួរនេះ។ ជាពិសេសអំពីៗការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមុនរបបកម្ពុជាជាធិបតេយ្យ។ ខ្ញុំមិនមានព័ត៌មានពីសម័យអាណានិគម ហើយនិងសម័យអាណានិគមបារាំង ឬក៏អាណានិគមជប៉ុនទេ ប៉ុន្តែខ្ញុំអាចមានព័ត៌មានពីឆ្នាំ១៩៥០ មកដល់១៩៦០ ដែលខ្ញុំហៅថា ជាការរៀបការតាមប្រពៃណីមុនកម្ពុជាប្រជាធិបតេយ្យ។ តាមប្រពៃណីសង្គមកម្ពុជាត្រូវបានរៀបចំដោយឪពុកម្តាយ ដើម្បីរៀបការកូន ហើយ ឬក៏មានការយល់ព្រមពីឪពុកម្តាយដើម្បីឱ្យកូនរៀបការបាន។ ចំពោះការធ្វើសេចក្តីសម្រេចរបស់នារីវិញ កូនស្រីវិញ គឺមិនមានការសម្រេចទេ ពីព្រោះថា ឪពុកម្តាយរបស់ខាងកូនស្រីជាអ្នកណែនាំកូនស្រីឱ្យរៀបការ ហើយកូនស្រីរង់ចាំឱ្យឪពុកម្តាយធ្វើសេចក្តីសម្រេចជំនួសនាង។ ម្យ៉ាងវិញទៀត កូនប្រុសមានសេរីភាពច្រើនជាង។ កូនប្រុសអាចស្នើទៅឪពុកម្តាយ ឬក៏បងប្អូនដែលសមាជិកគ្រួសារនោះអាចទៅទាក់ទង ចែចូវខាងគ្រួសារខាងស្រីបាន។ ហើយអាពាហ៍ពិពាហ៍ទាំងឡាយត្រូវបានរៀបចំដោយឪពុកម្តាយ ហើយនិងសម្រេចដោយឪពុកម្តាយ។ ចំពោះកូនប្រុសដែលចង់រៀបការមួយខាងស្រីដែលគាត់ស្រឡាញ់ បើសិនជាគេ ខាងស្រីបដិសេធ គេពិបាកនឹងសុំការយល់ស្របពីឪពុកម្តាយដើម្បីរៀបការ។

[១០:៤៣:២០]

កាលណាមានការព្រមព្រៀងហើយរវាងភាគីទាំងសងខាង មានន័យថា ឪពុកម្តាយខាងកូនប្រុសហើយឪពុកម្តាយខាងកូនស្រីហើយ បន្ទាប់មក បើចំពោះគ្រួសារដែលប្រកាន់ប្រពៃណីគេមានពិធីភ្ជាប់

ពាក្យ។ ប៉ុន្តែភ្លាមៗមុនពេលសង្គ្រាម ហើយមុនពេលរដ្ឋប្រហារហ្នឹង ប្រពៃណីហ្នឹង មិនត្រូវបានប្រើទេការភ្ជាប់ពាក្យ ពីព្រោះមានការទម្លាក់គ្រាប់ៗបែកជាដើម។ ហើយការយល់ស្របពីឪពុកម្ដាយរួចហើយ គឺគេកំណត់កាលបរិច្ឆេទនៃការរៀបការ តាមប្រពៃណី គឺជួនកាលគេប្រើអាចារ្យ ឬក៏ហោទាយ ដើម្បីកំណត់កាលបរិច្ឆេទ។ ហើយការរៀបការ រៀបអាពាហ៍ពិពាហ៍នោះជាពិធីដ៏ធំមួយ គឺធម្មតាគេប្រារព្ធឡើងក្នុងបីថ្ងៃ ដែលមានពិធីផ្សេងៗដូចជា គេនិមន្តព្រះសង្ឃឲ្យចូលរួមផ្ដល់សិរីមង្គល ហើយនិងគេហៅសមាជិកក្រុមគ្រួសារក្នុងសហគមន៍ចូលរួមផង គឺថាមិនត្រឹមតែជាបញ្ហារវាងក្រុមគ្រួសារទាំងខាងប្រុសខាងស្រីទេ ប៉ុន្តែគឺនៅក្នុងសហគមន៍គេអញ្ជើញមនុស្សជាច្រើនផងដែរ។ នេះគឺកើតឡើងនៅក្នុងមុនសម័យកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែគឺថា នៅពេលដែលមានចលនាសង្គ្រាម គឺថាគេសង្ខេបប្រពៃណីជួនកាលគេរៀបការតែមួយថ្ងៃ គេមិនប្រើវិធីច្រើន ហើយមិនប្រើឧបករណ៍បំពងសំឡេងច្រើនទេ។ សូមសង្ខេបប៉ុណ្ណេះ សូមអរគុណ។

[១០:៤៥:១១]

**ស៖** ចាស សូមអរគុណ។ ដើម្បីបញ្ជាក់នៅលើចំណុចនេះឲ្យរឹតតែច្បាស់ សូមឲ្យអ្នកជំនាញជួយបញ្ជាក់ថា តើការរៀបអាពាហ៍ពិពាហ៍បែបប្រពៃណីមុនរបបខ្មែរក្រហមនោះ មានការរៀបចំ និងសម្រេចពីឪពុកម្ដាយ ឬក៏ត្រូវតែមានការរៀបចំ និងសម្រេចពីអាជ្ញាធរមានសមត្ថកិច្ច ឬក៏អាជ្ញាធរស្រុកដែរ?

**ឆ៖** សូមអរគុណចំពោះចម្លើយ។ ដើម្បីឆ្លើយឲ្យបានត្រឹមត្រូវ ករណីភាគច្រើន ចំពោះឪពុកម្ដាយខាងកូនក្រមុំគេជាអ្នកសម្រេច ហើយឪពុកម្ដាយខាងប្រុសវិញ គេសម្រេច<ដោយ>យល់ស្រប<ទៅតាមសំណើរបស់កូនកំលោះ>។ <ហើយរបៀប>ដែល<គេទទួលបាន>ការអនុញ្ញាតពីអាជ្ញាធរវិញ គឺថាវាអាចនឹង<ត្រូវបាន>គេ<>ចុះបញ្ជី<នៅអាជ្ញាធរមូលដ្ឋាន ប៉ុន្តែភាគច្រើនអាជ្ញាធរមូលដ្ឋានទាំងអស់នោះ ដូចជាប្រធានភូមិអីជាដើម ត្រូវបានគេអញ្ជើញឲ្យមកចូលរួមក្នុងពិធីមង្គលការនោះដែរ។ ហើយនេះហើយគឺជានីតិវិធីក្នុងការ>ចុះអត្រានុកូលដ្ឋាន<ការរៀបការនោះ>។ តាមធម្មតា គេអញ្ជើញប្រធានភូមិឲ្យចូលរួមក្នុងពិធីនោះដែរ។

**ស៖** តើការអញ្ជើញប្រធានភូមិ ឬក៏មេឃុំឲ្យចូលរួមនោះ គ្រាន់តែជាសាក្សីដើម្បីបំពេញបែបបទរដ្ឋបាលទេ ឬក៏គាត់ចូលរួមក្នុងនាមជាអ្នកសម្រេច ថាតើអ្នកណាត្រូវការជាមួយអ្នកណា?

**ឆ៖** ខ្ញុំសូមអភ័យទោស ខ្ញុំមិនអាចឆ្លើយនឹងសំណួរនេះបានទេ សហព្រះរាជអាជ្ញា។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៤៧:១៧]

**ស៖** សំណួរមួយទៀតដែរ ខ្ញុំចង់និយាយលម្អិតអំពីបែបបទ ឬក៏ទម្លាប់នៃការជ្រើសរើសគូស្រករនៅមុនរបបខ្មែរក្រហម។ លោកស្រីបានបញ្ជាក់មុននេះបន្តិចហើយ ប៉ុន្តែដើម្បីឲ្យវឹតតែច្បាស់ តើនៅមុនរបបខ្មែរក្រហម ការរៀបចំទុកដាក់កូនប្រុសស្រី ឬក៏ការជ្រើសរើសគូស្រករ ជាធម្មតាហ្នឹង មានការពិភាក្សារវាងចាស់ទុំទាំងសងខាង មានន័យថា ទាំងចាស់ទុំខាងប្រុស និងខាងស្រីពិភាក្សាគ្នា ហើយបានមានការចូលរួមពីគូស្រករទាំងខាងប្រុស ទាំងខាងស្រី ដឹងឮអំពីព័ត៌មានដែលពួកគាត់នឹងត្រូវរៀបការ ហើយត្រូវពិចារណាថាតើពួកគាត់ត្រូវរៀបការដែរ។ តើនីតិវិធីនៃការធ្វើហ្នឹងវាយ៉ាងណាដែរ សូមលោកស្រីជួយរៀបរាប់លម្អិត ហើយអ្នកណាខ្លះចូលរួមពិភាក្សា ហើយសម្រេចពីការរៀបការនេះ?

**ឆ៖** សូមអភ័យទោស នេះជាសំណួរអំពីការរៀបការមុនរបបខ្មែរក្រហមមែនទេ? អ៊ីចឹង ខ្ញុំសូមបន្ត។ សំណួររបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងការជ្រើសរើសគូស្រករនៅក្នុងការរៀបការអ្នកណាជាអ្នកសម្រេច ជាអ្នកជ្រើសរើស តើចង់សួរបែបនោះឬយ៉ាងណា។ អ៊ីចឹង ខ្ញុំសូមរៀបចំឃ្លាឡើងវិញ។ កូនស្រីដែលនៅលីវ មិនទាន់រៀបការ អ៊ីចឹងឪពុកម្ដាយជាអ្នកសម្រេច។ ប៉ុន្តែចំពោះនារីមួយចំនួនដែលគាត់បាត់បង់ឪពុកម្ដាយ ដោយសារសង្គ្រាម គឺថាមានម្ដាយមីង ឪពុកមា ឬក៏បងប្អូនប្រុសស្រី <សាច់ញាតិ ឬក៏អ្នកណាក៏ដោយឲ្យតែជាអ្នកថែរក្សានារីនោះ គឺ>ជាអ្នកជួយសម្រេច។ រីឯកូនស្រីនោះមិនមានអំណាចសម្រេចថា ទេ ឬក៏ព្រមនោះទេ។ គឺមានអ្នកផ្សេងជាអ្នកជួយសម្រេច។

[១០:៤៩:២៣]

ចំពោះកូនប្រុសដែលនៅលីវ ដែលមិនទាន់រៀបការនោះ គាត់អាចសុំទៅឪពុកម្ដាយ ឬក៏សាច់ញាតិ ដែលអ្នកមានអំណាច មេបាជាដើមហ្នឹង ដើម្បីរៀបចំការរៀបអាពាហ៍ពិពាហ៍របស់គាត់។ ជាពិសេស គឺចេញពីខាងកូនប្រុសទៅចាស់ទុំរបស់ខ្លួន។ ហើយឪពុកម្ដាយអាចនឹងជួយសម្រេច ជួយណែនាំដើម្បី -- បន្ទាប់មកគាត់ក៏ចាប់ផ្ដើមទៅចែចូវខាងក្រុមគ្រួសារខាងកូនស្រី។ អ៊ីចឹងគឺថា<អំណាចក្នុងការសម្រេចចិត្តគឺពឹងទៅលើឪពុកម្ដាយ។> រីឯការជ្រើសរើសនោះ គឺថា ឪពុកម្ដាយ<អ្នកជ្រើសរើស>គឺថា តើអ្នកណាជាអ្នកដែលសម ស័ក្តិសមនឹងកូនប្រុស កូនស្រីរបស់ខ្លួនហ្នឹងគឺឪពុកម្ដាយទាំងសងខាងក៏គេជាអ្នកជួយសម្រេចដែរ។

**ស៖** តើនៅមុនរបបខ្មែរក្រហម ហេតុអ្វីបានជាមានការចូលរួមពីឪពុកម្ដាយក្នុងការសម្រេចចិត្តដល់ការរៀបការរបស់កូនប្រុសកូនស្រី?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** សូមអរគុណច្រើនសហព្រះរាជអាជ្ញា។ តាមប្រពៃណីនៅក្នុងវប្បធម៌កម្ពុជាក៏ដូចនៅក្នុងកម្ពុជា -- ដូចជាវប្បធម៌របស់ជាតិមួយចំនួនដែរ គឺថាកូនប្រុសកូនស្រីមិន<យល់ដឹងដូចមនុស្សដែល>មានអំណាចទាំងស្រុងទេ។ <ឪពុកម្តាយ>គេចាត់ទុកថា<ជាទ្រព្យសម្បត្តិ តែជាទ្រព្យសម្បត្តិរបស់>ឪពុកម្តាយ។ <ដូច្នេះឪពុកម្តាយគិតថា ពួកគេត្រូវតែ>ធ្វើសេចក្តីសម្រេចលើកូនៗរបស់ខ្លួនទាក់ទងទៅនឹងការអប់រំ ហើយនិងសិទ្ធិទៅលើការរៀបការកូនចៅនោះផងដែរ <ដែលជាបញ្ហាសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជាជាច្រើន>។ អ៊ីចឹងក៏មូលហេតុនេះហើយ គឺឪពុកម្តាយជាអ្នកចូលរួមក្នុងការធ្វើសេចក្តីសម្រេចក្នុងការរៀបការកូន។ មិនចំពោះតែការរៀបការទេ គឺថាជីវិតអនាគតរបស់កូនៗ ពេលខ្លះឪពុកម្តាយជាអ្នកសម្រេចដែរ។

[១០:៥១:៥០]

**សៈ** តើនៅមុនរបបខ្មែរក្រហម បុរស ឬស្ត្រីអាចបដិសេធមិនព្រមរៀបការនៅពេលដែលមានការស្នើឡើងដោយចាស់ទុំដែរឬទេ?

**ឆ៖** តាមអ្វីដែលខ្ញុំយល់ តាមរយៈការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ស្ទើរតែនារីទាំងអស់ ពួកគាត់សង្ឃឹម ហើយនិងរំពឹងឲ្យឪពុកម្តាយជាអ្នកធ្វើសេចក្តីសម្រេចឲ្យខ្លួន។ ពួកគាត់អត់មានជម្រើសក្នុងការឆ្លើយបដិសេធទេ ពីព្រោះគេពឹងផ្អែកលើឪពុកម្តាយជាអ្នកជ្រើសរើសឲ្យគេ។ ចំពោះកូនប្រុសវិញ តាមបច្ចេកទេស ខ្ញុំអាចនិយាយថាគេអាចបដិសេធបាន។ ប៉ុន្តែខ្ញុំមិនមានឧទាហរណ៍ពិសេសដែលថា កូនប្រុសអាចបដិសេធពេលដែលឪពុកម្តាយផ្គូផ្គងរើសឲ្យហើយហ្នឹង អាចបដិសេធបាន<>។

**សៈ** តើលោកស្រីអាចលើកជាឧទាហរណ៍មួយចំនួនពាក់ព័ន្ធទៅនឹងសមូលហេតុដែលបុរស ឬក៏ប្រសិនបើអាចស្ត្រីបដិសេធមិនព្រមរៀបការដែរឬទេ ដោយសារកត្តាអ្វីខ្លះ?

**ឆ៖** ស្ត្រីម្នាក់ដែលខ្ញុំបានជួបនៅក្នុងការសិក្សាស្រាវជ្រាវ គាត់បានបដិសេធមិនរៀបការនៅ<មុន>របបខ្មែរក្រហមហើយ<ក្រោយមក>គាត់<ត្រូវ>បាន<បង្ខំឲ្យរៀបការនៅក្នុងរបបខ្មែរក្រហមដែលនេះជាករណីអភ័ព្វ។> គាត់អាចបដិសេធបានមុនសម័យខ្មែរក្រហម <ព្រោះ>គាត់ចង់រៀនខាងដុកទ័រខាងវេជ្ជសាស្ត្រឲ្យបានចប់ <ហើយគាត់កំពុងរៀននៅសាលាពេទ្យ>។ ឪពុកម្តាយជាអ្នកសម្រេចជំនួសគាត់ <ដោយ>បានណែនាំបុរសដ៏ល្អ<ម្នាក់ទៅគាត់> ហើយគាត់បានបដិសេធ។ <>គាត់<អាចគេចបាន ព្រោះ>ប្អូនស្រីគាត់<ត្រូវបានឪពុកម្តាយបង្ខំឲ្យរៀបការ>ជាមួយបុរសនោះទៅវិញ។ <នេះជាឧទាហរណ៍មួយដែលខ្ញុំនៅចាំ។>

[១០:៥៤:១៩]

**ស៖** តើនៅមុនរបបខ្មែរក្រហមហ្នឹងមានការដាក់ទណ្ឌកម្មដែរឬទេនៅលើបុរស ឬស្ត្រីដែលមិនព្រមរៀបការ ឬក៏បដិសេធមិនព្រមរៀបការ? ឧទាហរណ៍ ករណីដែលលោកស្រីបានរៀបរាប់មុននេះ ស្ត្រីដែលបដិសេធមិនព្រមរៀបការ?

**ឆ៖** នេះជាសំណួរគួរឲ្យចាប់អារម្មណ៍។ ខ្ញុំមិនដែលបានគិតដល់ទេ ប៉ុន្តែខ្ញុំមិននឹកឃើញករណីណាមួយដែលកូនប្រុស ឬក៏កូនស្រី ត្រូវបានដាក់ទោស ឬក៏ដាក់វិន័យស្តីបន្ទោសអ្វីចំពោះការបដិសេធមិនព្រមរៀបការតាមគំនិតរបស់ឪពុកម្តាយទេ គឺខ្ញុំមិនធ្លាប់ប្រទះករណីបែបនេះ។

**ស៖** ពាក់ព័ន្ធទៅនឹងអាពាហ៍ពិពាហ៍ដែលរៀបចំឡើងតាមបែបប្រពៃណីនៅកម្ពុជា មុនរបបខ្មែរក្រហមដែលជាការរៀបចំតាមបែបប្រពៃណី ហើយមានការដឹងឮពីសាមីខ្លួន អ្នកដែលត្រូវរៀបការ។ ខ្ញុំសុំលើកយោងដល់ការសិក្សាស្រាវជ្រាវ ចុះខែតុលា ឆ្នាំ២០១៤ ដែលមាននៅក្នុងសៀវភៅដែលនិពន្ធដោយ ដឺឡាំងហ្គីស ស្រ្តេសស៊័រ ហ៊ីមិនតាំង ដែលមានចំណងជើងថា "កែប្រែខ្លួនប្រាណដូចខ្មោច"។ ផ្នែកដែលនិយាយពីការសិក្សា ពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបខ្មែរក្រហម គឺឯកសារ E3/9614 នៅត្រង់ ERN ជាភាសាខ្មែរ 01037040, ERN ជាភាសា -- សុំទោស មុននេះជាភាសាអង់គ្លេស។ ERN ជាភាសាខ្មែរ គឺ01212343។ មិនមានការបកប្រែជាភាសាបារាំងទេ។ នៅក្នុងនោះ អ្នកនិពន្ធបានលើកយោងស្នាដៃរបស់ អេហ៊ុី ហារ៉ា ដែលគាត់បានរៀបចំការសិក្សាលម្អិតបែបនរវិទ្យា អំពីជីវិតអ្នកភូមិនៅរបបខ្មែរក្រហម។

[១០:៥៦:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោស ដែលខ្ញុំកាត់ផ្តាច់ លោកប្រធាន។ ខ្ញុំដឹងថា គាត់អត់មាន ERN ជាភាសាបារាំងទេ ក៏ប៉ុន្តែយើងក៏ស្តាប់អត់បាន ERN ជាភាសាអង់គ្លេសដែរ អ៊ីចឹងសូមឲ្យនិយាយ ERN ជាភាសាអង់គ្លេសម្តងទៀត។

**ប្រធានអង្គជំនុំ៖**

សូមលោកព្រះរាជអាជ្ញា បញ្ជាក់ ERN ជាភាសាអង់គ្លេសឲ្យបានច្បាស់។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**កញ្ញា សុង ឆវ័ន្តៈ**

ចាស អរគុណ។ ឯកសារ គឺ E3/9614, ERN ជាភាសាអង់គ្លេស គឺ01037040 ហើយសុំការអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បង្ហាញឯកសារនេះនៅលើអេក្រង់ ដើម្បីឱ្យអ្នកជំនាញអាចតាមដានបានផងដែរ។

**សួរដោយកញ្ញា សុង ឆវ័ន្តៈ**

**សៈ** នៅក្នុងការសិក្សារបស់ ដឺឡាំងហ្គិសនេះ មានផ្នែកមួយដែលនិយាយអំពីការសិក្សាពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបខ្មែរក្រហម។ ហើយគាត់បានយោងដល់ស្នាដៃរបស់ អេប៊ីហាវ៉ា ដែលបានរៀបចំជាការសិក្សាលម្អិតបែបនរវិទ្យា អំពីជីវិតអ្នកភូមិនៅមុនពេលរបបខ្មែរក្រហម។ ដែលការសិក្សាទាំងនោះ រួមមានពិធីរៀបការ ការរៀបការ មានន័យថា ការរៀបការនៅក្នុងថ្ងៃរៀបការតែម្តង មានសកម្មភាពអ្វីខ្លះ? នៅក្នុងភូមិមួយដែលមានឈ្មោះថា ភូមិស្វាយ ជាភូមិនៅក្នុងប្រទេសកម្ពុជា ការសិក្សាបានរៀបរាប់អំពីកម្មវិធីបែបបទនៃការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីដែលធ្វើឡើងចាប់ពីឆ្នាំ១៩៥៩ ដល់ ឆ្នាំ១៩៦០។ អេប៊ីហាវ៉ា បានរៀបរាប់អំពីការសុំរៀបការតាមបែបលក្ខណៈប្រពៃណីជាធម្មតាមួយ ហើយខ្ញុំសុំដកស្រង់៖ “តាមទំនៀមទម្លាប់ដ៏ល្អបំផុត បុរសវ័យក្មេងសម្រេចចិត្តដោយខ្លួនគាត់ ថាតើត្រូវរៀបការជាមួយអ្នកណា ហើយពេលគាត់សម្រេចរួចហើយ គាត់ក៏សុំឪពុកម្តាយរបស់គាត់ឱ្យចាប់ផ្តើមសួរនាំទៅក្រុមគ្រួសារខាងកូនស្រី។ នៅពេលដែលក្រុមគ្រួសារខាងកូនស្ត្រីយកការសុំរៀបការនោះ ស្ត្រីវ័យក្មេង ខ្លួននាងត្រូវបានពិគ្រោះយោបល់ និងជាថ្មីម្តងទៀត។ បើតាមប្រពៃណី នាងមានសេរីភាពដើម្បីទទួលយក ឬច្រានចោលនូវសំណើនេះ។” បញ្ចប់ការដកស្រង់។

[១០:៥៩:១៦]

ដើម្បីបន្ថែមបន្ថែមពីលើនេះទៀត មានការសិក្សារបស់ ដឺឡាំងហ្គិស និងស្នាដៃរបស់អ្នកដទៃទៀត គឺឯកសារដដែលនៅ ERN ជាភាសាអង់គ្លេសដដែល ប៉ុន្តែជាភាសាខ្មែរចុះមកខាងក្រោមមកពីរទំព័រ។ ក្រោយពីបានពិនិត្យលើលទ្ធភាពនៃការស្រាវជ្រាវ ស្តីអំពីការរៀបចំតាមប្រពៃណីនៅកម្ពុជាដែលពាក់ព័ន្ធនឹងការរៀបការ ដោយមានការយល់ព្រមពីបុរសនិងស្ត្រី ដែលត្រូវរៀបការនោះ គាត់បានធ្វើសេចក្តីសន្និដ្ឋានថា ខ្ញុំដកស្រង់៖ “ជាសង្ខេប មង្គលការតាមបែបលក្ខណៈប្រពៃណីមុនរបបខ្មែរក្រហមមានលក្ខណៈសំខាន់ពិសេសសម្រាប់គូស្វាមីភរិយា។ ក្រុមគ្រួសារនិងសហគមន៍ទាំងមូល រួមទាំងវិញ្ញាណក្ខន្ធដូនតាផងដែរ។ អាពាហ៍ពិពាហ៍ទាំងនោះ ភាគច្រើនត្រូវបានរៀបចំជាញឹកញាប់បំផុត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដោយមានការយល់ព្រមពីអ្នកដែលគេចង់រៀបការ តាមទំនៀមទំលាប់កម្រត្រូវបានបង្ខិតបង្ខំ បើយោងតាមការស្រាវជ្រាវដែលមានកន្លងមក។" ខ្ញុំបញ្ចប់ការដកស្រង់។

យោងតាមការសិក្សាស្រាវជ្រាវដែលខ្ញុំបានរៀបរាប់ជម្រាបជូនលោកស្រីមុននេះ តើមតិយោបល់ដែលបានលើកឡើងខាងលើនេះ មានភាពស្របគ្នាទៅនឹងលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់លោកស្រីពាក់ព័ន្ធទៅនឹងការរៀបការតាមបែបប្រពៃណីនៅមុនរបបខ្មែរក្រហមដែរឬទេ?

**ឆៈ** សូមអរគុណច្រើន។ ចាស ខ្ញុំយល់ស្របថាវាដូចជាគំនិតដែលខ្ញុំយល់ឃើញ ប៉ុន្តែនៅក្នុងការសិក្សារបស់ខ្ញុំ ទោះបីជានារីនៅលើវត្រូវបានពិគ្រោះយោបល់ជាមួយឪពុកម្ដាយអំពីការរៀបការរបស់នាងក៏ដោយ គឺនាងត្រូវយល់ស្របដោយមិនបានពិចារណាអ្វីទេ។ អ៊ីចឹងគឺថា ខ្ញុំមិនគិតថាជាការយល់ព្រមដោយពិតប្រាកដនោះទេ ពីព្រោះគាត់មិនបានជ្រើសរើសបុរសនោះដោយផ្ទាល់ខ្លួនទេ។

[១១:០១:៥០]

**សៈ** ដើម្បីបញ្ជាក់លើចំណុចនេះ តើស្ត្រីដែលត្រូវរៀបការត្រូវបានគេពិគ្រោះយោបល់ហើយនិងបានទទួលព័ត៌មានពីបុរសដែលគាត់ត្រូវរៀបការ មុនការដែលគាត់សម្រេចបដិសេធ ឬក៏ទទួលយកសំណើដែរឬទេ?

**ឆៈ** គឺអាស្រ័យទៅលើឪពុកម្ដាយចំពោះព័ត៌មានដែលត្រូវផ្ដល់ទៅឲ្យកូននោះ កូនស្រីនោះ។ ស្ត្រីជាច្រើនដែលខ្ញុំបានសម្ភាសនោះគឺថា ថ្ងៃខែដែលត្រូវដែលរៀបការហ្នឹងឯង គឺជាថ្ងៃទី១ ដែលពួកគាត់បានជួបប្ដីរបស់គាត់ <ដូច្នេះ>គាត់<ដឹងតិចតួចបំផុតអំពីប្ដីរបស់គាត់មុនថ្ងៃរៀបការ>។ ប៉ុន្តែជាថ្មីម្ដងទៀត ចំពោះនារីគឺគេមិនយល់ថាជាការរៀបការជា ដែលមិនល្អទេ ពីព្រោះគឺពឹងផ្អែកលើឪពុកម្ដាយជាអ្នកសម្រេចឲ្យពួកគាត់។

**សៈ** តើការសម្រេចរៀបការនោះជាការសម្រេចបែបលក្ខណៈគ្រួសារ ឬក៏ជាការសម្រេចដែលមានការចូលរួមពីអាជ្ញាធរ?

**ឆៈ** បើខ្ញុំយល់សំណួរបានត្រឹមត្រូវគឺថា គឺជាបញ្ហាគ្រួសារ១០០ភាគរយ។ មានការជូនដំណឹងទៅអាជ្ញាធរ បន្ទាប់ពីអ្វីៗបានសម្រេចរួចហើយនៅក្នុងចំណោមក្រុមគ្រួសារនោះ។

[១១:០៣:៤៤]

**សៈ** ចាសសូមអរគុណ។ មុននោះលោកស្រីក៏បានពិពណ៌នាដោយសង្ខេបអំពីការរៀបការតាមបែបប្រពៃណីថាមានកម្មវិធីអ្វីខ្លះ ហើយមានការចូលរួមពីអ្នកណាខ្លះដែរ? ប៉ុន្តែខ្ញុំចង់ឲ្យលោកស្រីជួយ

បញ្ជាក់អំពីពេលវេលា តើបន្ទាប់ពីមានសំណើសុំឧទាហរណ៍ពីខាងកូនប្រុសទៅខាងស្រីហ្នឹង តើរយៈពេលនីមួយៗ គម្លាតពីរយៈពេលនៃកម្មវិធីនីមួយៗហ្នឹងគឺយ៉ាងណាដែរ? ជាឧទាហរណ៍បើសិនបើមានការស្នើសុំពីខាងកូនប្រុសទៅចាស់ទុំខាងកូនប្រុស ដើម្បីឱ្យចូលទៅសួរនាំ ឬក៏ហៅថាចែចូវទៅខាងកូនស្រីហ្នឹង រយៈពេលយ៉ាងណា ហើយគម្លាតពីរយៈពេលមួយទៅកម្មវិធីមួយទៀតហ្នឹងយ៉ាងណាដែរ?

**ឆ៖** ខ្ញុំមិនអាចនិយាយជាទូទៅថាតើត្រូវពេល ត្រូវការរយៈពេលប៉ុន្មាន បន្ទាប់ពីការចាប់ផ្ដើមគំនិតដំបូង ឬក៏ចែចូវដំបូងដល់ថ្ងៃរៀបការនោះទេ។ ប៉ុន្តែ<ខ្ញុំមិនចាំថាមាន>អាពាហ៍ពិពាហ៍<ណាមួយដែល>រៀបចំក្នុងរយៈពេលខ្លី<នោះទេ មានន័យថា ត្រូវចំណាយ>រយៈពេល<រាប់ខែ> ឬក៏ពេលខ្លះការរៀបចំត្រូវរង់ចាំដល់<កន្លះ>ឆ្នាំ។ <លើកលែងតែការរៀបការនៅ>ក្នុងឆ្នាំ១៩៧៣ <ឬ>១៩៧៤ នៅពេលដែលក្រុមគ្រួសារខាងកូនស្រីព្រួយបារម្ភអំពីសន្តិសុខ<របស់កូនស្រី>នោះខ្ញុំមានព័ត៌មាន<ខ្លះ>ថា ពួកគេបានប្រញាប់ដើម្បីរៀបការឱ្យបានឆាប់ៗ។ <ដូច្នេះពួកគេមិនទាន់ត្រៀមខ្លួនរួចរាល់ដើម្បីរៀបការទេ ប៉ុន្តែឪពុកម្ដាយចង់រៀបចំរៀបការឱ្យកូនស្រីខ្លួន> ពីព្រោះដោយសារមានការទម្លាក់គ្រាប់បែកធ្វើឱ្យមានការភ័យខ្លាចក្នុងការរស់នៅរាល់ថ្ងៃ។ អ៊ីចឹងឪពុកម្ដាយហ្នឹងគិតថា សំខាន់ណាស់ត្រូវតែ<ឱ្យកូនស្រីខ្លួន>មានការការពារ<>ឱ្យបានឆាប់ៗនៅក្នុងអំឡុងពេលនេះ។ ក៏ប៉ុន្តែមិនកើតទូទាំងប្រទេសទេ នៅក្នុងតំបន់មួយចំនួនទេ គឺដំណើរការរៀបចំការរៀបការនេះចាប់ផ្ដើមឡើងដែលថាខាងប្រុសចាប់ផ្ដើម ហើយខាងស្រីយល់ព្រម គឺថាអាចប្រហែលជា<ចំណាយពេលរាប់ខែ> បន្ទាប់<មានការចរចាគ្នាជាច្រើនរវាងគ្រួសារទាំងពីរ>។

[១១:០៦:២៦]

**ស៖** ចុះនៅក្នុងករណីដែលមាន កុំជាប់ពាក្យ ឬក៏ការភ្ជាប់ពាក្យមុនពេលរៀបការ តើជាធម្មតារយៈពេលនៃការរង់ចាំហ្នឹងប៉ុន្មានដែរ? ខ្លីបំផុតប៉ុនណា? ហើយអាចយូរបំផុតដល់រយៈពេលណាដែរ?

**ឆ៖** សូមអភ័យទោសសហព្រះរាជអាជ្ញា ខ្ញុំអត់មានចម្លើយទៅនឹងសំណួរនេះទេ។

**ស៖** ចាស អរគុណ។ សំណួរមួយទៀត តើយោងតាមការសិក្សាស្រាវជ្រាវរបស់លោកស្រីនៅមុនរបបខ្មែរក្រហមមានហេតុផលចម្បងអ្វីខ្លះ ដែលទាំងខាងកូនប្រុស ទាំងខាងកូនស្រី និងខាងក្រុមគ្រួសាររបស់ពួកគាត់ទាំងពីរហ្នឹងគិតថាគួររៀបការហើយការរៀបការហ្នឹងគួរត្រូវធ្វើតាមបែបប្រពៃណី?

**ឆ៖** ការរៀបការនៅក្នុងសម័យខ្មែរក្រហម គឺខុសគ្នាឆ្ងាយពីការរៀបការតាមប្រពៃណី។

**ស៖** តើមានហេតុផលចម្បងផ្សេងដែលប្រជាពលរដ្ឋកម្ពុជានៅមុនរបបខ្មែរក្រហមគិតថា ការ

រៀបការតាមបែបប្រពៃណីហ្នឹងមានសារៈសំខាន់ចម្បងអ្វីខ្លះដែរឬទេ?

**ឆ៖** ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដែលរៀបបញ្ចូលទាំងការចូលរួមរបស់ឪពុកម្តាយ ហើយនិងសមាជិកក្រុមគ្រួសារដែលជាអ្នកប្រារព្ធពិធីអាពាហ៍ពិពាហ៍។ ហើយការងារទាំងអស់នេះមិនកើតមានឡើងទេនៅក្នុងសម័យខ្មែរក្រហម។

**ស៖** ចុះអំពីបុរសនិងស្ត្រីដែលពួកគាត់ត្រូវរៀបការជាមួយនឹងគ្នាហ្នឹង តើមានការគិតគូរអំពីឋានៈ? តើមានករណីដែលមានអ្នកក្រ មានជីវភាពក្រីក្រអាចរៀបការជាមួយនឹងអ្នកដែលមានជីវភាពធូរធារ គ្រួសារដែលធូរធារ ឬក៏អ្នកដែលមានកម្រិតសិក្សាខ្ពស់ អាចរៀបការជាមួយនឹងអ្នកដែលមានកម្រិតសិក្សាមធ្យម ឬក៏ទាបបានដែរឬទេ នៅក្នុងការរៀបអាពាហ៍ពិពាហ៍មុនរបបខ្មែរក្រហម?

[១១:០៩:២២]

**ឆ៖** ចំពោះការរៀបអាពាហ៍ពិពាហ៍មុនរបបខ្មែរក្រហម វាភាគច្រើនជាបញ្ហាក្នុងគ្រួសារ <ដូច្នេះគ្រួសារទាំង>ពីរ <ទាំង>គ្រួសារខាងប្រុស និងខាងស្រី ដែល<ពាក់ព័ន្ធនឹងការរៀបការនោះ> គេត្រូវតែយល់ព្រមលើការរៀបអាពាហ៍ពិពាហ៍។ ផ្អែកតាមទស្សនៈនេះ គឺថាយើងមានការលំបាកក្នុងផ្គូផ្គងកូនស្រីជាមួយនឹងបុរសម្នាក់ដែលមានឋានៈគ្រួសារខុសគ្នាឆ្ងាយពេក ដូចថាបុរសនៅក្នុង<ភពមួយផ្សេងទៀតអ៊ីចឹង។ ដូច្នេះភាគច្រើន ឧទាហរណ៍>កូនស្រីកសិករត្រូវ គួរតែរៀបការជាមួយនិងកូនប្រុសកសិករ។ កូនស្រីអ្នកជំនួញគប្បីតែរៀបការជាមួយអ្នកជំនួញ។ រីឯកូនស្រីរបស់គ្រួសារអ្នកមានការអប់រំ គប្បីតែរៀបការជាមួយនឹងអ្នកមានការអប់រំ។ អ៊ីចឹងហើយ ចំពោះកូនស្រីដែល<>មានការអប់រំខ្ពស់ <នៅពេលនោះកម្រមានកូនស្រីទទួលបានការអប់រំខ្ពស់ណាស់ ព្រោះកូនស្រីមិនអាចទៅរៀនបានទេ។ ដូច្នេះ>កូនស្រី<ដែលមានការអប់រំ>នោះ<>រំពឹងថាឪពុកម្តាយនឹងផ្សំផ្គុំខ្លួនជាមួយនឹងបុរសម្នាក់ដែលមានការអប់រំប្រហាក់ប្រហែល ឬក៏ខ្ពស់ជាងនាង។

**ស៖** ចាស អរគុណ។ និយាយអំពីបរិយាកាសនៅថ្ងៃរៀបការ នៅមុនរបបខ្មែរក្រហមនុ៎ង តើនៅថ្ងៃរៀបការហ្នឹង កម្មវិធីហ្នឹងគេចាប់ផ្តើមដោយរបៀបណា ហើយមានការចូលរួមយ៉ាងណាដែរ ហើយការចូលរួមរបស់ចាស់ទុំញាតិមិត្តដែលមកដល់ផ្ទះរបស់កូនស្រីហ្នឹង មានសារៈសំខាន់យ៉ាងណាដែរចំពោះកម្មវិធីរៀបការបែបប្រពៃណីនោះ?

[១១:១១:២០]

**ឆ៖** សូមអភ័យទោស តើមុនសម័យខ្មែរក្រហមឬ? ចំពោះសម័យមុនខ្មែរក្រហមនៅក្នុងការ

រៀបអាពាហ៍ពិពាហ៍ គឺជាពេលវេលា ៗមួយដែលសហគមន៍ ប្រជាជននៅក្នុងភូមិឃុំហ្នឹង គេស្វាគមន៍ចូលរួម គឺមិនមែនតែគូស្រករទេ គឺថាមានឪពុកម្ដាយ ហើយបងប្អូននៅឆ្ងាយជិត ហើយអាចនិងអ្នកជិតខាង ដូចជាអាជ្ញាធរមូលដ្ឋានផងដែរ។ គេរំពឹងថានឹងអញ្ជើញអ្នកទាំងហ្នឹង ចូលរួមក្នុងពិធីមង្គលការ។

**ស៖** ចាស សូមអរគុណ។ នៅលើប្រធានបទដដែល គឺមុនរបបខ្មែរក្រហម ក្រោយពីថ្ងៃរៀបការរួច តើស្វាមីភរិយាថ្មីដែលទើបនឹងរៀបការហ្នឹងរស់នៅជាមួយគ្នាដែរឬទេ? ហើយក្នុងករណីដែលពួកគាត់រៀបការហើយ ពួកគាត់មិនចុះសម្រុងនឹងគ្នា តើពួកគាត់មានសិទ្ធិក្នុងការលែងលះគ្នា ឬក៏រស់នៅបែកគ្នាដែរឬទេ?

**ឆ៖** តាមបច្ចេកទេស គឺគេអាចធ្វើបែបនោះបាន ដែលថាគូស្រករដែលរៀបការហើយអាចនឹងលែងលះគ្នាបាន ប៉ុន្តែជាករណីកម្រ ពីព្រោះនៅពេលនោះ ពីព្រោះគឺថាសម័យនោះ គេត្រូវរក្សាគោលការណ៍ប្ដីមួយប្រពន្ធមួយ។ អ៊ីចឹង គឺថាចំពោះបុរសក្នុងករណីខ្លះគេអាចមានប្រពន្ធ<ច្រើន។ មិនមានហេតុផលដែលបុរសចង់លែងប្រពន្ធទេ គាត់អាចរក្សាទុកប្រពន្ធច្រើនបាន។> ប៉ុន្តែចំពោះស្ត្រីវិញ គឺមានការ<ខ្មាសអៀនបើសិនជា>មានការលែងលះ។ អ៊ីចឹងគឺថា<>ភាគីទាំងសងខាងហ្នឹង<កម្រមានហេតុផល>លែងលះ<ណាស់>។ ក៏ប៉ុន្តែមានករណីខ្លះគេលែងលះដែរ ក្នុងករណីកម្រ ប៉ុន្តែជាសេចក្ដីសម្រេចដ៏ខ្លាំងចំពោះនារីក្នុងការសម្រេចចំពោះភាគីខាងស្រីហ្នឹង ប៉ុន្តែវាអាចទៅរួច។

[១១:១៣:៥៤]

**ស៖** ចាស សូមអរគុណ។ ក្រោយពីថ្ងៃរៀបការ តើស្វាមីភរិយាត្រូវស្ថិតក្រោមបញ្ជា ឬក៏ពួកគេត្រូវបានណែនាំ ឬក៏ប្រាប់ថា ពួកគេត្រូវតែរស់នៅ ហើយនិងរួមមេត្រីជាមួយគ្នា ឬក៏ពួកគេមានសិទ្ធិសម្រេចអំពីការងារទាំងអស់នេះ?

**ឆ៖** តាមអ្វីដែលខ្ញុំយល់ គឺថាគេដំណាម គេកម្រនឹងនិយាយរឿងនេះណាស់។ ឪពុកម្ដាយកម្រប្រាប់ឪពុកម្ដាយ -- ឪពុកម្ដាយកម្រប្រាប់កូនប្រុសកូនស្រីថា ត្រូវធ្វើម៉េចនៅយប់បន្ទាប់ពីរៀបការនោះ<ណាស់>។ ខ្ញុំចងចាំថា មាននារីមួយចំនួនគេណែនាំថាឲ្យ<ធ្វើ>តាមប្ដីរបស់ខ្លួន<នៅយប់រៀបការនោះ> ហើយតាមប្រពៃណីរបស់កម្ពុជានោះ គឺថាគេដំណាមមិននិយាយអំពីការរួមរ័ករវាងមនុស្ស -- ទោះបីជាម្ដាយនិងកូន<ស្រី>ក៏ដោយ នៅក្នុងគ្រួសារក៏ដោយ។ <ខ្ញុំបានជួបស្ត្រីជាច្រើនដែលមិនមានការចេះដឹងផ្នែកសុខភាព ដូចជាការមានរដូវជាដើម ដូច្នេះ>នៅក្នុងក្រុមសង្គម ដែលថាម្ដាយ ឬក៏<បងប្អូន>ស្រី <មិនអាច>បង្រៀនអំពី<បញ្ហាមានរដូវនោះ> ខ្ញុំមិនគិតថា ឪពុកម្ដាយប្រាប់កូនស្រីថាត្រូវ

<រួមភេទយ៉ាង>ដូចម្ដេច<នៅក្រោយអាពាហ៍ពិពាហ៍>នោះទេ។ ចំពោះខាង គ្រួសារខាងប្រុស ខាងកូនប្រុសវិញ ក៏ខ្ញុំមិនគិតថា មានការណែនាំពីឪពុកម្ដាយឲ្យធ្វើដូចម្ដេចនោះដែរ។ ប៉ុន្តែការយល់ដឹងចំពោះក្រុមគ្រួសារមុនរបបខ្មែរក្រហមនោះក្ដី ហើយរបបក្រោយរបបខ្មែរក្រហមនោះក៏ដោយ គឺថារឿងទូទៅដែលគេសួរនោះ គេគ្រាន់តែសួរថា តើអ្នកឯងមានកូនប៉ុន្មានហើយ? មានកូនហើយឬនៅ? អ៊ីចឹង ដូច្នេះ វាជាការគួរសមជាង គឺថាគេសួរពាក្យ ថាតើកូនមានកូនហើយឬនៅ? ឬក៏តើចង់បានកូនហើយឬនៅ? ហ្នឹងហើយ គឺថាគេតែងតែប្រើសំណួរបែបនេះវិញទេ ទាក់ទងនឹងការបន្តពូជនោះ។

[១១:១៦:៣២]

**ស៖** តាមការសិក្សាស្រាវជ្រាវរបស់លោកស្រី តើធ្លាប់មានករណីដែលចាស់ទុំ ឬក៏ឪពុកម្ដាយខាងប្រុស ឬខាងស្រី ខាងណាមួយក៏បាន ធ្លាប់ណែនាំឲ្យពួកគេត្រូវតែមានកូន ដើម្បីបន្តវង្សត្រកូលអ៊ីចឹងហើយមានការបញ្ជាថា ដាច់ខាតត្រូវតែធ្វើដូច្នេះដែរឬទេ? ហើយនៅក្នុងករណីដែលមានករណីដូច្នេះកើតឡើង តើធ្លាប់មានស្ត្រី ឬបុរសនោះអាចបដិសេធថា មិនអាចធ្វើបាន ឬក៏គាត់មានសិទ្ធិក្នុងការសម្រេចអំពីបញ្ហាទាំងអស់នេះដែរឬទេ?

**ឆ៖** ខ្ញុំនឹកមិនឃើញថាមានរឿងរ៉ាវណាមួយដែលឪពុកម្ដាយ ធ្វើការបង្គាប់ជាក់លាក់ទៅកាន់កូនៗរបស់ខ្លួននោះទេ នៅមុនសម័យខ្មែរក្រហម <ថាពួកគេត្រូវតែមានកូន ដើម្បីរក្សាខ្សែគ្រួសារ>។ ខ្ញុំអាចខុស <ព្រោះ>នៅបច្ចុប្បន្ននេះ<នៅកម្ពុជា> ក៏ឪពុកម្ដាយសួរទៅកាន់កូនៗរបស់គាត់អ៊ីចឹងដែរ ខ្ញុំមិនដឹងថានេះជាការណែនាំ ជាបង្គាប់អ្វីនោះទេ។

**ស៖** បើទោះជាការបង្គាប់ ការណែនាំ ឬក៏ជាការផ្ដល់មតិយោបល់ ឬក៏ជាសំណួរតាមបែបផ្ដល់មតិយោបល់ថា គួរតែក៏ដោយ តើកូនប្រុសស្រី ឬក៏គូស្វាមីភរិយាហ្នឹង គាត់មានសិទ្ធិសម្រេច ឬក៏បដិសេធមិនធ្វើតាមដែរឬទេ?

[១១:១៨:៣៤]

**ឆ៖** សូមទោសដែលខ្ញុំមិនដែលបានឆ្លើយទៅសំណួរទី២។ នៅជាភាសាអង់គ្លេសនិយាយថា ឪពុកម្ដាយ<បាន>ប្រាប់ទៅកូនៗថា ពួកគេត្រូវតែមានកូន។ ខ្ញុំគិតថា ឪពុកម្ដាយមិនបាននិយាយបែបនេះទៅកាន់កូនថា នែ! អ្នកឯងគួរតែមានកូននោះទេ។ ប៉ុន្តែគ្រាន់តែឪពុកម្ដាយ គាត់ចង់បានចៅ។ អ៊ីចឹងមើលទៅទិសដៅតែមួយ។ ប្ដីប្រពន្ធដែលរៀបការហើយនេះ គឺថាគួរតែមានកូន។ ប៉ុន្តែខ្ញុំគិតថា ឪពុកម្ដាយ គឺថាមិនបានបង្គាប់ ឬក៏ប្រាប់ទៅកូនៗថា នែ! អ្នកឯងត្រូវតែមានកូនទៅ។ ប៉ុន្តែវាមានគំនាបពី

សង្គម មិនមែនតែពីឪពុកម្ដាយ<បងប្អូន>ទេ គឺសហគមន៍ផងដែរ ថានៅក្នុងសង្គមកម្ពុជា នៅពេលគេរៀបការហើយ គឺថាគេគួរតែមានកូន។ នេះជាគំនាបសង្គម។

[១១:១៩:៤៦]

ស្ត្រី និងបុរស គឺថាមានសិទ្ធិក្នុងការនិយាយថា អត់ទេ មិនចង់បានទេ។ ហ្នឹងនៅក្នុងមុនសម័យខ្មែរក្រហម។ ឯនិយាយតាមន័យបច្ចេកទេស គឺថាអាចអ៊ីចឹងបាន ពីព្រោះថា វាមានការអនុញ្ញាតពន្លូតកូន។ ប៉ុន្តែ<បើ>ខ្ញុំ<ស្រមៃនោះ>ទោះបីប្រុសក៏ដោយ ស្រីក៏ដោយ<>និយាយ<ថា ទេ>ទៅកាន់ឪពុកម្ដាយរបស់គេបានថាគេមិនចង់បានកូន <វាពិបាកស្រមៃណាស់។ ខ្ញុំមិនអាចស្រមៃឃើញថា គ្រួសារ> នៅ<មុន>សម័យខ្មែរក្រហម<មានការពិភាក្សាគ្នាបែបនេះ>។ <>ដូច្នេះនិយាយឡើងវិញមក គឺថា ខ្ញុំ <មិនគិតដូច្នោះទេ។> តាមការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ខ្ញុំមិនគិតថាឪពុកម្ដាយប្រាប់ទៅកូនៗថា នែ! អ្នកឯងត្រូវតែមានកូននោះទេ។ <មិន>មានការបង្គាប់បែបនេះ<ពីឪពុកម្ដាយទេ> គ្រាន់តែថា គាត់ចង់បានចៅ ចង់តចៅអ៊ីចឹងទៅក៏ថា វាមិនមែនជាការបង្គាប់អីនោះទេ។ ប្រសិនណាជាឪពុកម្ដាយនិយាយទៅកាន់កូនស្រីរបស់ខ្លួនថា បើរៀបការនៅពេលនេះ អ្នកឯង<រំពឹងថានឹងមាន>កូន<ទេ? ខ្ញុំមិនជឿថា>កូនស្រី<>ឆ្លើយ<ទៅឪពុកម្ដាយ>ថា ហ៊ឺ! ខ្ញុំសម្រេចថាមិនចង់បានកូនបែបនេះបានទេ។ គឺថាស្ត្រីប្រហែលជាមិនអាចនិយាយបែបនេះបានទេ ប្រហែលជាខាងបុរសនោះក៏មិនអាចនិយាយបែបនេះបានដែរ។

[១១:២១:២៦]

**ស៖** សំណួរចុងក្រោយដើម្បីបញ្ចប់ប្រធានបទរបស់ខ្ញុំ។ តើនៅមុនរបបខ្មែរក្រហមការរៀបការតាមបែបប្រពៃណីបានធ្វើឡើង ហើយក្រោយពីការរៀបការគូស្វាមីភរិយាដែលរស់នៅជាមួយគ្នាហ្នឹងគាត់សម្រេចអំពីការរួមរស់នៅជាមួយគ្នា ការរួមមេត្រីជាមួយគ្នា ដោយខ្លួនឯង ឬក៏មានការសម្រេច ឬក៏ណែនាំពីគោលនយោបាយពីរដ្ឋ ពីថ្នាក់ស្រុក ថ្នាក់ភូមិមកដែរ?

**ឆ៖** នៅក្នុងសម័យខ្មែរក្រហម--

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំនេះ គឺនៅលើប្រធានបទដដែលនៅមុនរបបខ្មែរក្រហម?

**ឆ៖** សូមអធ្យាស្រ័យ សូមរៀបសំណួរឡើងវិញបានទេ?

**ស៖** ដើម្បីឲ្យងាយយល់និងខ្លី តើនៅមុនរបបខ្មែរក្រហម ក្រោយពីគូស្វាមីភរិយាបានរៀបការជាមួយនឹងគ្នាហើយ តើពួកគាត់មានសិទ្ធិសម្រេចអំពីការរួមភេទជាមួយគ្នាដោយខ្លួនឯង ឬក៏មានគោល

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នយោបាយអំពីអជ្ញាធរថ្នាក់ភូមិ ថ្នាក់ស្រុក អំពីផែនការទាំងអស់នេះដែរ?

[១១:២៣:១៨]

**ឆ៖** នេះគឺជាបញ្ហាផ្ទាល់ខ្លួន។ អ្នកខាងក្រៅ លើកលែងតែប្ដីប្រពន្ធទេ គឺថាអ្នកខាងក្រៅគេមិនអាចបង្គាប់ ឬក៏ថាណែនាំឲ្យអ្នកទាំងនោះរួមភេទអីជាមួយគ្នានោះទេ។ ខ្ញុំចាំ ខ្ញុំជួបស្ត្រីម្នាក់ដែលបានរៀបការមុនសម័យខ្មែរក្រហម ប៉ុន្តែគាត់អត់បានរួមភេទជាមួយប្ដីទេ គឺថាតាំងពីការហើយ បីខែ អត់សោះ អៀនពេក ហើយប្ដីនោះក៏អៀនដូចគ្នា។ ដោយសារថាអ្នកទាំងពីរហ្នឹងត្រូវបានឪពុកម្ដាយហ្នឹងគឺថាផ្សំផ្គុំបង្គាប់ឲ្យរៀបការ។ ខ្ញុំគិតថាមានគូស្រករជាច្រើនក៏អ៊ីចឹងដែរ។ ពីព្រោះថាគូស្រករហ្នឹងគេជួបលើកដំបូងគឺនៅថ្ងៃការហ្នឹងតែម្ដង។ អ៊ីចឹងកាលណាគេអៀនហើយ គឺថាអ៊ីចឹងហើយ មិនអាចទៅរួចទេ មិនអាចរួមដំណេកអីជាមួយគ្នាភ្លាមបានទេ។

[១១:២៤:១៤]

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណអ្នកស្រីអ្នកជំនាញ។

លោកប្រធាន ខ្ញុំបានបញ្ចប់ប្រធានបទរបស់ខ្ញុំ សូមបន្តវេទិកានេះជូនទៅលោក វីល្លៀម ស្មីត។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរសហការីទាំងអស់ <និងអ្នកជំនាញ>។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក<ប្រធាន តើខ្ញុំអាច>ចាប់ផ្ដើមដោយសូមផ្ដល់ជូននូវឯកសារមួយចំនួនទៅលោកស្រី ហើយដែលយើងបានជូនដំណឹងទៅមេធាវីការពារក្ដីប៉ុន្មានអាទិត្យមុននេះរួចមកហើយ ហើយក៏ដូចជាការបង្ហាញទៅដល់អ្នកជំនាញនូវផែនទីផងដែរ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះជូនលោកអ្នកជំនាញ។

*(មន្ត្រីតុលាការយកឯកសារជូនអ្នកជំនាញ)*

[១១:២៥:០៤]

**សួរដោយលោក វីល្បៀម ស្មីត៖**

**ស៖** បាទ អរុណសួស្តីកញ្ញាអ្នកជំនាញ។ ខ្ញុំសុំយោងទៅពីរបីទំព័រនៃសៀវភៅរបស់លោកស្រី។ គឺថានៅទំព័រដំបូង យើងឃើញមានចំនួនជាច្រើន ឬក៏នៅខាងក្បែរៗទំព័រនេះក៏យ៉ាងដូច្នោះដែរ។ ដោយ-សារតែការបោះ ព្រីនចេញមកក្រៅ។ ក៏ប៉ុន្តែនៅពេលជាមួយគ្នា ខ្ញុំសុំអនុញ្ញាតពីលោកប្រធាន អនុញ្ញាតឱ្យយើងខ្ញុំបង្ហាញ បញ្ចាំងបង្ហាញនៅលើអេក្រង់នូវសម្រង់មួយចំនួនផងដែរ ដើម្បីងាយស្រួលតាម។ ហើយនៅសល់ពេលតែពីរបីនាទីទៀតទេ ត្រូវសម្រាកពិសារបាយថ្ងៃត្រង់ ខ្ញុំសុំពន្យល់អំពីគោលបំណងរបស់ខ្ញុំ ដែលខ្ញុំត្រូវសួរទៅលោក ទៅកញ្ញាអ្នកជំនាញនៅព្រឹកនេះ តាមរយៈសហការីរបស់ខ្ញុំនោះ ខ្ញុំក៏ គឺខ្ញុំក៏សុំនិយាយអំពីការរៀបការនៅក្នុងសម័យខ្មែរក្រហម។ ដូចដែលយើងបានពិភាក្សាពីខាងមុនមកហើយ គឺការរៀបការនៅមុនសម័យខ្មែរក្រហម គឺយើងចង់ដឹង ថាតើមានការខុសគ្នា មានការផ្ទុយគ្នា មានការកែប្រែទៅដល់របៀបរបបរៀបការនៅក្នុងសម័យខ្មែរក្រហមដែរឬក៏អត់។ ដូច្នេះ សំណួរដំបូងរបស់ខ្ញុំទៅកាន់លោកស្រី គឺនៅក្នុងសម័យខ្មែរក្រហម នៅពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចរួមមកនោះ តើដំណើរការនៃការរៀបការ មានការផ្លាស់ប្តូរណាមួយជាចម្បងដែរឬទេ? បាទ សូមឆ្លើយសង្ខេបបានហើយ បានខ្ញុំសួរលម្អិតទៅតាមក្រោយទៀត។

[១១:២៧:០០]

**ផ៖** ចាស សូមអរគុណច្រើន។ នៅពេលខ្មែរក្រហមឡើងកាន់កាប់អំណាច ខ្មែរក្រហមបានផ្លាស់ប្តូរយ៉ាងខ្លាំងនូវរបៀបរបប ឬក៏ថាប្រព័ន្ធ ឬក៏របៀបរបបនៃការរៀបការនេះ <គឺពួកគេបានផ្លាស់ប្តូរអ្វីៗទាំងអស់>។

**ស៖** យោងទៅតាមភស្តុតាងរបស់លោកស្រីពីខាងដើម លោកស្រីឆ្លើយថា ការរៀបការនៅមុនសម័យខ្មែរក្រហម គឺជាបញ្ហារបស់គ្រួសារ។ ១00ភាគរយហើយ គឺជាបញ្ហារបស់គ្រួសាររវាងកូនប្រុសកូនស្រី រវាងឪពុកម្តាយ។ នៅក្នុងសម័យខ្មែរក្រហមវិញ តើការយល់ព្រម ឬការអនុញ្ញាត ឬក៏ដំណើរការនៃការរៀបការ វាជាបញ្ហារបស់គ្រួសារវិញដែរ ឬក៏ជាវាបញ្ហារបស់រដ្ឋទេ?

**ផ៖** <នីតិវិធីនៃការរៀបការ>គឺថាវាមានការ<ខុសគ្នា>ច្រើន ប៉ុន្តែខ្មែរក្រហមមានសិទ្ធិផ្តាច់មុខតែម្តងក្នុង ការអនុញ្ញាតឱ្យរៀបការនេះ។

**ស៖** ឥឡូវនេះខ្ញុំចង់សួរតាមពីខាងក្រោយ គឺសួរពាក់ព័ន្ធទៅនឹងសៀវភៅរបស់លោកស្រី ដែលទាក់ទងទៅនឹងភាពជាម្តាយ និង -- គឺឯកសារ E3/10655 ភាពជាម្តាយនៅក្នុងពេលសង្គ្រាម ការមាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្ទៃពោះក្នុងសម័យខ្មែរក្រហម ERN គឺ <01322862> <ហើយនិងជំពូកទី៥>នៃសៀវភៅរបស់លោកស្រី លោកស្រីលើកៗមកពិភាក្សាអំពី<ការរៀបការនៅក្នុងរបបខ្មែរក្រហម។ ហើយនៅក្នុងផ្នែកមួយនៃសៀវភៅនេះ លោកស្រីបានពិភាក្សាពី>របៀបពីរ <ដែល>ស្រី និងប្រុសត្រូវរៀបការជាមួយគ្នា<នៅពេលដំបូង>។ ទី១ គឺការរៀបការ គឺត្រូវតែអនុញ្ញាតដោយខ្មែរក្រហម ក្រោយមានសំណើ។ ហើយមួយទៀត គឺថាការបង្ខំឲ្យរៀបការដោយខ្មែរក្រហម ដោយមិនមានសំណើពីសាមីខ្លួន។ តើត្រឹមត្រូវទេថា <តាមការសរសេរ>នៅក្នុងសៀវភៅរបស់លោកស្រី<ៗយល់>ថា ការរៀបការក្នុងសម័យខ្មែរក្រហមមានពីររបៀបបែបនេះឯង។ ទី១ គឺដាក់សំណើទៅ ហើយទើបមានការអនុញ្ញាតជាក្រោយ។ ហើយមួយទៀត គឺៗថាការបង្ខំឲ្យរៀបការ ដោយមិនបាច់មានការដាក់សំណើទេ អ៊ីចឹងមែនទេ?

[១១:២៩:៤៣]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយ សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរ លោក លោកស្រីចៅក្រម សហការីទាំងអស់។ ខ្ញុំសូមជំទាស់ពាក់ព័ន្ធទៅនឹងពាក្យដែលបានប្រើប្រាស់នៅក្នុងការតាំងជាសំណួរនេះ សំណួរដែលចេញមកពីសហព្រះរាជអាជ្ញាគឺបានប្រើពាក្យខ្មែរក្រហមទៀតហើយ។ ថ្ងៃនេះយើងមិនបានសួរទៅកាន់សាក្សី<ទេ គឺយើងសួរទៅ>អ្នកជំនាញ។ ពាក្យខ្មែរក្រហមមិនពាក់ព័ន្ធទៅនឹងអំណាចរដ្ឋនៅពេលនោះទេ <អាចត្រឹមកម្រិតតំបន់ ឬកម្រិតជាតិ វាគ្មានន័យអ្វីទាំងអស់>។ ដូច្នេះ យើង<ត្រូវតែច្បាស់លាស់>បន្តិចនៅពេលដែលសួរសំណួរទៅកាន់អ្នកជំនាញ ថាតើយើងកំពុងនិយាយកម្រិតណាដែរ? ពីព្រោះ<ពាក្យថា>ខ្មែរក្រហមដូចជារឿងមួយ<ងាយស្រួលប្រើ>មែន ក៏ប៉ុន្តែមិនមានន័យអីទេ។ អ៊ីចឹងនៅពេលដែលសហព្រះរាជអាជ្ញាសួរ សហព្រះរាជអាជ្ញាគួរតែសួរឲ្យបានជាក់លាក់ថា តើពេលនោះយើងនិយាយអំពីកម្រិតរដ្ឋ កម្រិតណាដែលយើងនិយាយកម្រិតរដ្ឋថ្នាក់កំពូលតែម្តង ឬថ្នាក់ភូមិ ថ្នាក់ឃុំ។ តើនិយាយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏និយាយអំពីអ្វីសូមឲ្យច្បាស់លាស់។ បាទនិយាយសរុបមកវិញគឺថា មុននឹងតាំង នៅពេលតាំងសំណួរសូមសួរឲ្យបានច្បាស់លាស់ ពីព្រោះវាមានបញ្ហាថាពេលខ្លះវាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ណាមួយ ពាក់ព័ន្ធទៅនឹងអាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធទៅនឹងគោលនយោបាយ ឬក៏ពាក់ព័ន្ធទៅនឹងអំណាចរដ្ឋតែម្តង។ អ៊ីចឹងសូមឲ្យច្បាស់លាស់បន្តិច។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វីល្លៀម ស្មីត៖**

ហេតុផលដែលថា បានជាពាក្យនេះត្រូវបានយកមកប្រើប្រាស់ ពីព្រោះថាអ្នកជំនាញរូបនេះក៏បើប្រើពាក្យថារបបខ្មែរក្រហមតែម្តងនៅក្នុងសៀវភៅរបស់គាត់នេះ។ អ៊ីចឹង ខ្ញុំសួរតាមពីខាងក្រោយអ្នកជំនាញទេ ខ្ញុំយល់ហើយនូវអ្វីដែលមេធាវីការពារក្តីលើកឡើង ប៉ុន្តែនៅពេលនេះយើងព្យាយាមពិភាក្សាគ្នា<លើគំនិតជាច្រើន ហើយយើងត្រូវនិយាយដោយប្រើប្រាស់>ពាក្យពេចន៍<ឲ្យបានទូលាយបន្តិច។> ប៉ុន្តែខ្ញុំយល់ឃើញថាសហការី មេធាវីការពារក្តីប្រហែលជាសូមស្តាប់ឲ្យបានល្អិតល្អន់បន្តិចសិនទៅ ពេលនោះយើងនឹងយល់ហើយ តើថ្នាក់ដឹកនាំមានពាក់ព័ន្ធជាមួយនឹងការ<បញ្ជាឲ្យមានការ>រៀបការដោយបង្ខំដែរឬក៏អត់ ឬក៏ការរៀបការដោយបង្ខំ ធ្វើឡើងសម្រេចឡើងដោយអាជ្ញាធរមូលដ្ឋានទេ?

[១១:៣២:៤០]

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់ ចាំដល់វេនរបស់មេធាវី មេធាវីអាចសួរបំភ្លឺបាន។

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ ខ្ញុំមើលទៅឃើញដល់ពេលវេលាហើយ ប៉ុន្តែខ្ញុំអាចបន្តសួរបាន។ កញ្ញាអ្នកជំនាញ -- ប្រហែលជាខ្ញុំផ្អាកត្រឹមនេះសិនហើយមើលទៅ ដល់ពេលហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

ដល់ពេលឈប់សម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

កញ្ញា កាស៊ូមិ ឥឡូវដល់ពេលសម្រាកហើយ កញ្ញាអាចសម្រាកបានហើយ អង្គជំនុំជម្រះអញ្ជើញកញ្ញាមកកាន់កន្លែងផ្តល់សក្ខីកម្មវិញឲ្យបានមុនម៉ោងមួយកន្លះរសៀល។

បង្គាប់អនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។ សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ។

**សួរដោយលោក វីណ្សៀម ស្មីត៖**

សូមអរគុណ។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់ និងសូមជម្រាបសួរអ្នកជំនាញ។

**ស៖** មុនពេលយើងឈប់សម្រាកបាយថ្ងៃត្រង់ <>លោកស្រី<បាននិយាយ>ថា ក្នុងរបបប៉ុលពត មាន<របៀប>រៀបការហ្នឹងពីរ។ ទី១ គឺក្នុងករណីដែលគូស្រករត្រូវបានអនុញ្ញាតឲ្យរៀបការ។ ហើយមួយទៀតនោះ គឺគូស្រករត្រូវបានបង្ខំឲ្យរៀបការ។ ខ្ញុំចង់សួរលោកស្រីសង្ខេបខ្លីថា តើការរៀបការដែលត្រូវបានគេអនុញ្ញាតហ្នឹង គឺវាដំណើរការដោយរបៀបណា? តើលោកស្រីអាចរៀបរាប់អំពីដំណើរការវាបន្តិចបានទេ? ហើយតើៗវាមានភាពខុសគ្នាយ៉ាងណាដែរ ទៅនឹងការរៀបការនៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ?

**កញ្ញា កាស៊ូមិ ណាកាហ្គាវ៉ា៖**

**ឆ៖** សូមអរគុណ។ ជម្រាបសួរ។ អាពាហ៍ពិពាហ៍ដែលត្រូវបានអនុញ្ញាតដោយខ្មែរក្រហម គឺខុសគ្នាពីរបៀបគូស្រកររៀបការនៅមុនសម័យខ្មែរក្រហម។ នៅក្នុងសម័យខ្មែរក្រហមប្រសិនបើអ្នកណាម្នាក់ចង់រៀបការគឺគេត្រូវស្នើសុំការអនុញ្ញាតពីខ្មែរក្រហម។ ដំណើរការនេះមិន<មាន>ធ្វើឡើងនៅមុនសម័យខ្មែរក្រហមនោះទេ។ មានន័យថា នៅមុនសម័យខ្មែរក្រហមអ្នកដែលត្រូវរៀបការហ្នឹងគឺមិនចាំបាច់សុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានដែលជាអ្នកតំណាងឲ្យរដ្ឋនោះទេ។ ក៏ប៉ុន្តែក្នុងសម័យខ្មែរក្រហម ដើម្បីទទួលបានការអនុញ្ញាតរៀបការ មានន័យថាឲ្យការរៀបការរបស់ខ្លួនហ្នឹងស្របច្បាប់ គឺថាខ្លួនត្រូវស្នើសុំការអនុញ្ញាតពីខ្មែរក្រហម គឺដែលជាការ<អនុម័ត>មួយក្នុង<ការរៀបការ>ជាច្រើន។

[១៣:៣២:៣៣]

**ស៖** បាទ ហើយចំពោះការអនុញ្ញាតចំពោះសំណើសុំនេះ តើជាសំណើសុំធម្មតាដែលគេធ្វើឡើងនៅមុនសម័យខ្មែរក្រហម បែបប្រហែលវាអាចថាកូនកម្លោះហ្នឹងស្នើសុំរៀបការជាមួយនឹងស្រីណា

ម្នាក់ ហើយគេត្រូវទៅជួបឪពុកម្ដាយរបស់ខាងស្រី ហើយមានដំណើរការនិយាយគ្នាទៅ។ តើលក្ខណៈនេះ វាស្រដៀងគ្នាទៅនឹងការស្នើសុំ ឬក៏ការរៀបចំអាពាហ៍ពិពាហ៍មុនសម័យខ្មែរក្រហមនោះដែរឬទេ?

**ឆ៖** ភស្តុតាងដែលខ្ញុំទទួលបានពីប្រជាជន គឺ<ប្រហែលជា>មិនតំណាងឲ្យអ្នកដែលគេរៀបការ<ដោយបានស្នើសុំ>ទាំងអស់នោះ<>ទេ។ ក៏ប៉ុន្តែតាមរយៈការសន្ទនា ការសម្ភាសរបស់ខ្ញុំនោះគឺដំណើរការ ការរៀបការដោយស្នើសុំនោះ ស្រដៀងគ្នាទៅនឹងការរៀបការមុនសម័យខ្មែរក្រហមដែរ។ មានន័យថាឪពុកម្ដាយទាំងសងខាងហ្នឹងក៏ត្រូវការមានការយល់ស្របគ្នា ហើយក៏ត្រូវទៅកាន់ខ្មែរក្រហមដើម្បីស្នើសុំនោះដែរ។ ក៏ប៉ុន្តែករណីដែលខ្ញុំធ្លាប់បាន<ឮ គឺ>មានស្ត្រីម្នាក់ហ្នឹងគឺគាត់ទៅសុំ ស្នើសុំអង្គការដោយផ្ទាល់តែម្ដង។ <ក្នុងន័យនេះ ខ្ញុំអត់មានភស្តុតាងបញ្ជាក់អំពីនីតិវិធីនេះទេ។>

**ស៖** នៅពេលដែលលោកស្រីនិយាយថា គឺគេត្រូវទៅជួបខ្មែរក្រហមសុំការអនុញ្ញាត លោកស្រីចង់និយាយអំពីខ្មែរក្រហមនៅថ្នាក់មជ្ឈិម ឬក៏នៅថ្នាក់មូលដ្ឋាន នៅថ្នាក់ភូមិជាក់លាក់ណាមួយ?

**ឆ៖** គឺការសម្ភាសរបស់ខ្ញុំនោះ គឺខ្ញុំសម្ភាសពាក់ព័ន្ធទៅនឹងគូស្រករនៅតាមភូមិទាំងអស់។ គឺគេស្នើសុំអាជ្ញាធរភូមិតែម្ដង។

[១៣:៣៥:០០]

**ស៖** តាមរយៈការស្រាវជ្រាវរបស់លោកស្រី តើលោកស្រីមានបានគិតឃើញថា អាជ្ញាធរខ្មែរខ្មែរក្រហមថ្នាក់ភូមិយកមកពិចារណាថា គេត្រូវសម្រេចយល់ព្រម ឬក៏មិនយល់ព្រមយ៉ាងណាដែរនោះឬទេ?

**ឆ៖** វាមានលក្ខណៈខុសគ្នាយ៉ាងខ្លាំង ខ្ញុំមិនអាចនិយាយបានថា វាមានលក្ខណៈដូចៗគ្នានោះទេ អ្នកខ្លះត្រូវបានគេអនុញ្ញាត ប្រសិនណាជាខ្លួនមានអាយុក្នុងកម្រិតណាមួយ ឧទាហរណ៍ថា ចន្លោះពី២០ទៅ២៥ ប៉ុន្តែអ្នកដែលអាយុក្មេងពេកចង់រៀបការ គឺវាមានការហាមឃាត់ ដែលអាជ្ញាធរខ្លះកំណត់ហាមឃាត់មិនឲ្យរៀបការទេ អាយុក្មេងពេក។ យ៉ាងហោចណាស់ក៏នៅក្នុងខេត្តកំពង់ចាមដែរ ដែលគេមិនបានអនុញ្ញាតឲ្យអ្នកណាម្នាក់រៀបការទេ រហូតដល់ពេលវេលាណាមួយជាក់លាក់។ បើទោះណាមានការស្នើសុំរៀបការក៏ដោយ ក៏អាជ្ញាធរប្រាប់ថា រង់ចាំសិន ចាំដល់ពេលវេលាកំណត់មួយជាក់លាក់ហ្នឹងក្នុងឆ្នាំ១៩៧៨ <បើខ្ញុំមិនច្រឡំទេ។ ដូច្នេះវាខុសគ្នាខ្លាំង>។

**ស៖** ចំពោះឧទាហរណ៍នៅកំពង់ចាមនេះ លោកស្រីដឹងថា មានមូលហេតុអ្វីទេ ដែលគេមិនអនុញ្ញាតឲ្យរៀបការរហូតដល់កាលកំណត់ណាមួយនោះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំមិនបានដឹងទេ ហើយអ្នកដែលទៅសម្ភាសដោយផ្ទាល់នោះ អាហ្នឹងក៏មិនបានដឹងយ៉ាងណានោះដែរ។

[១៣:៣៦:៥១]

**ស៖** តាមរយៈកិច្ចសម្ភាសន៍ និង ការសិក្សាស្រាវជ្រាវដែលលោកស្រីបានធ្វើ តើលោកស្រីអាចជម្រាបជូនតុលាការបានទេថា មូលហេតុចម្បងនោះវាមានអ្វីខ្លះដែរ ដែលថាហេតុអ្វីបានជាបុរសស្ត្រីហ្នឹងបានស្នើសុំរៀបការ?

**ឆ៖** មានភាពខុសគ្នាច្បាស់លាស់ណាស់ រវាងបុរស និងស្ត្រី សម្រាប់ធ្វើម៉េចឲ្យគេ -- សម្រាប់ធ្វើម៉េចឲ្យខ្លួនអាចស្នើសុំរៀបការបាននោះ។ សម្រាប់ស្ត្រី កត្តាចម្បងជំរុញបង្ខំមែនទែននោះ គឺខ្មែរក្រហមបានអនុញ្ញាតឲ្យកងទ័ពខ្មែរក្រហម<ដែលត្រូវរបួស>នោះ ជ្រើសរើសប្រពន្ធ ជ្រើសរើសគូស្រករ។ នេះតាមខ្ញុំដឹងគេអនុវត្តនៅទូទាំងប្រទេសតែម្តង។ អ៊ីចឹងស្ត្រីក្មេងៗ ពួកគាត់ភ័យខ្លាចណាស់ ប្រសិនណាពួកគាត់ត្រូវបានកងទ័ពខ្មែរក្រហមដែលរងរបួសនេះ ឬក៏ថា អាចរហូតដល់ពិការហ្នឹង ហើយមកជ្រើសរើសខ្លួនយកធ្វើជាប្រពន្ធហ្នឹង។ អ៊ីចឹងរាល់ស្ត្រីដែលត្រូវបានកងទ័ពពិការ ឬរងរបួសស្នើសុំហ្នឹងខ្លាចណាស់។ ហើយ<រឿងនេះមិនបានកើតឡើងចំពោះបុរស>នោះទេ។

ហើយកត្តាសំខាន់មួយទៀត សម្រាប់ស្ត្រីដែលនៅលីវ ដែលត្រូវស្នើសុំរៀបការឲ្យបានលឿនៗហ្នឹងគឺថា ពួកគាត់ហ្នឹងជឿជាក់ថា ប្រសិនណាពួកគាត់បានរៀបការហើយហ្នឹង ពួកគាត់វាមានលក្ខណៈប្រសើរជាង ដូចជាអ្នកដែលរៀបការហើយហ្នឹងអាចស្នាក់នៅជិតឪពុកម្តាយ ព្រោះវាសំខាន់ណាស់ នេះគឺជាកាតព្វកិច្ចមួយចម្បងសម្រាប់កូនស្រីនៅកម្ពុជាយើងនេះ ដែលត្រូវថែទាំមើលឪពុកម្តាយ។ <ហើយទី២ គេ>ជឿថា កាលណាខ្លួនក្លាយទៅជាប្រពន្ធរបស់គេ គឺថាវាអាចបន្ថយបន្ទុកពលកម្មហ្នឹងបានមួយចំនួនដែរ។ អ៊ីចឹងបានជាស្នើសុំរៀបការហ្នឹង។ អ៊ីចឹងចំពោះខាងបុរសវិញ ខ្ញុំអត់មានព័ត៌មាន មិនដឹងថាមានកត្តាជំរុញអ្វីដែលនាំឲ្យបុរសហ្នឹងស្នើសុំរៀបការនោះទេ។

[១៣:៣៩:២៦]

**ស៖** លោកស្រីបានលើកឡើងនិយាយអំពីកងទ័ពពិការ ដែលត្រូវជ្រើសរើសគូស្រករដើម្បីរៀបការ។ នៅក្នុងឯកសាររបស់លោកស្រី គឺឯកសារ E3/2959, អង់គ្លេស <00421894> ដល់ -- 895, ខ្មែរ 00738350, បារាំង 00701497។ លោកស្រីបាននិយាយទៅកាន់<ស្ត្រី>ម្នាក់ដែលត្រូវបានគេបង្ខំ<>ឲ្យរៀបការ<ជាមួយបុរសពិការម្នាក់ ហើយគាត់>ថា៖ “ប្តីរបស់ខ្ញុំ គឺជនពិការ គាត់ពិការ<ជើង>

មួយចំហៀង <គេឲ្យគាត់ទៅលើកទំនប់ ហើយ>គាត់ដើរ<ជាន់>មីន។ អ៊ីចឹង <អង្គការ>ឲ្យគាត់<មានសិទ្ធិ>ជ្រើសរើសគូស្រករដើម្បីរៀបការ។ <ហើយ>គាត់<បានស្នើសុំទៅអង្គការថាគាត់ចង់>រៀបការជាមួយ<ខ្ញុំ>។ គាត់ពិការជើងមួយចំហៀងក្នុងសម័យខ្មែរក្រហម អ៊ីចឹងគាត់មានសិទ្ធិជ្រើសរើសគូស្រករបាន។”

អ៊ីចឹងសំណួររបស់ខ្ញុំសួរថា បើសិនជាកងទ័ពខ្មែរក្រហមមានសិទ្ធិជ្រើសរើសគូស្រករ តើខាងនារីៗវិញ មានសិទ្ធិបដិសេធបានដែរឬទេ?

**ឆ៖** តាមដែលខ្ញុំដឹង អត់ទេ។ គឺថានារីៗនោះមិនអាចជំទាស់បានទេ គឺថាត្រូវតែធ្វើតាមសេចក្ដីសម្រេចនេះដោយគ្មានត្រូវសួរអ្វីនោះឡើយ។

[១៣:៤១:០៧]

**សៈ** ហើយនៅក្នុងរឿងមួយទៀត នៅក្នុងរឿងរ៉ាវមួយ លោកស្រីបាននិយាយទៅកាន់អតីត<កុមារ>យោធា<ខ្មែរក្រហម អំពីអាទិភាពរបស់>កងទ័ពខ្មែរក្រហម<ក្នុងការ>ជ្រើសរើសប្រពន្ធនេះ។ នៅក្នុងសៀវភៅរបស់លោកស្រី ទំព័រលេខ៣៣ គឺ E3/2959, អង់គ្លេស 00421894, ខ្មែរ 00738349, បាទ ហើយបារាំង 00701479។ កងទ័ពដែលជាកុមារ អ្នកនិយាយគឺ “ចំណុចល្អ<មួយអំពីខ្មែរក្រហមនោះ>គឺថា បើយើងចង់រៀបការប្រពន្ធជាមួយអ្នកណាម្នាក់ យើងអាចស្នើសុំអង្គការ<ប៉ុន្តែការរំលោភគឺត្រូវបានហាមឃាត់ជាដាច់ខាត>។ គឺថាយើងអាចរៀបការជាមួយអ្នកណាម្នាក់ដែលៗក៏បានដែរ ឲ្យតែយើងស្រឡាញ់។ <ប៉ុន្តែយើងត្រូវតែសួរនាងដែរ ហើយបន្ទាប់មក>យើងក៏ដាក់សំណើសុំទៅអង្គការ។ បើសិនណាជានារីនោះមិនព្រមទេ ក៏អង្គការបង្ខំដែរ។” តើនេះជារឿងរ៉ាវធម្មតាដែលលោកស្រីបានស្ដាប់ឮនៅរាល់កិច្ចសម្ភាសន៍ថា នៅ -- គឺថាកងទ័ពខ្មែរក្រហមហ្នឹង មានសិទ្ធិច្រើនណាស់ មានសិទ្ធិសម្បើមណាស់ក្នុងការជ្រើសរើសគូស្រករនារីណាម្នាក់យកមកធ្វើជាប្រពន្ធនោះ។ ហើយស្ត្រីវិញ គឺថាមិនអាចបដិសេធបានដែរ។ តើស្ថានភាពបែបនេះ ជាស្ថានភាពទូទៅ ឬក៏យ៉ាងណា?

[១៣:៤២:៥០]

**ឆ៖** តាមការដែលខ្ញុំយល់តាមរយៈកិច្ចសម្ភាសន៍នេះ <ចម្លើយរបស់អតីត>កងទ័ពខ្មែរក្រហមដែលជាកុមារនេះ<គឺកម្រមានណាស់ ដែល>គាត់ៗត្រូវស្នើសុំយោបល់ហ្នឹងពីស្ត្រីហ្នឹង។ ជាធម្មតាតាមដែលខ្ញុំធ្លាប់ឮហ្នឹង គឺប្រសិនជាស្ត្រី នារីនៅលីវណាម្នាក់ ត្រូវបានគេជ្រើសរើសរៀបការជាមួយនឹងកងទ័ពពិការ គឺគាត់ត្រូវតែរៀបការជាមួយនឹងកងទ័ពនោះ។ ខ្ញុំបានសម្ភាសកងទ័ពយោធាពិការម្នាក់

01364768



<នៅដើមឆ្នាំនេះ>នៅៗរតនគិរី ដែលជាអតីតកងទ័ពខ្មែរក្រហម។ គាត់ក៏បានបញ្ជាក់អះអាងដូចគ្នានេះដែរ។ <មិនងាយស្រួលទេសម្រាប់ខ្ញុំដែលបានជួបអតីតកងទ័ពខ្មែរក្រហមបែបនេះ។> កាលនោះ គឺខ្ញុំជួបគាត់ដោយចៃដន្យ <គឺខ្ញុំមាន>សំណាងល្អ។ <គាត់ថា> គាត់បានរៀបការនៅក្នុងឆ្នាំ១៩៧៥ ក្រោយគាត់សម្រាកនៅមន្ទីរពេទ្យអស់រយៈពេលបីខែ សំណាងហើយដែលគាត់មិនស្លាប់។ ក្រោយពីគាត់ត្រឡប់ទៅកំពង់ចាមវិញ គាត់លែងអាច<ដើរ>កើតទៀតហើយ គាត់ក៏ស្នើសុំមេរបស់គាត់ដែលជាខ្មែរក្រហមនោះថា នេះឥឡូវនេះ ខ្ញុំចង់បានប្រពន្ធហើយ។ ហើយមេរបស់គាត់ហ្នឹងថា តើសមមិត្តឯងចង់រៀបការជាមួយអ្នកណា? គាត់ចង្អុលទៅ គាត់ថា នោះខ្ញុំចង់ការជាមួយនារីនោះ។ ហើយខ្ញុំនេះ ក៏សួរទៅយោធាពិការកុមារហ្នឹងថា "ចុះអ្នកឯងម៉េចបានថា ពេញចិត្តជាមួយម្នាក់ហ្នឹង បើនៅឆ្ងាយដែរ?" <ហើយគាត់>ថា "ហ៊ឺ! ខ្ញុំពេញចិត្ត មើលទៅគឺខ្ញុំពេញចិត្ត"។ <ហើយគាត់ក៏បានរៀបការជាមួយនារីនោះ។> ហើយ<ប្រាកដណាស់ មានអ្នកផ្សេងៗទៀតហ្នឹងបញ្ជាក់ថា> ស្ត្រីនារីក្មេងៗជាច្រើនហ្នឹងភ័យខ្លាចណាស់ <ខ្លាច>គេជ្រើសរើសឲ្យរៀបការជាមួយនឹងយោធាពិការនោះ។

[១៣:៤៤:៣៧]

**សៈ** លោកស្រី ក៏បាននិយាយពាក់ព័ន្ធទៅនឹងការអនុញ្ញាតឲ្យរៀបការនេះផងដែរថា ស្ត្រីខ្លះបានសម្រេច -- លោកស្រីថា នារីខ្លះគាត់ចង់រៀបការវិញដែរ ដោយសារថាធ្វើឲ្យការរស់នៅរបស់គាត់មានភាពប្រសើរ <តើត្រឹមត្រូវទេ?> តើពួកគាត់ទាំងនុ៎ងមានពន្យល់ប្រាប់លោកស្រីទេថា ការរស់នៅជីវភាពរស់នៅវាយ៉ាងម៉េចដែរ ដែលគាត់ចង់បានក្រោយការរៀបការ ហើយវាពិបាកយ៉ាងម៉េចមុនហ្នឹង ? ហើយពាក់ព័ន្ធទៅនឹងដែលថា ប្រសិនណាជាពួកគាត់រៀបការ គាត់នឹងមានការរស់នៅហ្នឹងមានលក្ខណៈប្រសើរហ្នឹងវាយ៉ាងដូចម្តេចដែរ?

**ឆៈ** ភាគច្រើននោះ គឺនារីនៅលីវ ដែលស្ថិតនៅក្នុងវ័យបន្តពូជនៅក្នុងកងចល័ត កងនារី ការរស់នៅរបស់ពួកគាត់ហ្នឹងពិបាកណាស់ ពីព្រោះពួកគាត់ត្រូវងើបពីដេកនៅម៉ោងបីព្រឹក ជួនកាលដល់ម៉ោងពីរព្រឹកឯណោះ ហើយពួកគេត្រូវបញ្ជូនឲ្យទៅរស់នៅឆ្ងាយពីឪពុកម្តាយ គឺថាជីវិតរបស់គាត់ហ្នឹងគឺថាគួរឲ្យភ័យខ្លាចណាស់។ អ៊ីចឹងពួកគាត់បានជឿជាក់ថា ប្រសិនណាជាបានរៀបការទៅ គឺឈប់រស់នៅជាមួយក្រុមនោះទៀតហើយ អ៊ីចឹងអាចគេចផុតពីពលកម្មដ៏ធ្ងន់ៗសម្រាប់នារីនៅលីវទាំងអស់នោះ ហើយពួកគាត់អាចរស់នៅជិតឪពុកម្តាយ អាចមើលថែទាំឪពុកម្តាយបានផងដែរ ក្នុងករណីណាមួយដែលឪពុកម្តាយរបស់គេត្រូវការជំនួយពីកូនស្រីនោះ។

[១៣:៤៦:៣០]

**ស៖** សូមអរគុណ។ តើលោកស្រីមានសួរសំណួរជាក់លាក់បែបនេះទៅនឹងនារីដទៃទៀតថា ប្រសិនណាការរៀបការនេះមិនមែនដើម្បីឲ្យគេចផុតពីពលកម្មធ្ងន់ធ្ងរ និងជីវភាពនេះទេ តើពួកគាត់ចង់ការដែរ ដោយផ្ទាល់ដែរឬក៏យ៉ាងណា? <តើលោកស្រីមានបានសួរពួកគាត់ដោយផ្ទាល់បែបនេះទេ ឬមួយក៏នោះជាការពិចារណាចេញពីការ>សម្ភាស<ទាំងអស់នោះ>?

**ឆ៖** ខ្ញុំអត់បានសួរតាមរបៀបនេះទេ អ៊ីចឹងព័ត៌មានដែលខ្ញុំបានទទួលហ្នឹងគឺអ្វីដែលគេបានប្រាប់ខ្ញុំតែប៉ុណ្ណោះ។

**ស៖** គំនិតយោបល់របស់លោកស្រីនេះគឺថា ដោយសារតែការរស់នៅដ៏លំបាកលំបិនហ្នឹង គឺពេលហ្នឹងជាកត្តាមួយជំរុញឲ្យពួកគាត់ទទួលយកសំណើសុំរៀបការហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវហើយ ខ្ញុំអាចនិយាយថា ខ្ញុំយល់ថាពួកគាត់ហ្នឹង <>ចង់រៀបការ អ៊ីចឹងគេស្នើសុំហើយ មិនចាំបាច់ដល់ខ្មែរក្រហមមកសួរពួកគេវិញនោះទេ។

**ស៖** សូមអរគុណ។ តើលោកស្រីអាចពន្យល់ជូនតុលាការសង្ខេបបានទេ នៅក្នុងពិធីរៀបការហ្នឹង ដោយសារថាស្ថានភាពវាអាចខុសៗគ្នាពីកន្លែងមួយទៅកន្លែងមួយនោះ តែខ្ញុំសួរអំពីទិដ្ឋភាពរួម។ តើពិធីរៀបការទៅឲ្យអ្នកដែលបានស្នើសុំ ហើយអង្គការយល់ព្រម តើវាខុសគ្នាពិធីរៀបការមុនសម័យខ្មែរក្រហមដោយរបៀបណាដែរ?

[១៣:៤៨:២៨]

**ឆ៖** ពិធីរៀបការហ្នឹងគឺខុសគ្នាពីពិធីរៀបការនៅមុនសម័យខ្មែរក្រហម។ និយាយឲ្យងាយយល់ទៅ គឺថាដូចអង្គប្រជុំមួយអ៊ីចឹង។ គឺថាគេប្រមូលមនុស្សមកប្រជុំមក ហើយបុរសនិងស្ត្រីហ្នឹងគេហៅមកឲ្យចូលរួមជួបជុំគ្នាប្រជុំទៅ ហ្នឹងគឺជាការរៀបការហើយ។ អត់មានភ្ញៀវមកពីខាងគ្រួសារទាំងសងខាងអត់មានភ្ញៀវដែលជាមិត្តភក្តិ ជាអ្វីនោះទេ។ គឺមានវត្តមានតែគូស្រករដែលត្រូវរៀបការនេះទេ ដោយសារថា វាមាន ជាពិធីរៀបការរួម មានពីរបីគូឡើងទៅ។ ហើយវាអាចមានខ្មែរក្រហម ឬថាថ្នាក់ដឹកនាំមូលដ្ឋានមានមេភូមិ មេឃុំជាដើមនោះ គឺថាមានវត្តមាន ហើយមានម្នាក់ឡើងនិយាយទៅ គឺអាហ្នឹងគឺពិធីរៀបការហើយ។ ហើយពិធីរៀបការនេះខ្លីណាស់ គេចង់សន្សំសំចៃពេលវេលាហើយមើលទៅពេលវេលាណាស់។ រាល់គូស្រករទាំងអស់ មិនទាំងអស់ទេ ក៏ប៉ុន្តែគូស្រករមួយៗតម្រូវឲ្យឡើងប្តេជ្ញាគឺថាគេបានរៀបការដោយស្ម័គ្រចិត្តនៅចំពោះមុខអង្គការ អ៊ីចឹងមកក៏អាការប្រជុំដោយចាត់ទុកដូចរៀប

ការហ្នឹងក៏ចប់ទៅ។

**ស៖** តើមានពិធីសាសនាដូចជាព្រះពុទ្ធសាសនា ពិធីសាសនាអ្វីមួយ រួមទាំងព្រះពុទ្ធសាសនាផងដែរ <ដូចនៅសម័យមុនកម្ពុជាប្រជាធិបតេយ្យនោះទេ>?

**ឆ៖** ខ្មែរក្រហមលុបបំបាត់សាសនាហើយ អ៊ីចឹងមិនមានពិធីសាសនាអ្វីទាំងអស់ មិនមានលោកសង្ឃអ្វីនៅក្នុងពិធីរៀបការនេះទេ។

**ស៖** ខ្ញុំដឹងថា លោកស្រីបានលើកឡើងពីចំណុចនេះ។ ចុះលោកស្រីថា ការរៀបការហ្នឹងខ្លី តើខ្លីប៉ុនណា ហើយបើយូរ យូរប៉ុនណាដែរ?

[១៣:៥០:៤៥]

**ឆ៖** ខ្ញុំមិនបានសួរឲ្យបានច្បាស់លាស់ថា សម្រាប់ការរៀបការមួយៗនោះវាមានរយៈពេលខ្លីប៉ុនណា ក៏ប៉ុន្តែខ្ញុំសន្មតថា មួយម៉ោងគ្រប់គ្រាន់ហើយ។ ពីព្រោះគេថា បើសិនណាជាមានគូស្រករ ១០០គូ ត្រូវទៅរៀបការហ្នឹង គេមាន នៅក្នុងគូស្រករហ្នឹងក៏មានតំណាងដែរ គេមិនឲ្យគូស្រករទាំង ១០០គូឡើងប្ដេជ្ញាទាំងអស់គ្នាទេ គេមានតំណាងគូស្រករហ្នឹងដែរ។ ហើយម្នាក់ៗឆ្លើយអ៊ីចឹងមែន ឆ្លើយថា ពិធីរៀបការនេះខ្លីមែនទែន។

**ស៖** ខ្ញុំនៅតែចង់សួរលោកស្រីពាក់ព័ន្ធទៅនឹងការរៀបការដោយមានការស្នើសុំជាមុនសិន មុននឹងឈានចូលទៅដល់ការរៀបការដោយបង្ខំ។ តើ<មានវត្តមាន>ឪពុកម្ដាយ<ឬសាច់ញាតិទេ ចំពោះ>គូស្រករដែលស្នើសុំ<>អនុញ្ញាត<រៀបការនោះ>?

**ឆ៖** មិនមានទេ គឺថា មានឱកាសតិចណាស់មានវត្តមាន។ <បុរសស្ត្រីមួយចំនួនបានប្រាប់ខ្ញុំថា> ឪពុកម្ដាយរបស់គាត់មានវត្តមាន<នៅកន្លែងរៀបការនោះ ប៉ុន្តែរឿងនេះវាកម្រមានណាស់>។

**ស៖** ឥឡូវពាក់ព័ន្ធទៅនឹងតន្ត្រីភ្លេង សម័យ <ម្ហូបអាហារ ភេសជ្ជៈ> ការរាំរែក អីជាដើម សម្លៀកបំពាក់ គ្រប់ចំណុចទាំងអស់ <តើគេ>ប្រើប្រាស់<ជាធម្មតា>នៅក្នុងពិធីរៀបការ<ដែលគេអនុញ្ញាតនោះ ឬមួយក៏វាកម្រ ហើយមិនធម្មតាទេ>?

[១៣:៥២:៣៥]

**ឆ៖** អ្វីដែលលោកលើកឡើងនេះ គឺជារឿងមួយមិនធម្មតានោះទេ វាខុសគ្នាទាំងស្រុងហើយ។ គូស្រករខ្លះហ្នឹងបានរាយការណ៍មកប្រាប់ខ្ញុំថា គេនៅក្នុងពិធីរៀបការរបស់ពួកគាត់ហ្នឹង មានការកាប់គោឲ្យស៊ីដែរ ប៉ុន្តែកម្រណាស់ កម្រមានអ្នកណាកាប់គោឲ្យស៊ីអ៊ីចឹងណាស់ អត់មានរឿង ថារាំរែក មាន

ធីកស៊ីអីទេ មិនមានទេ <គឺគ្រាន់តែដូចការប្រជុំមួយតែប៉ុណ្ណោះ>។

**ស៖** សូមអរគុណ។ ក្រោយពីគូស្រករដែលស្នើសុំហើយត្រូវបានគេអនុញ្ញាតហើយនៅក្នុងពិធីរៀបការនោះ តើចាប់ពីពេលរៀបការហើយ តើប្ដី និងប្រពន្ធហ្នឹង គេឲ្យរស់នៅជាមួយគ្នា រហូតទៅ ឬក៏យ៉ាងម៉េចក្រោយពេលរៀបការភ្លាមហើយ?

**ឆ៖** ចាស គឺថា ខ្មែរក្រហម គេឲ្យខ្ទមតូចៗមួយ សម្រាប់គូស្រករដែលរៀបការថ្មីដើម្បីឲ្យរស់នៅជាមួយ។ ខ្ញុំ ការសិក្សាស្រាវជ្រាវរបស់ខ្ញុំ គឺគេឲ្យនៅជាមួយគ្នាយូរបំផុត មួយអាទិត្យ។ បាទ បី--ហើយក្នុងអំឡុងពេលយប់គេឲ្យរស់នៅជាមួយគ្នា ក៏ប៉ុន្តែពេលថ្ងៃ ទៅធ្វើការតាមគោលដៅរៀងៗខ្លួន។ ហើយក្រោយពីមួយសប្ដាហ៍ទៅគឺថា ប្ដីប្រពន្ធហ្នឹងគឺត្រូវបំបែកពីគ្នា។ គឺថា ពួកគាត់ភាគច្រើនហ្នឹង គឺប្ដីរបស់គាត់គឺថាត្រូវឲ្យទៅធ្វើការនៅឆ្ងាយ រស់នៅឆ្ងាយ ទៅធ្វើពលកម្ម ធ្ងន់ធ្ងរនៅឆ្ងាយ ហើយប្រហែលជាបីខែ ហើយបើថាសំណាងល្អហ្នឹងគឺថា មួយខែអាចមកជួបប្រពន្ធបានម្ដង។

**ស៖** តើលោកស្រីអាចពន្យល់ជូនតុលាការបានទេ ថាគោលបំណងអ្វីដែរ ដែលគេផ្ដល់ខ្ទម ឬក៏កូនផ្ទះតូចឲ្យទៅប្ដីប្រពន្ធរៀបការថ្មីៗនេះ ស្នាក់នៅជាមួយគ្នាហ្នឹង <មួយសប្ដាហ៍>ហ្នឹង? ហេតុអីក៏ឲ្យជួបគ្នាតែរយៈពេលខ្លី ដឹងមូលហេតុអីបានជាគេឲ្យជម្រកនេះនៅទេ?

**ឆ៖** សំណួរនេះគួរឲ្យមានចំណាប់អារម្មណ៍ណាស់ ខ្ញុំអត់មានចម្លើយទៅនឹងសំណួររបស់លោកព្រះរាជអាជ្ញាទេ។

[១៣:៥៥:១១]

**ស៖** <តើជាការត្រឹមត្រូវទេក្នុងការនិយាយថា> ការសិក្សាស្រាវជ្រាវរបស់លោកស្រីទាក់ទងទៅនឹងការរៀបការក្នុងសម័យខ្មែរក្រហម រួមទាំង ក្នុងនោះរួមមានតាំងពី<ការសិក្សាស្រាវជ្រាវ>អំពើហិង្សាផ្លូវភេទផង។ នេះគឺជាវិធីសាស្ត្រមួយដែលអាចធ្វើឲ្យយើងវិភាគនៅឯកសារសេសសល់មកពីសម័យកាលខ្មែរក្រហម ឯកសារចេញពីមជ្ឈិមបក្ស ចេញពីមេដឹកនាំ ខ្មែរក្រហម។ តើការផ្ដោតរបស់លោកស្រីមានផ្ដោតទៅលើចំណុចទាំងអស់នេះដែរទេ?

**ឆ៖** ត្រឹមត្រូវហើយ។ ខ្ញុំចង់ប្រមូលចងក្រងសំឡេងរបស់ស្ត្រីដែលគាត់មិនធ្លាប់បានប្រាប់ឲ្យអ្នកណាដឹងទេ។ ខ្ញុំចង់ឲ្យស្ត្រីទាំងអស់ហ្នឹងមានអារម្មណ៍ថារឿងរ៉ាវរបស់គាត់នេះសំខាន់ណាស់ ហើយបើសរសេរទៅគឺថាអ្នកដទៃទៀតគេពេញចិត្ត ចូលចិត្តនឹងស្ដាប់ណាស់។ ខ្ញុំមិនបានយកមកពិចារណានូវឯកសារគោលនយោបាយរឿងអ្វី ដូចលោកសួរនោះទេ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោកស្រីលើកឡើងថាការរៀបការមានពីររបៀបគឺ៖ ១) អនុញ្ញាត ១) បង្ខំ។ យើងទើបនិយាយគ្នាអំពីការរៀបការដោយមានការអនុញ្ញាតក្រោយមានការស្នើសុំ។ ឥឡូវយើងចូលសួរអំពីការរៀបការដោយបង្ខំ។ តើលោកស្រីចង់និយាយដូចម្តេចពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ តើការរៀបការដោយបង្ខំវាខុសគ្នាពីការរៀបការដោយ អនុញ្ញាតដោយរបៀបណា? លោកស្រីបានឆ្លើយថា នៅក្នុងការរៀបការដោយៗស្នើសុំនេះ ស្ត្រីហ្នឹងគឺថាត្រូវតែបង្ខំចិត្តទទួល <>ដើម្បីស្ពានភាពជីវភាពរស់នៅ។ នេះពាក់ព័ន្ធទៅនឹងការរៀបការដែលបានស្នើសុំជាមុន។ ក៏ប៉ុន្តែចំពោះការរៀបការដោយបង្ខំ តើលោកស្រីចង់មានន័យដូចម្តេច ពាក្យដែលលោកស្រីប្រើការរៀបការដោយបង្ខំ? បាទ សូមរៀបរាប់សង្ខេបជូនតុលាការផងបានទេ?

[១៣:៥៧:៣៦]

**ឆ៖** ការរៀបការដោយបង្ខំដែលខ្ញុំកំណត់និយមន័យវានេះ គឺស្ត្រីមិនចង់រៀបការអ្វីទាំងអស់។ មានស្ត្រីដែលគាត់<ស្ម័គ្រចិត្ត>ចង់បានប្តី ហើយដែលអាចត្រូវបានខ្មែរក្រហម ឬឪពុកម្តាយ<ជាអ្នក>ជ្រើសរើស<ហើយគេទទួលយកការរៀបការនោះ>។ ហ្នឹងខ្ញុំហៅនេះខ្ញុំហៅថាជាៗគូស្រករដែលរៀបការដោយមានការអនុញ្ញាត។ <ពួកគេត្រៀមខ្លួនរួចហើយ ដើម្បីរៀបការជាមួយនរណាម្នាក់។> ក៏ប៉ុន្តែការរៀបការដោយបង្ខំនេះវិញ គឺអត់មានពាក់ព័ន្ធទៅនឹងឋានៈ សង្គម អាយុ ឬក៏អ្វីនោះទេ។ បើសិនណាជាអ្នកណាម្នាក់មិនចង់រៀបការ ក៏ប៉ុន្តែខ្មែរក្រហមបង្ខំឲ្យរៀបការ គឺខ្ញុំហៅថាជាការរៀបការដោយបង្ខំ។

**ស៖** លោកស្រីហៅថាជាការរៀបការដោយបង្ខំ ដោយសារតែភាគីម្ខាងមិនចង់រៀបការនោះទេ ឬក៏លោកស្រីវាថាជាការរៀបការដោយបង្ខំនៅពេលដែលប្តីនិងប្រពន្ធគូស្រករទាំងពីរមិនចង់ដូចគ្នា?

**ឆ៖** បើខ្ញុំមើលទៅកត្តារបស់បុគ្គលម្នាក់ៗ ឧទាហរណ៍ថាបើសិនណាបុរសណាម្នាក់ ខ្ញុំធ្លាប់ៗជួបបុរសម្នាក់គេបង្ខំឲ្យរៀបការដែរ។ គេបង្ខំឲ្យគាត់រៀបការទោះបីប្រពន្ធរបស់គាត់បានស្នើសុំខ្មែរ-ក្រហមរៀបការក៏ដោយ ហើយមានអតីតកងទ័ពខ្មែរក្រហមពិការដទៃទៀតហ្នឹង គឺថាពួកគាត់ចង់រៀប-ការជាមួយស្ត្រីដែលពួកគាត់ជ្រើសរើសដោយខ្លួនឯង ឬក៏ជាមួយស្ត្រីណាក៏បានឲ្យតែខ្មែរក្រហមជ្រើសរើសរៀបការឲ្យ។ ប៉ុន្តែជាមួយអតីតកងទ័ពហ្នឹង គឺកងនារីៗ គឺថាភាគច្រើនស្ទើរតែទាំងអស់ត្រូវបានគេបង្ខំ។ <ពួកគេមិនចង់រៀបការនោះទេ។>

[១៣:៥៩:៣៨]

**ស៖** លោកស្រីនិយាយ<អំពី>ការរៀបការដោយមានការអនុញ្ញាត ហើយគេមានការរៀបចំ

ពិធី និងរៀបចំពីដំណើរការនៃការរៀបការ។ បាទ ពាក់ព័ន្ធទៅនឹងពិធីរៀបការនេះ ឬលោកស្រីហៅថាជាអង្គប្រជុំ នោះ តើពិធីរៀបការរបស់អ្នកដែលគេរៀបការឲ្យដោយបង្ខំនោះ វាខុសគ្នាពិធីរៀបការជាមួយអ្នករៀបការដែលបានស្នើសុំអង្គការនោះឬក៏យ៉ាងណា <ឬមួយក៏ការរៀបការនោះមានចម្រុះគ្នា>?

**ឆ៖** ជាថ្មីម្តងទៀត ខ្ញុំមិនអាចនិយាយទូទៅទេ។ ប៉ុន្តែការដែលខ្ញុំសង្កេតឃើញគឺវាមានលក្ខណៈចម្រុះគ្នា គឺអ្នកខ្លះត្រូវបានគេបង្ខំ អ្នកខ្លះមិនត្រូវបានគេបង្ខំទេ។ ហើយអ្វីដែលខ្ញុំចាប់អារម្មណ៍នោះ ខ្ញុំមិនមានតួលេខច្បាស់ទេ។ ប៉ុន្តែយ៉ាងហោចណាស់នៅក្នុងឆ្នាំ១៩៧៧ ចុងឆ្នាំហ្នឹង ឬក៏ដើមឆ្នាំ១៩៧៨ មានការរៀបការរួមជាច្រើន ដែលត្រូវបានធ្វើឡើងរវាងក្រុមអ្នកដែលគេបង្ខំឲ្យរៀបការ។

**ស៖** សុំឲ្យឧទាហរណ៍អំពីពិធីរៀបការដោយបង្ខំណាមួយ ចាប់ពីពេលវេលាដែលបុរសនិងនារីត្រូវបានគេប្រាប់ថានឹងត្រូវរៀបការពីពេលវេលាហ្នឹង។ សុំឲ្យលោកស្រីអធិប្បាយដោយសង្ខេបទាក់ទងទៅនឹងពិធីគេរៀបការដែលជាការរៀបការដោយបង្ខំ។

**ឆ៖** គឺមានគំរូផ្សេងៗ ប៉ុន្តែពិធីដ៏ទូទៅជាងគេហ្នឹងគឺថា បុរសនិងស្ត្រីបានទទួលដំណឹងថា គេនឹងរៀបការឲ្យពួកគាត់ គឺថាដូចជាគេប្រាប់ពីព្រឹក ល្ងាចគេរៀបការ។ ឬក៏គេអាចប្រាប់មួយថ្ងៃមុន។ ពិធីរៀបការនោះត្រូវបានរៀបចំឡើង គឺជាពិសេសនៅពេលល្ងាច នៅថ្ងៃនោះឯង គឺជាការជូនដំណឹងខ្លីណាស់ គឺថាក្នុងរយៈពេល២៤តែប៉ុណ្ណឹងទេ។

[១៤:០១:៥៩]

**ស៖** ខ្ញុំអាននូវសេចក្តីស្រង់ចេញពីសៀវភៅរបស់លោកស្រី ទាក់ទងទៅនឹងគឺការ -- បាទ គឺទំព័រ២៧៧។ លោកប្រធាន ខ្ញុំសុំការអនុញ្ញាតនិងដកស្រង់ខ្លឹមសារដែលខ្ញុំនឹងអាននោះគឺថានៅ ឲ្យបញ្ចាំងលើអេក្រង់ទូរស្សន៍ផង ប្រហែលជាសេចក្តីដកស្រង់មួយឬពីរដែលខ្ញុំនឹងអានជូនអ្នកជំនាញស្តាប់ ហើយពេលដែលខ្ញុំសុំអាន សុំឲ្យបង្ហាញលើអេក្រង់ផង។ សុំការអនុញ្ញាត បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សូមអរគុណលោកប្រធាន គឺថា<ទំព័រលេខ ២៧៧> ឯកសារ E3/1 អង់គ្លេស សូន្យ គឺថា--

**អ្នកបកប្រែ៖**

លោកប្រធាន សុំអនុញ្ញាតឱ្យគាត់បញ្ជាក់លេខ ERN ម្តង។ អ្នកបកប្រែតាមមិនទាន់ បាទ។

**ប្រធានអង្គជំនុំ៖**

លោក១ព្រះរាជអាជ្ញា សុំបញ្ជាក់លេខ ERN ម្តងទៀត ដើម្បីសម្រួលដល់អ្នកបកប្រែ បាទ។

**សួរដោយលោក វីណ្ៀម ស្មីត៖**

**ស៖** សុំអភ័យទោសលោកប្រធាន 01322865 <មានតែ>ជាអង់គ្លេស។ បុគ្គលម្នាក់នេះ គឺមកពី នៅក្នុងខេត្តព្រះវិហារ គាត់ត្រូវបានគេបង្ខំឱ្យរៀបការ។ គាត់និយាយថា៖ "គេបង្ខំឱ្យខ្ញុំរៀបការនឹងបុរសម្នាក់<ដែលរស់នៅក្នុងភូមិផ្សេង>។ ខ្ញុំមិនដែលស្គាល់បុរសនោះពីមុនទេ។ ខ្ញុំពិបាកចិត្តណាស់ ខ្ញុំមិនចង់រៀបការជាមួយគាត់ទេ។ ពិធីរៀបការនោះ គេរៀបចំនៅក្នុងផ្ទះដែលមានដំបូល ហើយជាកន្លែងរបៀបដូចកន្លែងខ្មែរក្រហមប្រជុំ។ អ៊ីចឹង គឺថាមិនមានដូរ្យតន្ត្រីអ្វីទេ។ ឪពុកម្តាយរបស់ខ្ញុំមិននៅជាមួយខ្ញុំទេ។ អ្នកដែលវត្តមាននៅក្នុងទីនោះគឺសុទ្ធតែជាអ្នកត្រូវរៀបការ។ គឺមានបុរសស្ត្រី១០០នាក់ជាង។ គឺថាភាគច្រើនមិនដែលស្គាល់<គ្នា>ពីមុនទេ។ អ្នកទាំងនោះមានប្រជាជនចាស់និងប្រជាជនថ្មី។ ភ្លាម១នោះគឺមេដឹកនាំខ្មែរក្រហមក្រុមបុរស<បញ្ជាឱ្យបុរស១ទាំងអស់នៅក្នុងបន្ទប់នោះ> ជ្រើសរើសនារី<ដែលខ្លួនចង់បានជាដៃគូ>។ ហើយបុរស<ម្នាក់>បានចង្អុលមកខ្ញុំ ហើយ<ទាហានខ្មែរក្រហម>បានណែនាំឱ្យយើងធ្វើសម្បថ ឬក៏ប្តេជ្ញាចំពោះមុខអង្គការ គឺនៅក្នុងខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៦។ បន្ទាប់មកយើងក្លាយជាប្តីប្រពន្ធចាប់ពីថ្ងៃនោះមក។ នៅពេលនោះគូស្រកររាប់រយបាន ត្រូវបានរៀបការជាមួយគ្នា <ហើយហូបរួមគ្នាក្រោយពិធីរៀបការនោះ> ហើយមិនមានអ្នកណាម្នាក់បដិសេធការបញ្ជានោះទេ។ បើអ្នកណាបដិសេធ គេនឹងយកទៅសម្លាប់។ គឺជាអកុសលណាស់ម្តាយរបស់ខ្ញុំមិនបាននៅទីនោះជាមួយខ្ញុំទេនៅពេលដែលគេបង្ខំឱ្យខ្ញុំរៀបការនោះ។" សំណួរ តើហេតុការណ៍នេះ ដែលនារីម្នាក់ប្រាប់ទៅលោកស្រីនោះ គឺជា១ទម្រង់គំរូមួយដូចដែលអ្នកផ្តល់សម្ភាសផ្សេងទៀតឆ្លើយដែរឬទេ នៅពេលដែលសិក្សានោះ? ជាពិសេស គឺនិយាយអំពីមានការប្រជុំ មិនមានការជូនដំណឹងជាមុនទេ ហើយមានមនុស្សច្រើនណាស់ ដែលត្រូវរៀបការរួមជាមួយគ្នា។ តើនេះជាកាលៈទេសៈទូទៅដែលលោកស្រីបានរកឃើញបែបនេះទេ?

[១៤:០៥:៥០]

**ឆ៖** របៀបដែលគេរៀបចំការរៀបការនោះ គឺថាវាមានលក្ខណៈរួមបែបនេះឯង។ <ប៉ុន្តែ>

ស្ថានភាពមួយនេះ ដែលនិយាយថា មេក្រុមប្រុស<>ជាអ្នកបញ្ជា ឬណែនាំបុរសៗឲ្យជ្រើសរើសប្រពន្ធ។ នេះមិនជាលក្ខណ:ទូទៅទេ។ តាមធម្មតានៅក្នុងការរៀបការនោះ គឺថាដៃគូ ឬក៏ថាគូស្រករគេត្រូវផ្គូផ្គងរួចហើយ បានគេរៀបការ ប៉ុន្តែករណីនេះជាករណីពិសេស។

**ស៖** នៅក្នុងស្ថានភាពការរៀបការដោយបង្ខំនេះ ដែលអ្នកឆ្លើយនុំងប្រាប់លោកស្រីងហ្នឹង គឺថាគេអញ្ជើញពួកអ្នកទាំងអស់នោះទៅប្រជុំ ហើយគេបានជ្រើសរើសគូឲ្យហើយក្នុងករណីភាគច្រើន តើអ៊ីចឹងដែរឬទេ?

**ឆ៖** នោះត្រឹមត្រូវហើយ។ ទោះបីជានារីមិនបានដឹងថាអ្នកណាត្រូវជាប្តីរបស់គាត់នោះក៏ដោយ ប៉ុន្តែនៅពេលដែលគេធ្វើដំណើរទៅដល់កន្លែងរៀបការនោះ គេឲ្យអង្គុយមួយជួរ ស្រីមួយជួរ បុរសមួយជួរ។ ជាទូទៅ គឺថាបុរសដែលនៅចំ អង្គុយចំមុខនារីនោះឯង ជាប្តីដែលគេត្រូវរៀបការ។ គេរៀបចំទុកជាមុន <ឬក៏គេផ្តល់លេខសម្គាល់រួចហើយ ដូច្នេះបើមានមនុស្សច្រើន នោះគេមិនដឹងថាអ្នកណាជាប្តីនោះទេ។ ដូច្នេះ> គឺថាមេដឹកនាំខ្មែរក្រហម គឺបានផ្គូផ្គងរួចជាមុនហើយ។

**ស៖** តើលោកស្រីបានឮព្រឹត្តិការណ៍ ឬអង្គហេតុពីអ្នកផ្តល់បទសម្ភាសន៍ទេ ដែលថា អំពីការរៀបការរួម គឺថាមានមនុស្ស១០០នាក់ជាង ឬក៏២០០នាក់ជាងនៅក្នុងការប្រជុំមួយ? <ខ្ញុំចង់និយាយថានៅទីនេះ ស្ត្រីម្នាក់នេះបាននិយាយថា មានមនុស្សរាប់រយនាក់ដែលត្រូវរៀបការនោះ។> តើធ្លាប់មានសាក្សី ឬក៏អ្នកផ្តល់សម្ភាសណាមួយ គឺថាមានការរៀបការរួម ដែលមានចំនួនច្រើនប្រហាក់ប្រហែលនេះដែរឬទេ?

**ឆ៖** គឺថា ចំនួនច្រើនបំផុត ដែលខ្ញុំទទួលបានហ្នឹង គឺថាមាន៣០០នាក់ ប៉ុន្តែកម្រណាស់។ ប៉ុន្តែគឺភាគច្រើន គឺ<តិចជាង>៥០គូ។ គឺថានារីម្នាក់ដែលលោកបានដកស្រង់ហ្នឹង គាត់បានពន្យល់អំពីពិធីរៀបការគំរូមួយក្នុងរបបខ្មែរក្រហមហ្នឹង គឺវាអាចពីមួយថ្ងៃគេរៀបការពីរគូ ទៅប្រាំបីគូ ទៅតាមគេរៀបការក្នុងអង្គភាពរបស់គេ។

[១៤:០៨:៤៦]

**ស៖** តើបុរស និងស្ត្រីហ្នឹង អាចបដិសេធការបញ្ជាឲ្យគេរៀបការដែរឬទេ?

**ឆ៖** ក៏ដូចគ្នាដែរ គឺវាមានករណីខុសៗគ្នាច្រើន គឺថាវាមានឱកាសច្រើនដែរ គឺថាគេអាចបដិសេធបានច្រើនពេល។ គេអាចបដិសេធ ហើយអាចចៀសផុតពីការរៀបការ ប៉ុន្តែភាគច្រើន ជាពិសេសក្នុងឆ្នាំ១៩៧៧-១៩៧៨ នៅពេលដែលប្រជាជននោះត្រូវបានបំភិតបំភ័យ ដោយខ្មែរក្រហមថា

កាលណាការបដិសេធ អាចនឹងមានន័យថា គេនឹងត្រូវសម្លាប់អ្នកណាដែលបដិសេធមិនព្រមរៀបការ។ អ៊ីចឹងហើយមនុស្សភាគច្រើនហ្នឹងគឺមិនហ៊ានបដិសេធទេ។ ប៉ុន្តែតាមការពិត គឺថាមានករណីដែលថា គេអាចបដិសេធ មនុស្សមួយចំនួនតូចបានបដិសេធ។

**ស៖** តើមានលទ្ធភាពក្នុងការបដិសេធមិនព្រមរៀបការដែរឬទេ? តើវាមានករណីហ្នឹង គ្រប់តំបន់ ឬក៏តំបន់ភូមិភាគណាមួយដែលលោកស្រីបានដឹង? តើមានទីតាំងណាមួយ គេអាចមានជម្រើសបដិសេធ ឬទីតាំងផ្សេងមិនអាច ឬមានករណីយ៉ាងដូចម្តេច?

**ឆ៖** បើខ្ញុំចាំមិនខុសទេ ខ្ញុំបានឮពេលលទ្ធភាពបែបនេះ គឺថាស្ទើរតែគ្រប់កន្លែងដែលខ្ញុំបានចុះទៅដល់នោះ ចុះទៅសម្ភាសន៍។

**ស៖** តើលោកស្រីធ្លាប់បានឮពីពាក្យសម្តី ពីសាក្សីដែលថា ពួកគេមិនអាចបដិសេធមិនព្រមរៀបការបានទេ? <ដូច្នេះតើលោកស្រីបានស្តាប់រឿងរ៉ាវពីរផ្សេងគ្នាទេ>? អ៊ីចឹងខ្ញុំសុំអានសេចក្តីដកស្រង់ចេញមកពីសៀវភៅរបស់លោកស្រី ឯកសារ E3/10655, គឺអង់គ្លេស <01322864><អត់មានភាសាខ្មែរ និងភាសាបារាំងទេ>។ បាទ គឺជាស្ត្រីពោះម៉ាយដែលគេគំរាមថានឹងសម្លាប់បើមិនព្រមរៀបការ។ គាត់បាននិយាយថា -- ជាសៀវភៅធំមួយទំព័រ២៧៦៖ "នៅពេលដែលកូនប្រុសរបស់ខ្ញុំអាយុ១ឆ្នាំ គេបានបង្ខំ<ខ្ញុំ>ឲ្យរៀបការជាមួយខ្មែរក្រហម។ ខ្ញុំមិនចង់រៀបការទេ។ ខ្ញុំអាច ខ្ញុំភ័យខ្លាចប្តី<ដែលខ្ញុំនឹងរៀបការជាមួយនោះធ្វើបាប>កូន<របស់ខ្ញុំដែលមានជាមួយប្តីមុន> ហើយខ្ញុំបានបដិសេធ។ <នៅពេលព្រឹក គេប្រាប់ខ្ញុំថា ខ្ញុំត្រូវរៀបការ។> ពេលនោះ គឺមេភូមិមកនិយាយជាមួយខ្ញុំ គាត់និយាយថា បើអ្នកឯងមិនព្រមរៀបការជាមួយបុរសនេះទេ គេនឹងសម្លាប់អ្នកឯង។ ដូច្នេះហើយ មិនមានជម្រើសអ្វីទេ ខ្ញុំត្រូវតែរៀបការជាមួយបុរសនោះ។ ខ្ញុំរៀបការជាមួយគាត់ពេលល្ងាចនៅថ្ងៃដដែល ពេលដែលគេបញ្ជាខ្ញុំនោះឯង។ ហើយៗខ្ញុំមិនចាត់ទុកគាត់ថាជាប្តីទេ។ ខ្ញុំមិននិយាយជាមួយគាត់ទេ។ ខ្ញុំមិនមានអារម្មណ៍អ្វីជាមួយគាត់ទេបន្ទាប់ពីរៀបការ។ ហើយគេបានបញ្ជូនគាត់ទៅកន្លែងឆ្ងាយក្រោយរៀបការ <យើងមិនបាននៅជាមួយគ្នាទេ>។<ប្រហែលជាបី>ខែម្តងតែប៉ុណ្ណោះ<គាត់ត្រឡប់មកជួបខ្ញុំ>។"

សំណួរ ថាតើការគំរាមកំហែងដើម្បីសម្លាប់ ដែលស្ត្រីម្នាក់នេះនិយាយនោះ ជាលក្ខណៈរួមទូទៅដែលលោកស្រីបានឮពីសាក្សីផ្សេងៗទៀតដែរឬទេ ពាក់ព័ន្ធទៅនឹងជម្រើសក្នុងការឆ្លើយតប ទៅនឹងការគំរាមកំហែងឲ្យរៀបការ ឬក៏ជាឧទាហរណ៍ដែលកម្រទេ?

[១៤:១២:៥៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆៈ** មានគំរូពីរ។ មួយ គឺថាខ្មែរក្រហម ឬក៏មេភូមិនិយាយច្បាស់ៗបែបនោះថា គេនឹងសម្លាប់អ្នកដែលគេបង្ខំ ឬសមាជិកក្រុមគ្រួសារនឹង<ត្រូវគេសម្លាប់បើសិនជាពួកគេបដិសេធ>។ ប៉ុន្តែវាមិនជារឿងទូទៅទេ ខ្ញុំមិនអាចនឹងបង្រួមបញ្ហានេះឲ្យតូចបានទេ។ ប៉ុន្តែសំខាន់ជាងហ្នឹងទៅទៀត គឺគំរូមួយទៀត មនុស្សហ្នឹងគឺត្រូវបានទទួលការបំភិតបំភ័យរួចហើយ ពីព្រោះគេរស់នៅក្នុងការភ័យខ្លាចខ្លាំង ក្នុងករណីដែលគេដឹងថា បើអ្នកណាហ៊ានប្រឆាំងនឹងខ្មែរក្រហមគេនឹងត្រូវសម្លាប់។ គឺថាមានសម្ពាធសម្ងាត់ សម្ពាធដ៏ស្ងប់ស្ងាត់មួយក្នុងសង្គម <ដែលពួកគេមិនគួរឆ្លើយ>បដិសេធ<ទេ>។

**សៈ** នៅក្នុងរបាយការណ៍របស់លោកស្រីនេះ គឺថាស្ត្រីត្រូវបានគេរំលោភដោយហេតុថា ពួកគេបដិសេធមិនព្រមរៀបការ។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** នៅក្នុងការសិក្សាដំបូងរបស់ខ្ញុំ ខ្ញុំបានឮរឿងបែបនេះ ហើយខ្ញុំក៏មានស្ត្រីម្នាក់ដែលត្រូវធ្វើគេបង្គាប់ឲ្យទៅមើលការរំលោភស្រីម្នាក់ទៀត ដែលគេបង្ខំឲ្យរៀបការហើយ គាត់បដិសេធ។

[១៤:១៤:២១]

**សៈ** ខ្ញុំនឹងអានចំណុចមួយទៀត នៅសៀវភៅទី១ គឺឯកសារ E3/2959, អង់គ្លេស 00421893, ជាភាសាខ្មែរ 00738347 ហើយនិងបារាំង 00701496។ ស្ត្រីម្នាក់នេះគាត់និយាយថា ប្តីរបស់គាត់បានស្លាប់ ហើយ<គេបានបញ្ជាឲ្យ>គាត់<>រៀបការ ហើយគាត់<និយាយថា៖ "ប្តីខ្ញុំ>គឺជាទាហាន<បារាំង។> គេចង បាទ គេសម្លាប់គាត់។ ក្រោយ <ប្រាំ>ខែក្រោយមក គេបង្ខំឲ្យខ្ញុំរៀបការហើយគេបាន -- ខ្ញុំបដិសេធ គេយកខ្ញុំទៅក្នុងព្រៃ ហើយគេរំលោភ<ខ្ញុំ ហើយខ្ញុំបាននិយាយទៅពួកគេថា>សម្លាប់<ខ្ញុំទៅ> កូន<>ខ្ញុំ<ប្រាំមួយ>នាក់<>បានស្លាប់ទៅហើយ <ដូច្នេះសូម>អ្នកឯងជីករណ្តៅកប់ខ្ញុំជាមួយ<កូនប្អូននាក់ដែលនៅរស់នេះ>ទៅ។ <>ខ្ញុំ<មិនព្រម>រៀបការនោះ<ទេ>។ ឥឡូវនេះ ខ្ញុំស្ទើរឆ្កួតហើយ។" តើលោកស្រីបានឮករណីបែបនេះ ផ្សេងទៀតដែរឬទេ?

**ឆៈ** ខ្ញុំមិនចាំការសន្ទនាជាមួយគាត់នេះទេ។

**សៈ** ជាមួយបទសម្ភាសន៍ ហើយនិងសេចក្តីដកស្រង់នៅក្នុងរបាយការណ៍ទាំងបីនេះ តើបទសម្ភាសន៍ទាំងអស់នោះលោកស្រីធ្វើខ្លួនឯង ឬក៏<បទសម្ភាសន៍ខ្លះធ្វើឡើងដោយអ្នកស្រាវជ្រាវផ្សេងទៀត>ដែលធ្វើការជាមួយលោកស្រី?

[១៤:១៦:១១]

**ឆៈ** ការសិក្សាស្រាវជ្រាវទី១របស់ខ្ញុំនោះ ដែលខ្ញុំជូនដំណឹងទៅតុលាការព្រឹកមិញនេះ ខ្ញុំបានធ្វើ

ដោយខ្លួនឯង ហើយនិងសហសេវិកខ្ញុំម្នាក់។ អ៊ីចឹងមានគ្នាពីរនាក់។ រីឯសៀវភៅមួយទៀត ដែលថា "ភាពជាម្ដាយក្នុងសម័យសង្គ្រាម" នោះគឺថា ផ្នែកមួយចំនួន គឺខ្ញុំជាអ្នកសម្ភាស ហើយមួយផ្នែកទៀតគឺកូនសិស្សខ្ញុំជាអ្នកសម្ភាស។ ហើយសៀវភៅរបស់ខ្ញុំមួយទៀត និយាយអំពីអំពើហិង្សាផ្លូវ<ភេទប្រឆាំងនឹងជនជាតិភាគតិច>នៅក្នុងសម័យខ្មែរក្រហម<ដែលខ្ញុំបាននិយាយអំពីការបង្ខំឲ្យរៀបការដែរ>នោះ<គឺ>ខ្ញុំ<ជាអ្នកធ្វើ>បទសម្ភាសន៍<ទាំងអស់នោះដោយផ្ទាល់>។

**ស៖** តើលោកស្រីធ្លាប់បានឮរឿងរ៉ាវអំពីមនុស្សដែលថាគេបង្ខំឲ្យរៀបការ គេបដិសេធ ហើយគេបញ្ជូនឲ្យទៅធ្វើការធ្ងន់ ឬក៏គេបញ្ជូនទៅដាក់ឃុំខ្លួន ឬដាក់គុកដែរឬទេ?

[១៤:១៧:២០]

**ឆ៖** ចាស ខ្ញុំ<បានស្ដាប់>រឿងជាច្រើនអំពីការដាក់ទណ្ឌកម្ម ការដាក់ទោសចំពោះអ្នកដែលបដិសេធមិនព្រមរៀបការនោះ។ ករណីមួយគឺខ្ញុំមាននារីម្នាក់នៅរតនគិរី គាត់នៅក្នុងកងកុមារ គឺគាត់អាយុ១៥ឆ្នាំ គេបង្ខំឲ្យគាត់រៀបការ គឺនៅចុងឆ្នាំ១៩៧៨ គឺក្នុងរវាងឆ្នាំ១៩៧៨។ នាងនៅតូចពេក គឺអាយុតែ១៥ នាងបដិសេធ។ ហើយគេក៏បានបញ្ជូននាងទៅមន្ទីរអប់រំបីខែ បន្ទាប់មកវៀតណាមក៏បានចូលស្រុក -- ចូលកម្ពុជា។ ហើយអ៊ីចឹងគឺថា សៀវភៅមួយទៀតនៅក្នុង -- ដែលមានចំណងជើងថា "ភាពជាម្ដាយនៅក្នុងសម័យសង្គ្រាម"ហ្នឹង ខ្ញុំនឹកឃើញនារីម្នាក់នៅសៀមរាបដែលប្រាប់ខ្ញុំថា គេបញ្ជូនគាត់ទៅៗមន្ទីរអប់រំកែប្រែ ដោយសារគាត់បដិសេធមិនព្រមរៀបការ។

**ស៖** ពាក់ព័ន្ធទៅនឹងរឿងរ៉ាវដែលលោកស្រីបាននិយាយយោងទៅដល់នោះ តើលោកស្រីគិតថាអាជ្ញាធរខ្មែរក្រហមបានទៅជួបបុរសនិងស្ត្រី ហើយណែនាំ ឬក៏បញ្ជាឲ្យពួកគេរៀបការដែរឬទេ? តើលោកស្រីគិតថាព័ត៌មានដែលលោកស្រីបានទទួលពីមនុស្សដែលផ្ដល់បទសម្ភាសន៍នោះ។ តើពួកគេមានលទ្ធភាពក្នុងការផ្ដល់ការយល់ព្រមដោយចិត្តរបស់គេទាំងស្រុងទៅនឹងការរៀបការហ្នឹងដែរឬទេ ដោយស្មោះត្រង់ទេ?

[១៤:១៩:០៨]

**ឆ៖** ករណីមួយៗគឺវាអាស្រ័យទៅនឹងទីតាំង គឺថ្នាក់ដឹកនាំអាជ្ញាធរនៅតាមមូលដ្ឋាននីមួយៗ<ហើយនិងឆ្នាំ នេះតាមការយល់ឃើញរបស់ខ្ញុំ>។ នៅក្នុងតំបន់ខ្លះ អ្វីដែលយើងមើលឃើញហ្នឹងគឺថាមេភូមិខ្លះគឺៗមានការអាណិតអាសូរគួរសមដែរ។ <ដូច្នេះទោះបីជា>គេបង្ខំឲ្យ ឬក៏បញ្ជូនទៅឲ្យធ្វើការពលកម្មធ្ងន់ក៏ដោយ គឺវាអាស្រ័យទៅលើចិត្ត សមានចិត្តរបស់មេភូមិ។ ហើយ<នៅក្នុងស្ថានភាពបែប

នោះ>គឺថា<គេអាចប៉ាន់ស្មានសួរនាំ ឬក៏>បដិសេធ<>សំណើ<បាន>។ ប៉ុន្តែក្នុងករណីតំបន់ខ្លះ ភូមិផ្សេងទៀតហ្នឹងគឺថា ដែលមានភាពតឹងតែងហ្នឹងគឺថា ជីវិតរបស់ប្រជាជនហ្នឹង គឺស្ថិតនៅក្នុងការភ័យរន្ធត់។ អ៊ីចឹងហើយ គឺគេដឹង គឺថា គេថា គេពិបាកនឹងបដិសេធនឹងឆ្លើយថា "ទេ"។

**ស៖** និយាយដោយសង្ខេបនៅពេលដែលពិភាក្សាអំពីការធ្វើបទសម្ភាសន៍ជាមួយមនុស្ស ដែលផ្តល់ភស្តុតាងមកឲ្យលោកស្រីទាក់ទងទៅនឹងការរៀបការដោយបង្ខំនេះ តើមនុស្សដែលនិយាយថា ពួកគេមានការភ័យរន្ធត់ មានការភ័យខ្លាច ហើយគេមិនអាចនិយាយបដិសេធ មិនព្រមរៀបការ ឬក៏មិនប៉ានប្រឆាំងនឹងបញ្ជាឲ្យរៀបការ។ អ៊ីចឹងក្នុងករណីដែលមនុស្ស អ្នកនោះឆ្លើយ តើអ្នកហ្នឹងរស់នៅក្នុងតំបន់ផ្សេងៗគ្នានៅទូទាំងប្រទេស ឬមួយក៏យ៉ាងដូចម្តេច?

[១៤:២០:៥៥]

**ឆ៖** នៅក្នុងការស្រាវជ្រាវរបស់ខ្ញុំមិនស្ថិតនៅក្នុងតែការរៀបការដោយបង្ខំតែមួយទេ គឺវាមានវិសាលភាពទូលំទូលាយ គឺនិយាយពីស្ត្រីនៅក្នុងរបបខ្មែរក្រហម។ ភាគច្រើន គឺស្ត្រីមានការភ័យខ្លាច ហើយពួកគាត់មានការព្រួយបារម្ភខ្លាំងណាស់នៅក្នុងរបបខ្មែរក្រហម។ ហើយកម្រិតនៃការភ័យខ្លាចហ្នឹង គឺវាខុសគ្នាពីមួយកន្លែងទៅមួយកន្លែង។ ហើយក៏អាចពីខេត្តមួយទៅខេត្តមួយដែរ យើងមិនអាចនិយាយថាដូចគ្នាទាំងអស់ទេ។ ចំពោះតំបន់ទាំងអស់ដែលខ្ញុំបានចុះដល់នោះ គឺថា នារីទាំងនោះ គឺធ្លាប់បានស្ថិតនៅក្នុងការភ័យខ្លាច។

**ស៖** សូមអរគុណ។ ប្រហែលនៅពេលនេះ មុននឹងយើងចូលទៅអ្វីដែលកើតឡើងបន្ទាប់ពីពិធីរៀបការនោះ គឺលោកស្រីបានបញ្ជាក់ថា ចំពោះការរៀបការដែលមេដឹកនាំគេអនុញ្ញាតនោះ ក្រោយពីរៀបការគេឲ្យនៅក្នុងផ្ទះមួយ គេឲ្យរស់នៅពីមួយថ្ងៃ ទៅមួយអាទិត្យ បានឲ្យបែកគ្នា។ ចុះចំពោះមនុស្សដែលគេបង្ខំឲ្យរៀបការវិញ តើលោកស្រីបានទទួលរឿងរ៉ាវ ឬក៏ដំណឹងអ្វី ឬក៏ពីករណីដែលថាគេបង្ខំឲ្យរួមដំណេកដែរឬទេ ក្រោយពីរៀបការ?

**ឆ៖** ចំពោះបុរស និង ស្ត្រី ដែលគេអនុញ្ញាតឲ្យរៀបការនោះ ខ្ញុំមិនមានរូបភាពច្បាស់លាស់ ថាគេណែនាំឲ្យធ្វើដូចម្តេចនោះទេ។ ប៉ុន្តែចំពោះមនុស្សដែលត្រូវបានគេបង្ខំឲ្យរៀបការហ្នឹង គឺដូចគ្នានឹងអ្នកផ្សេងទៀតដែរ។ គេរៀបចំផ្ទះតូចៗសម្រាប់ប្តីប្រពន្ធមួយៗឲ្យនៅមួយយប់ <ឬក៏ជាច្រើន>យប់ <ជាមួយគ្នា>។ គេណែនាំឲ្យនៅជាមួយគ្នា នៅក្នុងផ្ទះទាំងនោះ។ ហើយ អ៊ីចឹងហើយគឺថា អាចជាពិធីមួយដែលគេណែនាំឲ្យរួមដំណេក ក្រោយពីរៀបការ។

[១៤:២៣:១៦]

**ស៖** នៅពេលដែលនិយាយជាមួយសាក្សីហ្នឹង តើធ្លាប់ជួបករណី ប្រសិនបើករណីថា គេមិនព្រមរួមដំណេក បើមិនធ្វើអ៊ីចឹងគេមានការភ័យខ្លាច។ តើមានកត្តាអីដែលនាំឱ្យគេភ័យខ្លាចទេ?

**ឆ៖** ចាស ទាំងបុរសនិងស្ត្រី គេឆ្លើយថា គេមិនចង់រួមដំណេកទេ។ មិនទាំងអស់ទេ ប៉ុន្តែអ្នកខ្លះ គេនិយាយច្បាស់ថា គេមិនចង់ធ្វើបែបនោះទេ។ ប៉ុន្តែគេត្រូវតែធ្វើ ដើម្បីឱ្យបាននៅរស់។

**ស៖** ខ្ញុំអានចេញពីសៀវភៅរបស់លោកស្រី គឺE3/2959 គឺអង់គ្លេស <00421892> គឺខ្មែរ <00738345>, បារាំង 00701495 បទសម្ភាសន៍ហ្នឹងបានធ្វើឡើង គឺក្នុងទំព័រ៨៩ គឺស្ត្រីត្រូវបានប្ដីវាយបន្ទាប់ពីមិនព្រមរួមដំណេកក្រោយពីរៀបការ។ <គាត់និយាយថា៖> "ប្ដីទី២ គឺជាប្រជាជនថ្មី។ ថ្ងៃទី១ បន្ទាប់ពីរៀបការ គេបាន-- គាត់បានវ៉ៃខ្ញុំ ពីព្រោះខ្ញុំមិនស្រឡាញ់គាត់ ហើយមិនព្រមរួមដំណេកជាមួយគាត់។ គាត់បានវាយខ្ញុំ គាត់វាយចំភ្លៅខ្ញុំ ហើយដោយប្រើដៃ ហើយខ្ញុំមិនអាចទប់ទល់បានដោយហើយក៏បង្ខំឱ្យខ្ញុំឱ្យរួមភេទជាមួយគាត់។" អ៊ីចឹងគឺថាក្នុងករណីនេះ ចំពោះប្ដីដែលវាយប្រពន្ធ(ប្រពន្ធថ្មីរបស់គាត់) គឺបើសិនជាគេមិនព្រមរួមភេទបែបនេះ តើជារឿងដាច់ដោយឡែក ឬក៏ជារឿងមានករណីច្រើនដែរ?

[១៤:២៥:៣៤]

**ឆ៖** ខ្ញុំមានការលំបាកណាស់ក្នុងការឆ្លើយនៅសំណួរនេះ គឺវាអាស្រ័យទៅលើ<បុគ្គលម្នាក់>ៗ។ បើតាមខ្ញុំពិនិត្យឃើញគឺថា បុរសខ្លះប្រើអំពើហិង្សា ហើយក៏អាចថាបុរសនោះក៏មានការភ័យខ្លាចថាគេ គេក៏ត្រូវតែរួមដំណេក ហើយត្រូវប្រើអំពើហិង្សាប្រឆាំងនឹងប្រពន្ធ ហើយខ្ញុំក៏បានជួបនឹងបុរសដែលៗមានការភ័យខ្លាច ហើយក៏មិនអាចរួមដំណេកនោះដែរ។ ដោយហេតុថាបុរសភាគច្រើនគឺ បើសិនជាគេបង្ខំឱ្យគាត់រៀបការ ពួកគេៗត្រូវបានដកចេញនឹងភាពជាបុរស គេមិនអាចសម្រេចលើជីវិតអាពាហ៍ពិពាហ៍ទេ។ <នៅថ្ងៃទី១ គាត់>ត្រូវបាន<គេ>បង្ខំឱ្យ<មើល>ប្រពន្ធ<គាត់ ដែលគាត់ត្រូវជួយឧបត្ថម្ភ> ការពារ<តាមប្រពៃណីខ្មែរ>។ <ខ្មែរក្រហមមិនអាចបំបាត់គំនិតរាក់កំផែលអំពីភាពជា>បុរស<ក្នុងចំណោម>បុរស<ខ្មែរនោះបានទេ។> ហើយបុរសបែបនៅក្នុងករណីនោះ ហើយក៏គេព្យាយាមយកចិត្តទុកដាក់ប្រពន្ធឱ្យបានល្អ <គេចង់ឱ្យប្រពន្ធគេស្រឡាញ់គេ ហើយពួកគេជាអ្នកខាតបង់។> ហើយៗពេលខ្លះពួកគេមិនដឹងថាត្រូវធ្វើដូចម្ដេចចំពោះប្រពន្ធដែលភ័យខ្លាចហើយបដិសេធមិនព្រមរួមដំណេកនោះ។ ហើយនៅក្នុងរឿងរ៉ាវបែបនេះ ប៉ុន្តែមានរឿងរ៉ាវច្រើន ប៉ុន្តែមិនមែនបុរសទាំង

អស់ដែលធ្វើអំពើបែបនេះទេ ប៉ុន្តែវាជាករណីកម្រដែលមិនជាទូទៅទេ។

**ស៖** គូស្រករដែលត្រូវបានគេបង្ខំឱ្យរៀបការ តើលោកស្រីបានឮរឿងរ៉ាវពីសាក្សីថាគេនឹងតាមដានជាពិសេសដោយអាជ្ញាធរមូលដ្ឋាន ដើម្បីតាមដានមើលថាតើប្តីប្រពន្ធហ្នឹងរួមដំណេកដែរ ឬអត់ក្រោយពីរៀបការហ្នឹង?

**ឆ៖** ចាស ខ្ញុំមានរឿងរ៉ាវបែបនោះ។ ជាពិសេសគឺមនុស្សដែលត្រូវបានគេបង្ខំឱ្យរៀបការប្រឆាំងនឹងឆន្ទៈរបស់គេ។

[១៤:២៨:១១]

**ស៖** តើរឿងរ៉ាវនោះត្រូវបាន ដែលថាគេតាមដាននឹងដើម្បីធានាថាគេពិតជាបានរួមដំណេកទេថាតើរឿងហ្នឹងជារឿងទូទៅ ឬក៏ជាករណីកម្រ?

**ឆ៖** ខ្ញុំមានរឿងរ៉ាវច្រើន ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់ថាវាទូទៅទាំងអស់ទេ ប៉ុន្តែវាអាចនឹងជាករណីទូទៅបែបហ្នឹង។

**ស៖** បាទ ជាលទ្ធផលនៃការបង្ខំឱ្យគូស្រកររៀបការនោះ តើលោកស្រីបានឮរឿងហេតុ ឬក៏ករណីដែល<>ស្ត្រីមានផ្ទៃពោះ <ដោយសារការបង្ខំឱ្យរៀបការនោះ> គឺថាគេចំពោះករណីដែលថាស្ត្រីគាត់មានផ្ទៃពោះ គាត់ចង់រំលូតកូនអីជាដើម តើធ្លាប់ជួបករណីហ្នឹងដែរឬទេ?

**ឆ៖** គឺថាស្ត្រីមួយចំនួនច្រើន បានមានផ្ទៃពោះនៅក្នុងរបបខ្មែរក្រហម ខ្លះគឺកើតមកពី -- ជាលទ្ធផលនៃការរៀបការដោយបង្ខំ ប៉ុន្តែជាគោលការណ៍ស្ត្រីដែលខ្ញុំជួបហ្នឹងគឺថា ស្ត្រីភាគច្រើនឬក៏សឹងតែទាំងអស់មិនចង់មានផ្ទៃពោះទេនៅក្នុងសម័យនោះ។ ចំពោះស្ត្រីដែលត្រូវបានបង្ខំឱ្យរៀបការ ឬក៏ត្រូវបានគេអនុញ្ញាតឱ្យរៀបការ ឬដោយស្ម័គ្រចិត្តក៏ដោយ គឺមានគំនិតប្រហាក់ប្រហែលគ្នាហ្នឹង។ ប៉ុន្តែអ្វីដែលខ្ញុំបានឮចំពោះស្ត្រីដែលបានត្រូវគេបង្ខំឱ្យរៀបការហ្នឹងគឺថា ហើយក៏មានផ្ទៃពោះបន្ទាប់ពីការរៀបការហ្នឹង គឺថាអ្នកទាំងនោះគឺឈឺចាប់ខ្លាំងជាង គឺមានការបាក់ទឹកចិត្តខ្ពស់ជាងអ្នកផ្សេងទៀតដែលមានផ្ទៃពោះក្នុងពេលនោះ។

**ស៖** ហើយខ្ញុំសុំអានសេចក្តីដកស្រង់ខ្លីមកនៅក្នុងសៀវភៅទំព័រ២៨៩ គឺឯកសារ E3/10655 គឺថាភាសាអង់គ្លេស 01322877 គឺ៖ ស្ត្រី<ម្នាក់នេះនិយាយអំពីការ>រំលូតកូន <ក្រោយពី>គេបង្ខំឱ្យរៀបការ<ជាមួយបុរសម្នាក់ នៅពេលដែលសុបិនរបស់គាត់ចង់ក្លាយជាដុកទ័រ បានរលាយអស់ទៅ>។ ប្រហែលជាស្ត្រីម្នាក់ដែលលោកស្រីយោងទៅរកខាងដើមនេះឯង។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:៣០:៥៣]

ហើយគាត់និយាយថា៖ “នៅពេលដែលខ្ញុំមានផ្ទៃពោះ ខ្ញុំចង់រំលូតកូន។ <វាពិតជា>លំបាកណាស់<សម្រាប់ខ្ញុំ ដែលមានផ្ទៃពោះនៅពេលនោះ។ សូម្បីតែក្រោយពេលទារកមួយចំនួនបានកើតមកហើយ>ក៏ដោយ គឺជីវិតរបស់គេគឺវេទនាណាស់។ គេអាចរស់នៅជាមួយយាយៗ <ដែលបញ្ចុកអាហារ<>ពួកគេ<ដោយទំពារបាយលាយជាមួយស្ពាម្លូ>។ ខ្ញុំមិនចង់ឃើញ<>បែបនោះទេ។ <ទារកទាំងនោះឈឺច្រើនណាស់។> ហើយខ្ញុំក៏អាចនឹងមានការទុក្ខសោកចំពោះកូនរបស់ខ្ញុំដែលខ្ញុំមិនចង់ឲ្យកូននេះកើតទេ។ ដូច្នេះហើយវាល្អ គួរតែមិនមានកូនទេ ពីព្រោះយ៉ាងណាក៏ដោយ ខ្ញុំមិនអាចបញ្ឈប់ការមានផ្ទៃពោះរបស់ខ្ញុំបានទេ។ <យើងអត់មានមធ្យោបាយណាដើម្បី>រំលូតកូននៅក្នុងសង្គ្រាម<ទេ>។” អ៊ីចឹងសំណួរថា បើនារីស្ត្រីចង់រំលូតកូនវិញ តើលោកស្រីបានឮប្រវត្តិរឿងរបស់ផ្សេងទៀតដែរទេ ដែលគេបង្ខំឲ្យរៀបការហើយ ហើយក៏គាត់បានគិត បើមានផ្ទៃពោះ គាត់គិតពីរៀបវិធីរំលូតកូនហ្នឹងដែរឬទេ?

**ឆ៖** ដោយហេតុថាការរំលូតកូន<ជាបញ្ហាមួយមិនត្រូវនិយាយក្នុងចំណោមប្រជាជនកម្ពុជា> ដោយសារ<>វាផ្ទុយហ្នឹងសាសនា និងប្រពៃណីរបស់គេ គេដំណម <ដូច្នេះខ្ញុំមិនជឿថា មានស្ត្រីណា> និយាយ<ពីរឿងនេះដោយចំហជាមួយខ្ញុំនោះ>ទេ។ <>ប៉ុន្តែ<នៅក្នុងការស្រាវជ្រាវរបស់ខ្ញុំ> ខ្ញុំតែងតែសួរស្ត្រីទាំងនោះថា តើមានពេលណាមួយ ពួកគាត់ចង់រំលូតកូនដែរទេ ពេលដែលមានផ្ទៃពោះនៅក្នុងសម័យខ្មែរក្រហម? ភាគច្រើនអ្នកទាំងអស់នោះនិយាយថា ពួកគេចង់រំលូតកូន បន្ទាប់ពីរៀបការដោយបង្ខំនោះ។ អ៊ីចឹងខ្ញុំគិតថា ស្ត្រីម្នាក់ដែលខ្ញុំបានជួបហ្នឹងគឺថា គាត់មានទុក្ខព្រួយខ្លាំងណាស់ ពេលដែលគាត់មានកូន ពីព្រោះគាត់មិនស្រឡាញ់ប្ដីគាត់សោះ។

[១៤:៣៣:០២]

**ស៖** តើលោកស្រីបានជួបមនុស្សភាគច្រើនដែលត្រូវបានគេបង្ខំឲ្យរៀបការ ហើយនៅជាប្ដីប្រពន្ធជាមួយគ្នាទេ ក្រោយពីសម័យខ្មែរក្រហមហ្នឹង? ហើយបើសិនជាគេនៅជុំប្ដីប្រពន្ធ តើគេពន្យល់ពីមូលហេតុដែរឬទេ ថាហេតុអ្វីគេបន្តនៅជាមួយគ្នានោះ <បើការរៀបការនោះមិនមែនជាជម្រើសរបស់ពួកគេផង>?

**ឆ៖** ចាស ខ្ញុំបានសួរសំណួរនេះទៅពួកគេ។ ភាគច្រើននៃអ្នកទាំងនោះ គិតថា ពួកគេបានរៀបការរួចហើយ ទោះបីដោយមូលហេតុអ្វីក៏ដោយ ពួកគេគួរតែបន្តរស់នៅជាមួយគ្នា។ នេះហើយគឺជាពាក្យចុងក្រោយ។ ប៉ុន្តែបើខ្ញុំស្ដាប់សំឡេងរបស់ស្ត្រីវិញ ស្ត្រីភាគច្រើនគាត់និយាយថា គេសម្រេចចិត្តនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាមួយប្តីទោះបីចូលចិត្ត បាទ ដូចថាគេចូលចិត្តដោយសារប្តីហ្នឹងជាអ្នកផ្គត់ផ្គង់ខាងអាហារ ស្បៀងអាហារ។ ចំពោះក្នុងសង្គមខ្មែរហ្នឹង ស្ត្រីយល់ថា<បុរស>ជាអ្នកការពារ អ្នកគ្រប់គ្រង។ ហើយដូចដែលខ្ញុំបញ្ជាក់ខាងដើមគឺថា បុរសយល់ខ្លួនថាភាពជាបុរស ដើម្បីការពារប្រពន្ធហើយនិងគ្រប់គ្រង។ ប៉ុន្តែបន្ទាប់ពីខ្មែរក្រហម ទស្សនៈរបស់បុរសហ្នឹងត្រឡប់មកគេវិញ <>ហើយគេ<រំពឹងថាបុរសជាអ្នក>ការពារ ហើយនិងជាអ្នកគាំពារ<គ្រួសារ> ជាអ្នកផ្តល់ស្បៀងអាហារគ្រប់គ្រងជាដើម <បើប្រុសៗអាចការពារភាពជាបុរសនេះបាន នោះស្ត្រីនឹងច្បាប់ផ្តើមស្រឡាញ់គេជាប្តី>។ នេះហើយជាមូលហេតុដែលសំខាន់ដែលខ្ញុំបានស្តាប់ស្ត្រីទាំងនោះ។

**ស៖** ចុះអំពីបញ្ហានៃអាពាហ៍ពិពាហ៍ដោយបង្ខំ <>ជាទូទៅ<នោះយ៉ាងម៉េចដែរ?> នៅពេលដែលលោកស្រីនិយាយទៅរកបុរស និងស្ត្រីដែលគេបង្ខំឱ្យរៀបការនោះ ថាតើមានទស្សនៈរួមពីបញ្ហាហ្នឹងទេ ដែលថាពួកគេមិនសប្បាយទេ នៅពេលដែលគេបង្ខំឱ្យរៀបការ ឬក៏គេពេញចិត្ត? <>តើអារម្មណ៍របស់គេដូចម្តេចអំពីការរៀបការដោយបង្ខំនេះហ្នឹង?

[១៤:៣៥:២៨]

**ឆ៖** ដោយសារពេលដែលសម្ភាសហ្នឹង គឺថាវា៤ឆ្នាំក្រោយពីអាពាហ៍ពិពាហ៍ដោយបង្ខំ។ អ៊ីចឹង គឺក្នុងគំនិតដែលថាយើងត្រូវកំណត់ពីបញ្ហានៅពេលនេះ ចំពោះអ្នកដែលគេបង្ខំឱ្យរៀបការ ហើយគេសម្រេចចិត្តថាបែកគ្នាហើយនោះ ពួកគេមានវិប្បដិសារី គឺថាមិនគួរតែបានរៀបការបែបនោះ គេមិនពេញចិត្តទាល់តែសោះ។ ប៉ុន្តែចំពោះអ្នកដែលបន្តរួមរស់ជាមួយគ្នាវិញ គេមិនអាចបដិសេធចំពោះដំណើរដែលគេបាននៅជាមួយគ្នាពីពេលនោះ មកដល់ពេលនេះទេ ពីព្រោះគេយល់ថា ចាប់ផ្តើមពីបាតដៃទទេ ហើយមានកូន ហើយរហូតដល់កូនគេនៅរស់។ ប៉ុន្តែពេលដែលខ្ញុំសួរគាត់អំពីពិធីរៀបការជាក់លាក់អំពីរបៀបដែលគេរៀបការហ្នឹង ស្ត្រីភាគច្រើននិយាយថាពួកគេសោកស្តាយ ហើយមានវិប្បដិសារីដោយសារគេមិនមានពិធីការរៀបការត្រឹមត្រូវ មិនមានឪពុកម្តាយចូលរួម មិនមានសម្លៀកបំពាក់តែងខ្លួនឯងជាដើម។ ចំពោះបុរសមួយចំនួនដែលខ្ញុំបានសម្ភាសនោះ ពួកគេមិនបានសម្តែងពីអារម្មណ៍ការរៀបការដោយបង្ខំ ហើយគេទទួលថា ធ្វើម៉េចបើវាអ៊ីចឹងទៅហើយ។ ហើយពួកបុរសនោះ គាត់មិនមានវិប្បដិសារីអីធ្ងន់ធ្ងរខ្លាំងទេ។

[១៤:៣៧:០៣]

**ស៖** <សូមត្រឡប់មក>និយាយ<ពី>បញ្ហា<>រួមដំណោកក្រោយពីរៀបការហ្នឹង<តាមទស្សនៈ

របស់លោកស្រី នៅពេលដែល>គេណែនាំ <ឬក៏បញ្ជាឲ្យបុរសស្ត្រីរៀបការហ្នឹង តើពួកគេ>យល់ស្រប ទាំងស្រុង និង រួមភេទ<ជាមួយដៃគូទេនៅសម័យកម្ពុជាប្រជាធិបតេយ្យនោះ>?

**ឆ៖** ខ្ញុំមិនគិតបែបនោះ មិនគិតថាមានការយល់ស្របនោះទេ។ រីឯការរៀបការដោយបង្ខំ គឺ មិនមានការយល់ព្រម គឺមិនដោយឆន្ទៈរបស់ភាគីមួយៗទេ។ សេចក្ដីសម្រេចក្នុងការរួមដំណេក រួមរ័ក ហ្នឹង គឺថាមិនចេញឆន្ទៈរបស់គេទេ។ ពួកគេត្រូវបានបំភិតបំភ័យ ពួកគេមានការភ័យខ្លាច ទោះបីគេរួម ដំណេកក៏ដោយ គឺមិនមែនជាការព្រមព្រៀងពិតចេញពីបុរស និងស្ត្រីទេ។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណ។ ឥឡូវនេះ គឺថាម៉ោងពីរសាបសិបប្រាំបីនាទីហើយ ប្រហែលជាសមស្របដើម្បី សម្រាក លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

លោកព្រះរាជអាជ្ញាបន្តសំណួរ។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រី ចៅក្រម សហការី និងអ្នកជំនាញ។ ខ្ញុំមានសំណួរ តិចតួចទៀតទេ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** នៅថ្ងៃនេះ គឺលោកស្រីបានឆ្លើយថា លោកស្រីបានធ្វើការស្រាវជ្រាវល្អិតល្អន់ទាក់ទងទៅ នឹងអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសពាក់ព័ន្ធទៅនឹងការកំណត់ការរៀបការ ការអនុញ្ញាតឲ្យរៀបការ និងការរៀបការដោយបង្ខំ។ លោកស្រីមានឯកសារពាក់ព័ន្ធទៅនឹងសៀវភៅ ដែលបោះពុម្ពផ្សាយនៅឆ្នាំ២០០៨ ហើយក៏មានឯកសារផង យោងផងដែរនៅក្នុងសៀវភៅទី២ របស់

លោកស្រីពាក់ព័ន្ធទៅនឹងអំពើហិង្សាផ្លូវភេទ ប្រឆាំងទៅនឹងជនជាតិភាគតិច ហើយលោក<ស្រី>មានឯកសារពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ <នៅក្នុង>សៀវភៅទី៣ គឺមានចំណងជើងថា "ភាពជាមាតានៅក្នុងពេលសង្គ្រាម"។ <លោកស្រីនិយាយនៅថ្ងៃនេះដែរថា លោកស្រីក៏បានទទួលព័ត៌មាន> ទាក់ទងទៅនឹង<ការរៀបការដោយបង្ខំ> ពាក់ព័ន្ធទៅនឹង<ការងារនាពេលបច្ចុប្បន្ននេះ ទាក់ទងទៅនឹង>ទាហានកុមារនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ <លោកស្រីនិយាយយោងទៅលើ>របាយ-ការណ៍<របស់ ដេ ឡាំងហ្គីស និងអ្នកផ្សេងៗទៀត។ វាមានចំណងជើងថា "ដូចខ្មោចប្រែរូប" ដែលជា>ការសិក្សា ពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ដែលត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ២០១៤។ ហើយខ្ញុំគិតថា<>លោកស្រីក៏បានអានការសិក្សាស្រាវជ្រាវ រ៉ូសែល ប្រាហ្វ "អំពើហិង្សា<ផ្លូវភេទ>ទៅនឹងជនជាតិភាគតិចនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ" ដែលបោះពុម្ពផ្សាយនៅឆ្នាំ២០១៤។

ដូច្នេះសំណួររបស់ខ្ញុំពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវដែលលោកស្រីបានធ្វើ ក៏ដូចជាការសិក្សាស្រាវជ្រាវរបស់អ្នកនិពន្ធដទៃទៀត តាមការយល់ឃើញរបស់លោកស្រី <តើ>ការរៀបការដោយបង្ខំ<កើតឡើង>នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនៅតាមបណ្តាខេត្តដទៃៗទៀតនៅក្នុងអំឡុងពេល<នោះឬ>ទេ?

[១៥:០៣:០៣]

**កញ្ញា កាស៊ូមិ ណាកាហ្គាវ៉ា៖**

**ឆ៖** ហ្នឹងគឺជាការត្រឹមត្រូវហើយ។

**ស៖** ពីខាងដើមនេះលោកស្រីក៏បានលើកឡើងមានស្ត្រីម្នាក់ទៀត ដែលបានធ្វើការជាមួយលោកស្រីនៅគម្រោងការពារក្តីនៅកម្ពុជា។ <គឺលោកស្រី ប្រ៊ីដជិត ច័យក្រូណិន> គាត់បានសរសេររបាយការណ៍មួយដោយយោងទៅលើភស្តុតាងដូចគ្នានេះដែរ គឺភស្តុតាងដែលលោកស្រីបានប្រមូលជាក្រុមតែម្តង។ ខ្ញុំចង់សួរទៅលោកស្រីចំពោះគំនិតយោបល់ដែលគាត់បានលើកឡើងពាក់ព័ន្ធទៅនឹងភស្តុតាង។ នៅសៀវភៅនេះមានចំណងជើងថា "ខ្ញុំចង់ប្រាប់លោកអ្នកអំពីរឿងរ៉ាវអំពើហិង្សាផ្លូវភេទក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ" គឺឯកសារ E3/3416 អង់គ្លេស 00449489, ខ្មែរ 00721382, បារាំង 00630485។ គឺនៅក្នុងសៀវភៅនេះ គឺទំព័រ៨៧។ លោកប្រធាន ខ្ញុំសូមបញ្ចាំងនៅលើអេក្រង់ផងដែរ។ ខ្ញុំសូមអានសម្រង់គាត់ឲ្យគាត់ស្តាប់។

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

"ភាពស៊ីចង្វាក់គ្នានៃការរុករកអំពីការរៀបការដោយបង្ខំនៅទូទាំងភូមិសាស្ត្រ បញ្ជាក់អំពីមានគោល -- គឺថាមានគោលនយោបាយពីថ្នាក់លើពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំនេះ"។ ហើយវាពាក់ព័ន្ធថាតើអាជ្ញាធរថ្នាក់ក្រោមនេះអនុវត្តគោលនយោបាយនេះតឹងរ៉ឹងដោយរបៀបណា។ ដូចសោភ័ណបានពន្យល់ហ្នឹង៖ "ខ្ញុំបានបដិសេធមិនព្រមរៀបការពីរដង ដោយខ្ញុំយកលេសថា ខ្ញុំអត់មានខោអាវ ឬក៏អត់មានក្រមា ប៉ុន្តែខ្ញុំសម្រេចរៀបការទៅនៅពេលដែលគេស្នើសុំជាលើកទី៣។ នៅក្នុងតំបន់របស់ខ្ញុំ គេមិនបានបង្ខំប្រជាជនឲ្យរៀបការដូច<គេធ្វើចំពោះអ្នកផ្សេងនោះ>ទេ។ តំបន់ខ្លះតឹងតែងណាស់ គឺគេមិនអាចប្រកែកមិនព្រមរៀបការដូចខ្ញុំ ដូចជានៅស្រុកកំពង់ត្រាច ដែលខ្ញុំរស់នៅគឺមិនសូវជាតឹងតែងពេកទេ។ អ៊ីចឹងឯង បានជាខ្ញុំអាចប្រកែកមិនព្រមរៀបការបាន។" ហើយ<បន្ទាប់មក លោកស្រី ច័យ ក្រូណិន បន្តថ្លែងថា៖> "សូម្បីតែក្នុងតំបន់នេះក៏ដោយគឺច្បាស់ហើយថា គោលនយោបាយវាពិតជាកើតមានមែន។ ហើយវាមានភាពខុសគ្នា គឺខុសគ្នាតែរឿងតាមការអនុវត្តជាក់ស្តែងតែប៉ុណ្ណោះ។" ខ្ញុំគិតថាលោកស្រីបានអានរបាយការណ៍របស់គាត់ តើលោកស្រីមានយោបល់ថាម៉េចដែរចំពោះគំនិតយោបល់របស់គាត់នេះ ពាក់ព័ន្ធទៅនឹងភាពស៊ីចង្វាក់គ្នា អនុវត្តនៅតាមទីតាំងភូមិសាស្ត្រផ្សេងៗ បញ្ជាក់ថាមានគោលនយោបាយចេញពីថ្នាក់លើ។ ហើយការរៀបការដោយបង្ខំហ្នឹងគឺ ថាវាមានការអនុវត្តខុសៗគ្នាអាស្រ័យទៅលើការអនុវត្តជាក់ស្តែង។ តើលោកស្រីយល់ស្របជាមួយនឹងការលើកឡើងនេះទេ?

[១៥:០៦:០៧]

**ឆ៖** ខ្ញុំគិតថាមានគោលនយោបាយចេញពីថ្នាក់លើទៅដើម្បីឲ្យមានការរៀបការជាសមូហភាព ក៏ប៉ុន្តែខ្ញុំមិនមានភស្តុតាងបញ្ជាក់ឲ្យច្បាស់ថា ឲ្យមានការគោលនយោបាយបង្ខំឲ្យរៀបការនោះទេ។

**ស៖** សូមអរគុណ។ តែទោះជាយ៉ាងណាក៏ដោយ ភស្តុតាងដែលលោកស្រីប្រមូលបាន ថាការរៀបការដោយបង្ខំបានកើតមានឡើងនៅស្ទើរគ្រប់ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** ខ្ញុំសូមផ្តល់ឯកសារមួយជូនទៅលោកស្រីមើល គឺជាឯកសារគោលនយោបាយចេញដោយបក្សកុម្មុយនីស្តកម្ពុជា ឯកសារនេះទាក់ទងទៅនឹងឯកសារទង់បដិវត្តន៍ផងដែរ ហើយដែលមានចំណងជើងថា "ទស្សនៈសង្គមនិយម និងទស្សនៈមិនមែនសង្គមនិយម <ទាក់ទងនឹងបញ្ហាការកសាងគ្រួសារ>" <ដកស្រង់ចេញពីឯកសារថ្ងៃទី០២ ខែមិថុនា> នៅក្នុងឆ្នាំ<១៩៧៥> <ប៉ុន្តែជាឯកសារបោះពុម្ពឡើងវិញពីឯកសារ>ចុះ<ថ្ងៃទី០២ >ខែកុម្ភៈ ឆ្នាំ១៩៧៤។ <ហើយសូមបញ្ចាំងនៅលើអេក្រង់

01364787



កុំព្យូទ័រ។> សៀវភៅលេខ 487 គឺ ERN គឺ E3/775, អង់គ្លេស 00417943, ខ្មែរ 00407101, បារាំង 00593930។

"តើយើងជាយុវជនបដិវត្តអាចជ្រើសរើសគូស្រករដោយរបៀបណា? គឺយើងត្រូវមានអង្គការវិន័យត្រូវតែគោរពឲ្យបានត្រឹមត្រូវ ពាក់ព័ន្ធទៅនឹងការកសាងគ្រួសារ ទោះបីជាលទ្ធផលចេញអំពីការរៀបការដោយរបៀបណាក៏ដោយ គឺថាយើងត្រូវតែគោរពអង្គការវិន័យនេះឲ្យបានត្រឹមត្រូវ មិនត្រូវមានអារម្មណ៍រវើរវាយ មិនត្រូវអាក់អន់ចិត្តដោយសារថានេះមានតែអង្គការ ហើយនិងសមូហភាពទេដែលអាចធ្វើការវាយតម្លៃយ៉ាងហ្មត់ចត់ គ្រប់ជ្រុងជ្រោយទាំងអស់។ ហេតុដូច្នេះ ឯងត្រូវតែគោរពអង្គការវិន័យនេះឲ្យបានច្បាស់លាស់។" នេះគឺជាទស្សនាវដ្ដីពាក់ព័ន្ធទៅនឹងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ឬក៏ហៅថាខ្មែរក្រហមក៏បាននៅក្នុងសម័យកាលនោះ។ ខ្ញុំសូមលើកយកសម្រង់មួយទៀត ហើយសុំសួរសំណួរតាមក្រោយ។ នេះគឺជាសេចក្តីថ្លែងការណ៍របស់ នួន ជា ដែលអ្នកសរសេរប្រវត្តិរូបរបស់គាត់ ថេត សម្បត្តិ <និង ជីណា ចន> ហ្នឹងជាអ្នកលើកឡើង។ នៅក្នុងសៀវភៅរបស់ពួកគេថា "នៅខាងក្រោយវាលពិឃាត" នេះគឺជាសៀវភៅលេខ 455 គឺ <E3/24202>--

**អ្នកបកប្រែ៖**

សូមការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា អានម្តងទៀតលោកប្រធាន តាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាសូមអានលេខ ERNឲ្យបានច្បាស់ម្តងទៀតជូនដល់អ្នកបកប្រែ។

[១៥:០៩:៤២]

**លោក វីល្លៀម ស្មីត៖**

ខ្ញុំសូមទោសជាថ្មីម្តងទៀត គឺ00858253 ខ្មែរ, បារាំង 00849377 ដល់ 78។ អ្នកនិពន្ធបានដកស្រង់សម្តីរបស់ នួន ជា ដែលលើកឡើងថា "បុរសគឺតែងតែចង់ជ្រើសរើសយកស្រីស្អាតៗ ហេតុដូច្នេះឯងបានជាយើងបង្ខំឲ្យពួកគេរៀបការ ហើយអង្គការហ្នឹងគឺអ្នករើសប្រពន្ធឲ្យពួកគេ"។ បាទ ជាមួយនឹងសេចក្តីថ្លែងការណ៍នេះ -- យើងឃើញថាមានការជំទាស់។ ពិតណាស់យើងមានការជំទាស់។

**ប្រធានអង្គជំនុំ៖**

លោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ ពិតហើយខ្ញុំមានការជំទាស់មួយលោកប្រធាន។ ខ្ញុំសូមចាប់ផ្តើមពីចំណុចតូចមួយសិន។ ខ្ញុំមិនច្បាស់ថាតើហេតុអ្វី ថេត សម្បត្តិ ហើយនិង ជីណា ចន នេះទៅជាលើកតម្កើងថាសុទ្ធតែជាអ្នកសរសេរប្រវត្តិរូបនេះ –*បាយអូក្រាហ្វ៊ី* នេះ។ <ដូច្នេះនេះគឺជាការជំទាស់តូចមួយទៅនឹងការលើកឡើងនូវសំណួរពិសេសនោះ។> ការជំទាស់មួយទៀត គឺការជ្រើសរើសឯកសារដែលសហព្រះរាជអាជ្ញាបានលើកយកមកសំអាង គឺដកស្រង់ឯកសារចេញពីឯកសារទង់បដិវត្ត ហើយដែលនៅពេលនោះសហព្រះរាជអាជ្ញាបានដឹងច្បាស់អំពីគោលសីលធម៌ទាំង១២ប្រការនោះហើយ <ជាពិសេស>សីលធម៌<៦> ប្រការនេះ វាច្បាស់លាស់ជាង ពាក់ព័ន្ធទៅនឹងការរៀបការ។ ហើយសំខាន់បំផុតអ្នកជំនាញទើបតែផ្តល់សក្ខីកម្មពីខាងដើម ថាគាត់មិនបានសិក្សាស្រាវជ្រាវទៅលើឯកសារណាមួយ បាទ ឯកសារគោល-នយោបាយ ឯកសារសម័យកាល<នោះ> ឬក៏ឯកសារចេញដោយបក្សកុម្មុយនីស្តកម្ពុជានោះទេ។ អ៊ីចឹងតាមសម្តីរបស់គាត់ គាត់មិនមែនជាអ្នកជំនាញទៅលើឯកសារគោលនយោបាយនោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមិនទាន់ឮសួរសំណួរនៅឡើយ ទើបតែឮបង្ហាញឯកសារនៅឡើយតើ។ អ៊ីចឹងលោកហាក់បីដូចជាសន្មតជាមុនទៅហើយ ថាសហព្រះរាជអាជ្ញាសួរសំណួរណាទៅហើយ ព្រោះគាត់ទើបបង្ហាញឯក-សារនៅឡើយហ្នឹង។ <សូមចាំឲ្យគាត់លើកជាសំណួរសិន សឹមលោកជំទាស់ នោះទើបសមហេតុផល។>

**លោក វ៉ិចទ័រ កូប៉េះ**

យើងអាចដឹងមុន ស្មានមុនបាន។ <ប៉ុន្តែបើសហព្រះរាជអាជ្ញាងើបឡើងសួរនោះ> ខ្ញុំដឹងថា ខ្ញុំអាចនឹងជំទាស់ដូចតែគ្នាដដែលនេះទេ។

[១៥:១២:៣០]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកស្រីចៅក្រម។

**ស៖** សេចក្តីថ្លែងការណ៍ដែលខ្ញុំទើបតែបានអានឲ្យលោកស្រីស្តាប់អម្បាញ់មិញនេះ គឺអ្នកនិពន្ធបានបញ្ជាក់រួចមកហើយថា បក្សកុម្មុយនីស្តកម្ពុជាបានត្រួតត្រាទៅលើដំណើរការរៀបការ តើសេចក្តីថ្លែងការណ៍នេះវាស៊ីចង្វាក់គ្នាទៅនឹងការសិក្សាស្រាវជ្រាវនៅថ្នាក់មូលដ្ឋាន ពាក់ព័ន្ធទៅនឹងការត្រួតត្រាពី

សំណាក់អាជ្ញាធរខ្មែរក្រហមនៅថ្នាក់មូលដ្ឋាននៅទូទាំងប្រទេសនោះដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវនេះសំណួរសួរហើយខ្ញុំរក្សាការជំទាស់របស់ខ្ញុំដដែល គឺជាការជ្រើសរើសសម្រង់មួយចេញពីឯកសារសម័យកាល<> គឺឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា។ ហើយ<បន្ថែមពីលើនោះទៀត ដូចដែលខ្ញុំបាននិយាយពីខាងដើមមកហើយថា យោងតាមការទទួលស្គាល់របស់>អ្នកជំនាញនេះ<គាត់>ក៏ប្រាប់ហើយដែរថាគាត់មិនបានដឹងអំពីឯកសារគោលនយោបាយនេះទេ។ គាត់មិនបានសិក្សាស្រាវជ្រាវអំពីឯកសារគោលនយោបាយនេះទេ។ អ៊ីចឹងការសួរសំណួរទៅលើចំណុចនេះ គឺវាហួសពីសមត្ថភាពរបស់គាត់ជាអ្នកជំនាញផ្នែកនេះហើយ។ ហើយការជំទាស់តូចមួយទៀតនោះ តើៗ ថេត សម្បត្តិ និង ជីណា ចន នេះ អាចមានលក្ខណៈសម្បត្តិជាអ្នកសរសេរប្រវត្តិរូបដោយរបៀបណា?

[១៥:១៤:១៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោក<មានគំនិតជាយូរមកហើយ>ថា <>អ្នកជំនាញ<នេះមិនអាចឆ្លើយបានទេថា "ខ្ញុំមិនដឹងទេ" ឬក៏ថា "ខ្ញុំអត់មានចម្លើយទេ" បើគាត់>មិនទាន់ឆ្លើយនៅឡើយផង។ មិនទាន់ឆ្លើយថាខ្ញុំគ្មានចម្លើយទៅនឹងសំណួរនេះ ឬក៏យ៉ាងណានោះទេ។ <ខ្ញុំបានឮដូច្នេះពីរបីដងមកហើយ។ ដូច្នេះ នេះមិនមែន>ជាសាក្សី<ដែលងាយស្រួល>នាំ<មុខនោះទេ ហើយពិតណាស់> នៅពេលដល់វេនរបស់លោក លោកប្រើប្រាស់ភស្តុតាងណាមួយក៏បានដែរ ដើម្បីយកមកសួរសំណួរ យកមកតាំងសំណួរទៅកាន់រូបគាត់។ <ជាថ្មីម្តងទៀត>គាត់ជាអ្នកជំនាញ មិនមែនជាសាក្សី<ដែលងាយស្រួលសួរនាំមុខនោះ>ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ស្របថាគាត់ជាអ្នកជំនាញ គាត់ខុសពីអ្នកជំនាញដទៃទៀត ដែល<អាចដឹងបាននូវអ្វីដែលគាត់មានជំនាញ និងអ្វីដែលគាត់មិនមានជំនាញនោះ>។ នេះមិនមែនទាន់ផ្លាស់ប្តូរ ឬក៏ប៉ះពាល់ទៅដល់ការដែលខ្ញុំជំទាស់នេះទេ ពីព្រោះថាសហព្រះរាជអាជ្ញានេះ គាត់ជ្រើសរើសដោយចោះៗទេ ចេញពីឯកសារពីសម័យនោះ។ <នេះជាការជំទាស់ជាធម្មតានៅក្នុងបន្ទប់សវនាការនេះ។ ខ្ញុំបានទទួលការ>ជំទាស់ <ក្នុងការ>ជ្រើសរើសសម្រង់ដោយចោះៗបែបនេះ<គ្រប់ពេល>។ បើសិនជាសហព្រះរាជអាជ្ញា គាត់បន្ថែមពាក់ព័ន្ធទៅនឹងសីលធម៌ទាំង១២ប្រការផងមក ខ្ញុំមិនជំទាស់ទេ។ ជាពិសេស ប្រការទី៦នេះតែម្តង។ អ៊ីចឹង មួយសួរថា តើគាត់ដឹងពីអ្វីខ្លះ ហើយគាត់មិនដឹងពីអ្វីខ្លះជាមុនសិន។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**លោក វីល្មៀម ស្មីត៖**

នេះជាចំណុចចុងក្រោយរបស់ខ្ញុំហើយ ខ្ញុំ<នឹង>ចូលទៅនិយាយអំពីសីលធម៌១២ប្រការ ប្រការទី៦ នោះ<>។ <លោកលោកស្រីចៅក្រម ពិតណាស់ យើងមិនមែនកំពុងតែសួរនាំមុខអ្នកជំនាញនេះទេ។> អ្នកជំនាញ គាត់មានជំនាញរបស់គាត់ពាក់ព័ន្ធទៅនឹងទៅការអនុវត្តជាទូទៅ ទ្រង់ទ្រាយធំនៅទូទាំងប្រទេសកម្ពុជា<អំពីការការរៀបការដោយបង្ខំនោះ ហើយវាមានហេតុផលសម្រាប់គាត់ក្នុងការបញ្ចេញយោបល់ថាតើ>ឯកសារទាំងនេះ វាមានពាក់ព័ន្ធ ឬមិនពាក់ព័ន្ធ<>។ តែខ្ញុំត្រូវបន្តទៅមុខទៀតចុះ។

[១៥:១៦:១៤]

**សួរដោយលោក វីល្មៀម ស្មីត៖**

**ស៖** តើលោកស្រីឆ្លើយសំណួរខ្ញុំហើយឬនៅ?

**ឆ៖** អត់ទេ។

**ស៖** តាមការកត់សម្គាល់របស់លោកស្រីទាក់ទងទៅនឹងការអនុវត្តដ៏ទូលំទូលាយ ពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំនៅទូទាំងប្រទេសកម្ពុជា ប្រៀបធៀបជាមួយការសិក្សារបស់លោកស្រី <និងអ្នកផ្សេងទៀត តើវាស៊ីគ្នា>ទៅនឹងកម្រិតនៃការត្រួតត្រាដែលបានបញ្ជាក់<ពាក់ព័ន្ធទៅនឹង>ទស្សនាវដ្ដីនេះ ក៏ដូចជាសេចក្ដីថ្លែងការណ៍របស់ នួន ជា ពាក់ព័ន្ធទៅនឹងកម្រិតនៃការត្រួតត្រាទៅលើការរៀបការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ<នោះ? តើវាស៊ីសង្វាក់គ្នាទេ?>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឲ្យមានការសម្រេចពីអង្គជំនុំជម្រះ។ ខ្ញុំសូមជំទាស់ លោកប្រធាន។ ទោះបីជាដកចេញពីនោះក៏ដោយ គឺថាសហព្រះរាជអាជ្ញាគាត់មិនបានអានគោលនយោបាយ គោលសីលធម៌១២ប្រការនោះទេ។ បើមិនអានទេ ខ្ញុំសូមជំទាស់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធការជំទាស់។ សូមអ្នកជំនាញឆ្លើយ!

**កញ្ញា កាស៊ូមិ ណាកាហ្គាវ៉ា៖**

**ឆ៖** សូមអរគុណ។ ចំពោះភស្តុតាងនៅក្នុងសៀវភៅមួយថា *"ប៊ីហាញ ឌី យៀលលីង ហៀល"* នៅក្រោយការកាប់សម្លាប់វាលពិឃាដនេះ។ <ហេតុផលក្នុង>ការរៀបការនេះ ចំពោះខ្ញុំ គឺវា

<ហាក់ដូចជាចម្លែកខ្លាំងណាស់> ហើយខ្ញុំនឹកមិនឃើញអំពីមូលហេតុដែលថា ប្រុសៗ គឺថាត្រូវជ្រើសរើសនូវស្រីស្អាតៗ ប៉ុន្តែនៅខាងក្រោមនេះ នួន ជា បាននិយាយថា ការរៀបការនេះ គឺក្នុងគោលបំណងដើម្បីបម្រើចលនាបដិវត្ត។ គោលបំណងនៃការរៀបការគឺដើម្បីបម្រើគោលបំណងបដិវត្ត។ គឺថាវាដូចគ្នាមែនទែន នូវអ្វីដែលខ្ញុំបានឃើញ។ ហើយចំពោះឯកសារមួយផ្សេងទៀតផងដែរនោះ ខ្ញុំ<មិន>អាចភ្ជាប់ចំណុចនេះទៅនឹងការរៀបការដោយបង្ខំ<នោះទេ> ប៉ុន្តែខ្ញុំ<>អាចប្រៀបធៀប<ចំណុចនេះទៅនឹងជីវិតអាពាហ៍ពិពាហ៍ ដែលជីវិតអាពាហ៍ពិពាហ៍នេះមិនបានកើតឡើងទេ ក្រោយពេលប្រជាជនត្រូវបានគេរៀបការឲ្យរួចហើយ ឬក៏ក្រោយពេលគេបង្ខំឲ្យរៀបការរួចហើយនោះ។> ខ្ញុំអាចនិយាយបានតែប៉ុណ្ណេះឯង។

[១៥:១៨:៣៨]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** ខ្ញុំមានសំណួរពីរចុងក្រោយ។ ខ្ញុំសូមយោងទៅឯកសារទង់បដិវត្ត ដែលចេញផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជានៅខែតុលា ១៩៧៨ ដែលនិយាយ មានចំណងជើងថា "ផ្តោតទៅលើគោលនយោបាយ សីលធម៌ទាំង១២ប្រការ" គឺឯកសារ <E3/765> អង់គ្លេស <00539994>, ខ្មែរ 00376493 ដល់ 97, បារាំង 00540024 ដល់ 25។ បាទ សៀវភៅ គឺមានលេខរៀង៥១៤ ខ្ញុំចូលទៅក្នុងសារតូចមួយដែលបានលើកឡើង "សម្រាប់បញ្ហាបច្ចុប្បន្នក្នុងការកសាងគ្រួសារ មិនមានឧបសគ្គអ្វីទេ។ គឺយើងយោងទៅលើតែគោលការណ៍ពីររបស់បក្ស។ <ទី១> ភាគីទាំងពីរត្រូវយល់ព្រម ហើយទី<២> ត្រូវមានការយល់ព្រមពីសមូហភាព។ តែប៉ុណ្ណេះគឺរួចរាល់ហើយ។ ហេតុអ្វីក៏មានចំណុចពីរនេះពាក់ព័ន្ធទៅនឹងសីលធម៌របស់បុរសនិងនារី?" ឯកសារចុះខែតុលា ឆ្នាំ១៩៧៨ គឺឯកសារ E3/765។ សំណួររបស់ខ្ញុំសួរថា តើចំណុចនេះវាឆ្លុះបញ្ចាំងនូវអ្វីដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាទាក់ទងទៅនឹងការអនុវត្តការរៀបការដោយបង្ខំនេះដែរឬទេ?

**ឆ៖** គោលការណ៍ទាំងពីរនេះ ចំពោះអ្នកខ្លះដែលបានរៀបការហើយនោះ គឺគោលការណ៍ទាំងពីរនេះត្រូវបានយកមកអនុវត្ត។ ប៉ុន្តែចំពោះអ្នកដែលគេបង្ខំឲ្យរៀបការនោះ គឺគេបង្ខំឲ្យប្តេជ្ញាថាគេព្រមរៀបការ។ វាមិនបានចេញអំពីការស្ម័គ្រចិត្តដោយសុទ្ធចិត្តរបស់ពួកគេនោះទេ។ ហើយចំពោះ គេហៅថាត្រូវមានការសម្រេចយល់ព្រមពីសមូហភាពនោះ ដោយសារតែមានការភ័យខ្លាច<អំពើហិង្សា> គឺថា គ្មានអ្នកណាអាចប្រកែកមិនព្រមរៀបការនោះបានទេ។ ដូច្នេះ ពីខាងបក្សវិញនោះ គឺបក្សអាច

និយាយថា ភាគីទាំងពីរបានយល់ព្រមនៅក្នុងពេលរៀបការ ហើយក៏មានការយល់ព្រមពីសម្ភូហភាពដែរ។ ប៉ុន្តែតាមទស្សនៈរបស់បុរសនិងស្ត្រី អ្នកខ្លះគេយល់ស្រប យល់ព្រម អ្នកខ្លះអត់យល់ព្រមរៀបការទេ។ អ៊ីចឹងគោលការណ៍ទាំងពីរនេះមិនបានអនុវត្តគ្រប់ការរៀបការទាំងអស់នោះទេ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

សូមអញ្ជើញមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

[១៥:២២:១៦]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**ស៖** ជម្រាបសួរលោកស្រីអ្នកជំនាញ ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំនិងលោក ពេជ អង្គ តំណាងឱ្យក្រុមដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកស្រី ជាពិសេសពាក់ព័ន្ធទៅនឹងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំទៅលើបុរស និង ស្ត្រី ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្រោយពីរបបនេះដួលរលំទៅ។ ខ្ញុំសូមចាប់ផ្ដើមនិយាយអំពីអ្វីដែលលោកស្រីបានលើកឡើងកាលពីព្រឹកមិញ។ លោកស្រីថា មុនរបបកម្ពុជាប្រជាធិបតេយ្យ ការសម្រេចទៅលើការអប់រំនិងការរៀបអាពាហ៍ពិពាហ៍របស់កូន គឺធ្វើឡើងដោយឪពុកម្ដាយ។ ហើយវាជាសេចក្ដីសម្រេចដ៏សំខាន់។ ដូច្នេះ ខ្ញុំចង់ដឹងថា នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ តើការរៀបការជារឿងសំខាន់នៅក្នុងជីវិតរបស់បុរសនិងស្ត្រីមែនទេ? តើការរៀបអាពាហ៍ពិពាហ៍នេះវាមានផល វាមានឥទ្ធិពលយ៉ាងណាខ្លះទៅលើជីវិតរបស់បុរសនិងស្ត្រីនោះ?

**កញ្ញា កាស៊ូមិ ណាកាហ្គាវ៉ា៖**

**ឆ៖** ចាស សូមអរគុណច្រើន។ សារៈសំខាន់នៃការរៀបការនៅមុនសម័យខ្មែរក្រហមនោះសម្រាប់ស្ត្រីគឺថា គាត់ត្រូវតែបំពេញកាតព្វកិច្ចជាកូនស្រី ត្រូវតែយល់ស្របតាមសេចក្ដីសម្រេចរបស់ឪពុកម្ដាយ ហើយក៏ត្រូវតែដឹងគុណចំពោះឪពុកម្ដាយ។ ដូច្នេះ វាជាសញ្ញាណមួយ គឺជាដំណើរការមួយ

សម្រាប់កូនស្រី។ ហើយសម្រាប់កូនប្រុសវិញ វាជាដំណើរការដ៏ល្អដែលបុរសអាចបំពេញភាពជាបុរសរបស់ខ្លួន ក្នុងនាមជាអ្នកការពារ ក៏អ្នកផ្គត់ផ្គង់ទៅដល់គ្រួសារក្រៅពីឪពុកម្ដាយរបស់ខ្លួននេះ។

[១៥:២៤:៤៧]

**ស៖** សូមអរគុណលោកស្រី។ លោកស្រីបានពន្យល់អំពីរបៀបដែលស្ត្រីមើលឃើញអាពាហ៍ពិពាហ៍ក្នុងការគោរព និងផ្ដល់កិត្តិយលទៅដល់ឪពុកម្ដាយរបស់ខ្លួន។ ដូច្នេះ ខ្ញុំចង់ដឹងថា ជាថ្នូរមកវិញនោះ តើការរៀបអាពាហ៍ពិពាហ៍នេះគឺជាការការពារទៅដល់ស្ត្រីដែលយល់ព្រមរៀបការដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ។ ស្ត្រី គឺស្ថិតនៅក្រោមការការពារ<>គ្រប់ដំណាក់កាលទាំងអស់នៃជីវិតរបស់ខ្លួននេះ។ <ដូច្នេះគឺគេស្ថិតនៅក្រោមការការពារពីឪពុកម្ដាយរបស់ពួកគេ ហើយបន្ទាប់មកនៅក្រោមការការពារ>របស់ប្ដី<>។

**ស៖** នៅក្នុងឯកសារដែលគេបានបង្ហាញជូនលោកស្រីកាលពីព្រឹកមិញនេះហើយ គឺសៀវភៅរបស់ តេរីហ្សា ដឺឡាំងហ្គីស E3/9614, ERN ជាភាសាអង់គ្លេស 01037063។ គាត់និយាយអំពី "សំណាញ់សុវត្ថិភាព" ដែលបានបាត់បង់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកស្រីឯកភាពនឹងការសរសេររបស់គាត់ទេ? ហើយលោកស្រីមានយោបល់យ៉ាងណាពាក់ព័ន្ធនឹងពាក្យ "សំណាញ់សុវត្ថិភាព" ដែលមាននៅមុនរបបខ្មែរក្រហម ហើយត្រូវបាត់បង់នៅ<ក្រោយ>របបខ្មែរក្រហមនោះ?

[១៥:២៦:២៣]

**ឆ៖** ខ្ញុំយល់ស្រប មិនមានបណ្ដាញសុវត្ថិភាព ទាំងសម្រាប់ស្ត្រី សម្រាប់បុរសនៅក្នុងសម័យខ្មែរក្រហម។ បុគ្គលណាម្នាក់<ត្រូវ>បានបំបែកចេញពីគ្រួសារ។ កូនស្រី<និងកូនប្រុស>ហ្នឹង គឺត្រូវបានដកចេញពីឪពុកម្ដាយ។ ប្រពន្ធ <ត្រូវ>យកចេញពី<ប្ដី ហើយប្ដីក៏ត្រូវ>បំបែកចេញ<ពីប្រពន្ធ។> ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានសង្គម គឺត្រូវបានបំផ្លិចបំផ្លាញដោយខ្មែរក្រហម។ ដូច្នេះ មិនមានបណ្ដាញសុវត្ថិភាពនោះទេ។

**ស៖** តើលោកស្រីអាចរៀបរាប់លម្អិតជូនតុលាការបានទេ ថាតើផលប៉ះពាល់នៃការបាត់សំណាញ់សុវត្ថិភាពហ្នឹង វាមានយ៉ាងម៉េចខ្លះទៅលើស្ត្រីដែលលោកស្រីបានសម្ភាសនោះ?

**ឆ៖** ចំពោះនារីក្មេងដែលនៅលីវមិនទាន់រៀបការ ពួកគេបាត់បង់ការការពារពីឪពុកម្ដាយរបស់គេ <ហើយជាការពិតណាស់ ពួក>គេក៏បាត់បង់<ឱកាសក្នុង>ការការពារ<ចំពោះ>ឪពុកម្ដាយរបស់គេ<ដែលគេត្រូវធ្វើបែបនោះ>។ ហើយផលប៉ះពាល់ខាងផ្លូវអារម្មណ៍ ពេលនោះគឺធំធេងណាស់ <>

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែល<កូនស្រី>មិនអាចការពារឪពុកម្តាយរបស់គេ<បាន>។ វាអាស្រ័យទៅលើអាយុរបស់គេដែរ ប្រសិនបើកូនស្រី នៅពេលនោះគឺចាប់ផ្តើមជួយការងារផ្ទះរួចហើយនោះ នៅក្នុងចិត្តរបស់គាត់នោះ គាត់មានគំនិតថា គាត់ត្រូវតែផ្តល់ការការពារដល់ឪពុកម្តាយ ហើយឪពុកម្តាយត្រូវផ្តល់ការការពារមកខ្លួនវិញដែរ។ អ៊ីចឹងហើយកូនស្រីគឺទទួលរងផលប៉ះពាល់មួយដែលថាត្រូវបានកាត់ផ្តាច់នូវតួនាទីដ៏សំខាន់របស់ខ្លួនក្នុងជីវិត ក្នុងការការពារឪពុកម្តាយ ដែលថាជាភារកិច្ចក្នុងការសម្តែងនូវកតវេទិតា គឺការដឹងគុណទៅឪពុកម្តាយរបស់ខ្លួន។

[១៥:២៨:៣៨]

**ស៖** ចុះបុរសវិញ តើលោកស្រីអាចទាញសេចក្តីសន្និដ្ឋាននៃផលប៉ះពាល់នៃការបាត់បង់សំណាញ់សុវត្ថិភាពនេះទៅលើបុរសបានទេ?

**ឆ៖** ចំពោះបុរសដែលនៅលីវមិនទាន់រៀបការក្នុងរបបខ្មែរក្រហមនោះទេ វាអាស្រ័យទៅលើករណីមួយៗ គឺចំពោះអ្នកដែលមានអាយុច្រើន រវាងអាយុ១០ ទៅ អាយុ២០ឆ្នាំ ដែលនៅលីវ។ អ្នកដែលនៅក្មេងនោះគឺថា ពួកគេនឹកឪពុកម្តាយ គឺនឹកម្តាយខ្លាំងណាស់។ ពួកគេត្រូវការការពារនិងសេចក្តីស្រឡាញ់ពីម្តាយ។ <ខ្ញុំ>មាន<ការ>ប៉ះទង្គិចអារម្មណ៍ណាស់ <នៅពេល>ខ្ញុំជួបបុរសវ័យចំណាស់ម្នាក់ គាត់<និយាយដដែលៗ>ថា<> គាត់នឹកម្តាយគាត់ណាស់ក្នុងសម័យនោះ។ <វាពិតជាធ្វើឲ្យខ្ញុំរំជួលចិត្តណាស់។> ហើយគាត់ពន្យល់ពីរបៀបដែលពួកគេព្យាយាមចង់ជួបម្តាយរបស់គាត់ <ដោយប្រឈមនឹងគ្រោះថ្នាក់ដល់>ជីវិត<>។ <ប៉ុន្តែខ្ញុំមិនគិតថា បុរសមានតួនាទីដូច>ស្ត្រី<នោះទេ ដែល> គេគិតថា គេត្រូវផ្តល់ការការពារទៅដល់ឪពុកម្តាយរបស់គេ<>។

**ស៖** សូមអរគុណ។ ខ្ញុំសូមដកស្រង់នូវសម្រង់ខ្លីមួយនៃសក្ខីកម្មដែលបានស្តាប់នៅក្នុងសវនាការ គឺ 2-TCCP-232។ នេះជារហស្សនាមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលត្រូវបានស្តាប់សក្ខីកម្មនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ គាត់បានឆ្លើយនៅម៉ោង ១០:០៥នាទី គឺគាត់បានរៀបរាប់ភាពខុសគ្នារវាងអាពាហ៍ពិពាហ៍នៅមុន និង<ក្រោយ>របបខ្មែរក្រហម។ គាត់និយាយថា "កាលពីមុនមានគ្រួសារដែលត្រូវចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ដើម្បីប្រសិទ្ធពរជ័យទៅដល់គូស្វាមីភរិយាថ្មោងថ្មី។" ដូច្នេះខ្ញុំចង់និយាយអំពីការប្រសិទ្ធពរជ័យនេះ លោកស្រីអាចពន្យល់បានទេ ថាតើគ្រួសារនេះ គេប្រសិទ្ធពរជ័យយ៉ាងម៉េចខ្លះទៅដល់គូស្វាមីភរិយាថ្មោងថ្មីនៅមុនរបបខ្មែរក្រហមនោះ? ហើយតើនៅក្នុងរបបខ្មែរក្រហមផ្ទាល់តែម្តងនោះ ក្រុមគ្រួសារអាចប្រសិទ្ធពរជ័យទៅដល់គូស្វាមីភរិយាហ្នឹងបានទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:៣១:៣៥]

**ឆ៖** ជាពិសេសគឺថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺមិនមានការប្រសិទ្ធពរជ័យអ្វីទេ ពីព្រោះឪពុកម្ដាយត្រូវបានហាមឃាត់មិនឲ្យបំពេញភារកិច្ចនេះទេ ជាពិសេសក្នុងការឲ្យពរជ័យ ឬក៏ស្វាគមន៍ ឲ្យពរទៅកូន ពេលដែលរៀបការនោះទេ។ ចំពោះមុនសម័យកម្ពុជាប្រជាធិបតេយ្យនៅក្នុងដំណើរការនៃការរៀបអាពាហ៍ពិពាហ៍ ឪពុកម្ដាយទាំងប្រុស ខាងស្រីបានចូលរួមពិធី គឺថា សកម្មជាងកូនកំលោះ និងកូនក្រមុំ ពីព្រោះគឺថា ពួកគេត្រូវរៀបចំហើយ និងដំណើរការពិធីនានា ដើម្បីឲ្យកូនប្រុសកូនស្រីនោះមានជីវិតអាពាហ៍ពិពាហ៍អនាគតល្អ។ ហើយគេក៏ចាត់ទុកថា ជាការប្រសិទ្ធពរជ័យដែរ។

ហើយក្នុងករណីមួយទៀត គឺថា ឪពុកម្ដាយត្រូវតែចូលរួមពិធីទាំងមូល តាំងពីពិធីដែលមានវត្តមានព្រះសង្ឃផង ហើយនិងទទួលភ្ញៀវដែលចូលមក ចូលរួមក្នុងពិធីនោះដែរ។ ហើយខ្ញុំនៅចាំករណីមួយដែលថា ស្ត្រីម្នាក់បានបញ្ជាក់ថា គឺឪពុករបស់គាត់មិនអាចចូលរួមពេលព្រឹកបានទេ ព្រោះមានភារកិច្ចខាង រដ្ឋាភិបាល។ ហើយគាត់ថា គាត់មានការខ្មាសអៀនណាស់ ដែលឪពុកគាត់មិនបានចូលរួមក្នុងពេល ព្រឹកដែលគាត់ចូលរួមប្រជុំឯណា រដ្ឋាភិបាលនោះវិញ។ ហើយឪពុកម្ដាយដែលចូលរួមក្នុងពិធីមង្គលការ នោះ មានន័យថាពួកគេស្វាគមន៍ ពួកគេចូលរួម ហើយគេក៏បានឲ្យពរជ័យនៃការលើកទឹកចិត្តនៃការប្រសិទ្ធពរជ័យនេះឯង។

[១៥:៣៣:៥០]

**ស៖** តើលោកស្រីមានបានកត់សម្គាល់ឃើញថាអ្នកដែលត្រូវបានគេរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនមានគ្រួសារចូលរួមនៅក្នុងការរៀការនោះ មានអារម្មណ៍ឈឺចាប់ទេដែលគ្មានវត្តមានគ្រួសារនៅពេលរៀបការនោះ? ហើយប្រសិនបើពួកគាត់ឈឺចាប់នោះ តើលោកស្រីអាចនិយាយអ្វីខ្លះបានពាក់ព័ន្ធទៅនឹងចំណុចនេះ? ហើយតើអវត្តមានគ្រួសារក្នុងពេលរៀបការហ្នឹងវាមានផលប៉ះពាល់អ្វីខ្លះទៅលើគូស្វាមីភរិយាហ្នឹង?

**ឆ៖** វាប៉ះពាល់ខ្លាំងណាស់ ជាពិសេសចំពោះអ្នករៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ បាទ ទោះបីផ្អែកលើមូលដ្ឋាននៃការរៀបការបែបណាក្ដី ខ្ញុំមិនមានរឿងរ៉ាវច្រើនមកពីបុរសៗទេ ដែលរៀបការនៅក្នុងសម័យខ្មែរក្រហម ជាពិសេសអំពីរបៀបដែល អារម្មណ៍របស់គេ ដែលថាឪពុកម្ដាយ <មិនបាន>ចូលរួម។ ប៉ុន្តែខ្ញុំមានរឿងរ៉ាវជាច្រើនរបស់ស្ត្រីដែលបានរៀបការពេលនោះ ពីអារម្មណ៍របស់ពួកគាត់ដែលថាឪពុកម្ដាយមិនបានចូលរួមនោះ។ ពួកគេមានទុក្ខព្រួយខ្លាំង ពួកគេយល់ថា ខ្លួនគេគឺ

ត្រូវបាត់បង់នូវតម្លៃ ឬក៏សោកស្តាយ។ ហើយវិប្បដិសារី ហើយនិងការសោកស្តាយហ្នឹងស្ថិតនៅក្នុងចិត្តរបស់គេរហូតដល់ពេលបច្ចុប្បន្ន។

[១៥:៣៥:៣៤]

**ស៖** សូមអរគុណ។ កាលពីព្រឹកមិញលោកស្រីបានឆ្លើយថា ការប្រសិទ្ធពរជ័យតាមបែបសាសនាត្រូវបានលុបបំបាត់ចោលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយពិធីសាសនាផ្សេងៗសម្រាប់ការរៀបអាពាហ៍ពិពាហ៍ហ្នឹងក៏ត្រូវបានលុបបំបាត់ដែរ។ ដូច្នេះ តើអវត្តមាននៃពិធីបុណ្យសាសនានេះមានឥទ្ធិពលយ៉ាងណាមានផលប៉ះពាល់យ៉ាងណាខ្លះទៅលើបុគ្គលដែលលោកស្រីបានសម្ភាសនោះ?

**ឆ៖** តាមអ្វីដែលខ្ញុំចាំបានដោយហេតុដែល -- តាមរបៀបដែលខ្ញុំសម្ភាស គឺមិនបានផ្តោតអារម្មណ៍ខ្លាំងទៅលើពិធីសាសនាច្រើនក្នុងពិធីមង្គលការទេ <ព្រោះថាខ្ញុំខ្លួនឯងហ្នឹងមិនជឿលើសាសនាណាមួយផង ដូច្នេះ>ហើយខ្ញុំមិនបានចងចាំពីផលប៉ះពាល់ដែលថាមិនមានពិធីសាសនានៅក្នុងពេលរៀបការដែលគេប្រារព្ធមុនពេលសម័យខ្មែរក្រហម ហើយនិងក្នុងសម័យខ្មែរក្រហមនោះទេ។ ប៉ុន្តែ <ការសម្ភាសរបស់ខ្ញុំភាគច្រើនផ្តោតទៅលើ>អវត្តមានឪពុកម្តាយ ហើយនិងសមាជិកក្រុមគ្រួសារវិញ ពួកគេចង់ឲ្យមនុស្សនៅក្នុងសហគមន៍ភូមិចូលរួម ប៉ុន្តែវាមិនអាចទៅរួចទេនៅកាលនោះ។ ហើយជាពិសេស អំពីសម្លៀកបំពាក់ដើម្បីតែងខ្លួននៅក្នុងមង្គលការ គឺគេស្លៀកពាក់តែសម្លៀកបំពាក់ខ្មៅ មានក្រមា ហើយនេះជាសម្លៀកបំពាក់ដែលមិនសមស្របសម្រាប់អ្វីដែលគេរំពឹងចង់បានក្នុងពេលរៀបការទេ។ ពីព្រោះថាការរៀបអាពាហ៍ពិពាហ៍របស់ខ្មែរនោះគឺថា គឺមានអាហារច្រើនមុខណាស់ គេកាប់មាន់កាប់គោ ជ្រូក គឺថាមានអាហារច្រើនណាស់។ រីឯនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺមិនមានអាហារបែបទាំងនោះទេ។ ពួកគេខ្វះ ពួកគេមិនមាន។

[១៥:៣៧:៤២]

**ស៖** សូមអរគុណ។ លោកស្រីនិយាយអំពីបញ្ហាព្រហ្មចារីរបស់ស្ត្រី នៅក្នុងឯកសាររបស់លោកស្រីគឺ E3/2959, ERN ជាភាសាអង់គ្លេស 00421889 លោកស្រីនិយាយអំពីសារៈសំខាន់នៃភាពបរិសុទ្ធកាលនៅព្រហ្មចារីរបស់ស្ត្រី <ឬចំពោះប្រជាពលរដ្ឋខ្មែរទូទៅ ក៏ដូចជាចំពោះបុរស ដោយ> លោកស្រីបានយោងទៅលើសុភាសិតខ្មែរមួយ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ពីព្រោះថាឯកសារនេះមិនមានបកប្រែជាភាសាបារាំងទេ។ "គឺថាបុរសគឺជាមាសទឹក១០ ឯស្ត្រីគឺដូចសំពតក្នុងផ្នត់ បាទ ដូចជាក្រដាសសមួយសន្លឹក។" លោកស្រីអាចពន្យល់ជូនតុលាការបានទេ ថាតើព្រហ្មចារីនេះមានសារៈសំខាន់

យ៉ាងម៉េចខ្លះនៅប្រទេសកម្ពុជានោះ?

**ឆ៖** ខ្ញុំព្យាយាមបញ្ជាក់បញ្ហានេះឲ្យបានសាមញ្ញ ជាសាមញ្ញ។ តាមប្រពៃណីខ្មែរកូនជាដូចជាទ្រព្យសម្បត្តិរបស់ឪពុកម្តាយ ជាពិសេសកូនស្រីត្រូវបានគេចាត់ទុកថាជាទ្រព្យដ៏សំខាន់ក្នុងគ្រួសារដែលត្រូវតែរក្សាទុកឲ្យមានភាពបរិសុទ្ធរហូតដល់ពេលរៀបការ។ គឺដើម្បីរក្សាកិត្តិយស កិត្តិសព្ទគ្រួសារ ហើយដើម្បីធានាថា កូនស្រីអាចនឹងមានអាពាហ៍ពិពាហ៍ល្អត្រឹមត្រូវដូចដែលឪពុកម្តាយចង់បាន។ ពីជំនាន់មួយទៅជំនាន់មួយ ឪពុកម្តាយបានអនុវត្តនៅគំនិតបែបនេះ គឺថាកូនស្រីរបស់ខ្លួនត្រូវតែមានភាពបរិសុទ្ធដោយរក្សាទុកព្រហ្មចារីរហូតដល់ពេលរៀបការ។ ហើយកូនស្រីក៏មានគំនិតក្នុងចិត្តរបស់ខ្លួនគឺថាមិនត្រូវទាក់ទងជាមួយបុរស ឬក៏កំលោះណាទេ គឺរហូតទាល់តែរៀបការហើយ បានធ្វើទៅបាន។ ដូច្នេះហើយ<ព្រហ្មចារី មិនត្រឹមតែជាភាពបរិសុទ្ធក្នុងសុខភាពបន្តពូជនោះទេ ប៉ុន្តែនៅមុន>សម័យខ្មែរក្រហមហ្នឹង <ស្ត្រីដែលខ្ញុំបានជួបជាច្រើនបានប្រាប់ខ្ញុំថា ពួកគេព្យាយាម>មិនទាក់ទងជាមួយនឹងអ្នក<បុរស>ទេ គឺចង់រក្សាភាពបរិសុទ្ធ។ រីឯការទាក់ទងជាមួយបុរស ឬក៏យុវជនណាហ្នឹង គឺធ្វើឲ្យ<មានពាក្យចរាមអារ៉ាមថា នាងជាក្មេងស្រីមិនល្អ ជួបទាក់ទងជាមួយប្រុស។ ដូច្នេះ វាមិនត្រឹមតែជាបញ្ហាផ្លូវការនោះទេ>។

[១៥:៤០:៤៨]

**ស៖** សូមអរគុណ។ ការសម្ភាសនិងការស្រាវជ្រាវរបស់លោកស្រី អាចឲ្យលោកស្រីសន្និដ្ឋានបានទេ ថាស្ត្រីមួយចំនួននោះ ទទួលរងនូវការឈឺចាប់នៅពេលដែលខ្លួនបាត់បង់ព្រហ្មចារី ដោយសារតែការរៀបការ<ដោយបង្ខំ>នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ? តើនៅពេលដែលលោកស្រីសម្ភាសនោះ អ្នកទាំងអស់នោះ គាត់មានបានបង្ហាញពីការឈឺចាប់ ដោយសារតែការបាត់បង់ព្រហ្មចារីហ្នឹងទេ?

**ឆ៖** ចាស គឺពិតមែន។ វាអាស្រ័យទៅលើស្ត្រីអំពីរបៀបដែលគេរៀប -- ដែលគាត់រៀបរាប់។ ដំបូងគេចាត់ទុកថាការបង្ខំឲ្យរួមភេទនោះ គឺជាការវាយប្រហារលើរាងកាយរបស់គាត់។ <ហើយប្តីព្យាយាមវាយលើរូបកាយគាត់> ហើយជាផលវិបាកហ្នឹង គឺពួកគេបានបាត់បង់នូវភាពបរិសុទ្ធ ព្រហ្មចារី។ ដូច្នេះហើយ ពួកគាត់មានវិប្បដិសារីខ្លាំងណាស់។

**ស៖** សូមអរគុណ។ នៅក្នុងសៀវភៅរបស់លោកស្រី គឺ E3/2959, ERN ជាភាសាអង់គ្លេស 00421892, ជាភាសាខ្មែរ 00738345 លោកស្រីបានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់ជា

ភាសាអង់គ្លេស៖ “អ្នកដែលរៀបការថ្មីៗ គឺត្រូវបានបំភ្លេចចោលទាំងស្រុង”។

លោកស្រីអាចពន្យល់ជូនតុលាការបានទេ នៅពេលដែលលោកស្រីអះអាងបែបនេះ តើភាពជាឯកជនរបស់អ្នករៀបការថ្មីថ្មោងនោះត្រូវបានគេបំភ្លេចចោលយ៉ាងម៉េចខ្លះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ? ហើយលោកស្រីអាចជម្រាបបានទេ ថាតើបុរសនិងស្ត្រី ដែលលោកស្រីបានសម្ភាសហ្នឹង គាត់មានបានបង្ហាញអំពីការឈឺចាប់នៅពេលដែលបាត់បង់នូវផ្នែក ឬក៏ភាពជាឯកជនហ្នឹងទេ?

[១៥:៤៣:១៦]

**ឆ៖** នៅពេលដែលខ្ញុំយោងទៅរកការងារជាឯកជន<ដែលត្រូវបានដកហូត>នោះ គឺខ្ញុំយោងទៅរកគូស្រករដែលត្រូវបានគេបង្ខំឱ្យរៀបការ ហើយត្រូវបានគេតាមដាន ត្រូវបានល្បបតាមដាន ហើយមានរឿងរ៉ាវដែលខ្ញុំបានឮពីបុរស និងស្ត្រី ដែលត្រូវបានគេបង្ខំឱ្យរៀបការ ប្រឆាំងនឹងឆន្ទៈរបស់គេ គឺខ្មែរក្រហមជាអ្នកបង្ខំ។ គឺនៅពេលល្ងាច បន្ទាប់ពីគេរៀបការហើយនោះ គឺមានអ្នកតាមដានជាភាគច្រើននោះ គឺថាជាកុមារដែលវ័យក្មេង ដែលខ្មែរក្រហមគេបញ្ជូនមក ឱ្យមកលបស្តាប់ជិតៗផ្ទះ។ គឺជាខ្ទមដែលធ្វើដំបូលពីស្បូវ ឬក៏មានជញ្ជាំងពីស្លឹក គឺថាគេអាចមើលទៅឃើញខាងក្នុង តាមប្រឡោះជញ្ជាំងជាដើមហ្នឹង។ អ៊ីចឹង គឺថាគេអត់មានភាពឯកជន ជាអាថ៌កំបាំងទេ នៅពេលដែលកុមារជាល្បប ឬក៏ជាអ្នកតាមដាននោះមកហ្នឹង គឺគេអាចមើលឃើញ ហើយប្តីនិងប្រពន្ធគេយល់ថា មានគេអ្នកមកតាមដាន ដើម្បីពិនិត្យមើល ថាតើគេរួមដំណេក ឬអត់នោះ។

**ស៖** សូមអរគុណ។ កាលពីព្រឹកមិញ ឬក៏ប្រហែលជាដើមរសៀលនេះ លោកស្រីបាននិយាយថា បញ្ហារួមភេទហ្នឹងគេមិននិយាយទេនៅស្រុកខ្មែរនោះ។ ដូច្នេះការដែលមានគេឃ្លាំមើលថាតើប្តីប្រពន្ធហ្នឹងរួមដំណេកឬក៏អត់នោះ លោកស្រីកត់សម្គាល់ឃើញថា ចំណុចនេះវាបង្កព្យសនកម្ម ឬបង្កការឈឺចាប់ទៅដល់បុគ្គលដែលលោកស្រីបានសម្ភាសទេ?

[១៥:៤៥:៣១]

**ឆ៖** ចាស វាមានផលប៉ះពាល់យ៉ាងខ្លាំង ហើយ<ការប៉ះពាល់នេះមិន>ស្មើគ្នា<ទេ>ទៅនឹងបុរស<> ដោយសារបុរសមានភារកិច្ច ហើយត្រូវបានគេបង្ខំឱ្យរំលោភប្រពន្ធរបស់ខ្លួន។

**ស៖** ចុះលោកស្រីទាញសេចក្តីសន្និដ្ឋានយ៉ាងម៉េចចេញពីសម្តីដែលលោកស្រីថា ប្តីត្រូវបានបង្ខំឱ្យរំលោភប្រពន្ធរបស់ខ្លួននោះ? អ៊ីចឹងតើផលប៉ះពាល់ហ្នឹងវាមានយ៉ាងម៉េចខ្លះទៅលើបុរសនិងស្ត្រីនោះ? ឥឡូវសូមលោកស្រីនិយាយចាប់ពីបុរសទៅវិញ មុនទៅវិញ?

**ឆៈ** សូមអរគុណ។ យើងចាប់ផ្ដើមជាមួយបុរសខាងប្ដីនោះ។ ការបង្ខំបុរសឲ្យរំលោភអ្នកណាម្នាក់ហ្នឹងគឺជាអំពើអមនុស្សធម៌ មិនមែនបុរសទាំងអស់អាចធ្វើបានទេ ជាបឋមនោះ។ ប៉ុន្តែគេបង្ខំអ្នកនោះធ្វើបែបនោះ។ ការភ័យខ្លាចគឺជាកត្តាដែល<មិន>អាចរាស់វែងបាន។ ហើយ<ស្ត្រីជាច្រើន>គាត់<ភ័យខ្លាចខ្លាំងណាស់ ឬមួយក៏ពួកគេបង្ហាញមនោសញ្ចេតនាថា ពួកគេ>មិន<ចង់>ទទួល<>ប្ដី<នោះ>ទេ។ ហើយកាលៈទេសៈដ៏អាក្រក់បំផុតនោះ ដែលបុរសនោះត្រូវតែធ្វើ។ នោះគឺជាអំពើអមនុស្សធម៌។ ហើយខ្ញុំមិនអាចស្រមៃ ឬអាចគិតបានទេថា បុរសអាចធ្វើបែបនោះបាន។ ហើយ<ប្រហែលជានោះហើយ>គឺ<ជាមូលហេតុ ដែលបុរសជាច្រើន>ត្រូវបានគេបញ្ជូនទៅមន្ទីរអប់រំកែប្រែ<ដោយសារតែ>ខកខានមិនបាន<រំលោភ>ប្រពន្ធ។ អ៊ីចឹងគឺថា<វា>ប៉ះពាល់<ជីវិត>អាពាហ៍ពិពាហ៍បុរស<ជាប្ដី>នោះ<អាច>មានអារម្មណ៍<ថាមានកំហុសចំពោះប្រពន្ធ ឬមួយក៏>មានការព្រួយបារម្ភគឺថាក្នុងចិត្តរបស់ខ្លួនហ្នឹង គឺថា គិតថាប្រពន្ធមិនបានស្រឡាញ់ខ្លួនទេ។ វាអាចជាជំងឺបាក់ស្បាតក្នុងចិត្តរបស់គាត់ក្នុងរយៈពេលវែង រហូតដល់តែពេលគាត់ទទួលបានភាពជាបុរសឡើងវិញ ដែលគាត់អាចធានាថា ប្រពន្ធរបស់គាត់ទទួលយកគាត់បានជាប្ដី។ ដូច្នេះហើយគឺ នេះគឺជាផលប៉ះពាល់ដ៏ធំទៅលើបុរសដែលរងការបង្ខិតបង្ខំនោះ។

[១៥:៤៨:២៥]

ចំពោះស្ត្រីវិញ ខ្ញុំនឹងបន្ត។ ចំពោះនារីវិញ ស្ត្រីវិញ ដំបូងហ្នឹងផលប៉ះពាល់ហ្នឹងគឺមានធំធេងណាស់ទៅហើយ នៅពេលដែលគេបង្ខំគាត់ឲ្យរៀបការ<ប្រឆាំងនឹងទស្សនៈរបស់គាត់> ដោយមិនមានការយល់ព្រមពីឪពុកម្ដាយរបស់គាត់។ ហើយនៅដំណាក់កាលដំបូង គឺនាងត្រូវបានកាត់ផ្ដាច់ពីក្ដីសង្ឃឹមទាំងអស់។ គឺថា គូស្រករថ្មីៗ<ដែលគេបង្ខំឲ្យរៀបការ>ហ្នឹង <ភាគច្រើនគេ>ដឹង<ថា> គេ<ត្រូវតែរួម>ដំណេក <ព្រោះថា មេភូមិបានណែនាំនៅក្នុងពិធីរៀបការនោះ។ ដូច្នេះនាងដឹងថា អ្វីនឹងកើតឡើងនៅ>ពេលល្ងាច<>បន្ទាប់ពីរៀបការហ្នឹងឯង។ម្យ៉ាងវិញទៀត នាងត្រូវតែទទួលប្ដីរបស់នាង ពីព្រោះវាជាបញ្ហាដាច់ខាត។ នាងមិនអាចបដិសេធថា “ទេ” បានទេ។ បើគាត់អាច -- បើគាត់បដិសេធ លទ្ធផលហ្នឹងគឺថា គឺនៅក្នុងលទ្ធផលមួយក្នុងចំណោមនោះគឺថា អាចនឹងត្រូវគេសម្លាប់។ អ៊ីចឹងគឺគាត់ត្រូវតែទទួលយកប្ដីហ្នឹង។ នេះគឺជាក្ដីវន្ទត់ដល់ធំធេងចំពោះស្ត្រីដែលភាគច្រើនដែលថា គាត់មិនដែលប៉ះពាល់ទៅរឿងផ្លូវភេទពីមុនមកសោះ។ អ៊ីចឹង គឺថាចំពោះការរំលោភវិញ គឺថាវាមានកើតឡើងនៅក្នុងករណីខុសៗគ្នា ក្នុងករណីខ្លះគឺដោយអំពើហិង្សា ដោយសារប្ដីបានប្រើអំពើហិង្សា។ ប៉ុន្តែការរំលោភខ្លះទៀតគឺ

មិនៗមានអំពើហិង្សាទេ ខ្ញុំបានកត់ត្រាទុកទេ ប៉ុន្តែបុរសត្រូវបានគេបង្ខំឲ្យរំលោភប្រពន្ធ ហើយប្រពន្ធត្រូវតែរងអំពើការរំលោភពីប្តី។ អំពើនេះគឺបានបន្សល់ទុកនូវបទពិសោធន៍ដ៏រន្ធត់ បាក់ស្បាតចំពោះប្រពន្ធគឺមិនងាយនឹងភ្លេចបានដោយងាយៗទេ។ ដូច្នេះការបាត់បង់ ការយល់ស្របពីឪពុកម្តាយរបស់នាង គឺជាបទពិសោធន៍ដ៏រន្ធត់មួយហើយ ឥឡូវនេះមកដល់ពេលមួយ គឺគេបង្ខំឲ្យនាងមានទំនាក់ទំនងផ្លូវភេទជាមួយបុរសដោយបំផ្លាញដល់ព្រហ្មចារីរបស់នាង ដោយគ្មានការយល់ព្រមពីឪពុកម្តាយ។ ហើយក៏អំពើហ្នឹងបានធ្វើឲ្យស្ថិតនៅក្នុងបទពិសោធន៍ដ៏រន្ធត់មួយផ្សេងទៀត។ ដូច្នេះហើយស្ត្រីខ្លះគឺថា មានការប៉ះពាល់ដល់លទ្ធភាពបន្តពូជដោយសារអំពើរំលោភផ្លូវភេទដោយបង្ខំ។<ហើយនៅបន្តមានដល់បច្ចុប្បន្នសម្រាប់ស្ត្រីមួយចំនួនដែលគាត់មានផ្ទៃពោះដោយសារតែការរំលោភ>។

[១៥:៥១:៣០]

**ស៖** សូមអរគុណ។ ដើម្បីយល់ឲ្យច្បាស់អំពីជំហររបស់លោកស្រីទៅលើបញ្ហានេះ តើលោកស្រីយល់យ៉ាងណាចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំទាំងអស់ដែលលោកស្រីបានរៀបរាប់? លោកស្រីបានបែងចែកការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរៀបអាពាហ៍ពីពាហ៍ដោយមានការអនុញ្ញាត។ អ៊ីចឹងក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ តើលោកស្រីយល់ថាការបង្ខំឲ្យរួមដំណេកហ្នឹងវានាំឲ្យមានការរំលោភហ្នឹងទេ? ឬក៏វាអាស្រ័យទៅតាម<កាលៈទេសៈ ឬក៏តាម>ករណី? លោកស្រីយល់ថា ចាប់ពីពេលមានការរួមដំណេកមកចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំហ្នឹង គឺជាការរំលោភសេពសន្ថវៈហើយ?

**ឆ៖** ចាស តាមគំនិតរបស់ខ្ញុំគឺថា គឺជាការរំលោភសេពសន្ថវៈដោយ<ស្របច្បាប់>។ គឺថា<ការរំលោភ>ត្រូវតែ<ធ្វើឲ្យបានសម្រេច ដើម្បី>គោរពតាមការបញ្ជារបស់<ខ្មែរក្រហម>។

**ស៖** សូមអរគុណ។ លោកស្រីបានពន្យល់យ៉ាងច្បាស់ជូនសហព្រះរាជអាជ្ញារងអន្តរជាតិអំពីការរៀបអាពាហ៍ពិពាហ៍ដោយអនុញ្ញាត និង អាពាហ៍ពិពាហ៍ដោយបង្ខំ។ ហើយលោកស្រីក៏បានលើកឡើងជាច្រើនលើកច្រើនសាអំពីភាពភ័យខ្លាច ឬភាពភ័យរន្ធត់ ដែលកើតមានជាប់ជារហូតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះខ្ញុំចង់ដឹងថាតើបរិយាកាស ឬក៏ស្ថានភាពនៃការភ័យខ្លាចបំផុតនេះ វាកើតមានចំពោះអ្នកដែលត្រូវបានគេអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ដែរឬទេ?

[១៥:៥៣:២៦]

**ឆ៖** ចាស ត្រឹមត្រូវហើយ។ ស្ត្រី បុរស ផងដែរបានរស់នៅក្នុងក្តីភ័យរន្ធត់និងភាពតក់ស្លុតជា

ច្រើនដំណាក់កាល។ ហើយនិងគឺរងការបំពារបំពានទៅលើរាងកាយ ឬក៏ផ្លូវចិត្តនោះច្រើនដែរ ជាពិសេសគឺថារំលោភសេពសន្ថវៈផងដែរ។

**ស៖** ខ្ញុំសូមសង្កត់ធ្ងន់ត្រង់ចំណុចនេះ។ បរិយាកាសនៃការភ័យខ្លាច ឬភ័យរន្ធត់នេះ កើតមានទាំងអស់ចំពោះអ្នកដែលត្រូវបានអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ ហើយនិងអ្នកដែលត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ លោកស្រីចង់មានន័យថាអ៊ីចឹងមែនទេ?

**ឆ៖** សូមអភ័យទោស សូមលោកស្រីរៀបចំសំណួរម្តងទៀត ខ្ញុំតាមមិនទាន់។

**ស៖** ខ្ញុំព្យាយាមទៅលឿនដោយសារតែខ្ញុំមានពេលខ្លី ដូច្នេះហើយបានជាខ្ញុំសួរដោយសង្ខេបនោះ។ កាលពីព្រឹកមិញនេះលោកស្រីបានពន្យល់អំពីភាពខុសគ្នារវាងអាពាហ៍ពិពាហ៍ដែលទទួលបានការអនុញ្ញាតនិងអាពាហ៍ពិពាហ៍ដែលបង្ខំ។ ហើយលោកស្រីបាននិយាយជាច្រើនលើកច្រើនសាអំពីបរិយាកាសនៃភាពភ័យខ្លាច និងភ័យរន្ធត់ ដែលកើតមាននៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះបើតាមយោបល់របស់លោកស្រីនោះ ទាំងអ្នកដែលត្រូវបានអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ហ្នឹងក៏រស់នៅក្នុងភាពភ័យខ្លាច ឬភ័យរន្ធត់ហ្នឹងដូចគ្នាទៅនឹងអ្នកដែលត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ដែរមែនទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ។

[១៥:៥៥:១១]

**ស៖** សូមអរគុណ។ លោកស្រីបាននិយាយអំពីមាតុភាព គឺមានស្ត្រីដែលមានផ្ទៃពោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្រោយពីត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍។ ដូច្នេះលោកស្រីអាចរៀបរាប់ជូនតុលាការបានទេ ថាតើស្ត្រីទាំងអស់ហ្នឹងទទួលរងនូវព្យសនកម្មអ្វីខ្លះដោយសារតែខ្លួនមានផ្ទៃពោះនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះ? នេះជាសំណួរទី១។ បន្ទាប់មកទៀត សួរថា តើផលប៉ះពាល់យ៉ាងម៉េចខ្លះ នៅពេលដែលគាត់មានផ្ទៃពោះដោយសារតែការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះ?

**ឆ៖** សុំទោស ខ្ញុំហាក់ដូចជាក្តាប់មិនបានផ្នែកទី២ នៃ<សំណួរ>ទេ។ ប៉ុន្តែខ្ញុំឆ្លើយចំណុចទី១។ ផលប៉ះពាល់<នៃការមានផ្ទៃពោះ>ដោយសារការរៀបការដោយបង្ខំ<ចំពោះស្ត្រី> ហើយក៏ទៅលើបុរសដែរ។ ចំពោះនារី ស្ត្រីគេបានបង្ខំឲ្យនាងរៀបការដែលនាងមិនចង់បាន ដែលមានន័យថា គេបង្ខំឲ្យរៀបការជាមួយបុរសដែលនាងមិនមានចេតនាចង់រៀបការតាមការណែនាំ ឬក៏ឱវាទរបស់ឪពុកម្តាយ។ ពីដំបូងមកហ្នឹងគឺថា នាងអត់ក្តីស្នេហា ឬក៏សេចក្តីស្រឡាញ់អីទៅប្តីរបស់នាងទេ ហើយនាងអត់មានកាតព្វកិច្ចថាត្រូវតែស្រឡាញ់គាត់ទេ ពីព្រោះឪពុកម្តាយមិនបានយល់ស្របឲ្យគាត់រៀបការ។ ហើយនៅ

ពេលដែលគាត់មានផ្ទៃពោះវិញ ហើយគឺនារីក៏មានកំហឹង ពីព្រោះថាគាត់មិនអាចគេចផុតពីការមានផ្ទៃពោះ<>។

[១៥:៥៧:១៦]

<ពួកគេមិនបានស្រឡាញ់ប្ដីនោះទេ។ ពួកគេមិនចង់បានកូននោះទេ។ ពួកគេ>មិនចង់មានកូនជាមួយប្ដីរបស់គាត់ទេ។ ប៉ុន្តែត្រូវតែរក្សាគភ៌ហ្នឹង។ ហើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ត្រីមានផ្ទៃពោះមិនទទួលបានការថែទាំគាំពារអ្វីពិសេសចំពោះជាស្ត្រីមានផ្ទៃពោះទេ។ អ៊ីចឹង ក្នុងពេលដែលគាត់មានគភ៌ហ្នឹង នាងមានបន្ទុកធ្ងន់ជាងអ្នកធម្មតា។ ហើយនៅពេលដែលករណីហ្នឹងជាករណីមួយទៅហើយ។ ប៉ុន្តែក្នុងករណីដែលគាត់មានផ្ទៃពោះដោយសារប្ដីរំលោភគាត់វិញ រំលោភសេពសន្ថវៈគាត់វិញ មិនមែនស្ត្រីទាំងអស់ទេ ប៉ុន្តែក្នុងករណីហ្នឹង គឺនាងមិនចង់បានកូនពីលទ្ធផលបែបនេះទេ។ ដូច្នេះគឺថា នាងក៏មិនមានជម្រើសថា ធ្វើម៉េចដើម្បីជៀសឲ្យផុតពីការមានផ្ទៃពោះ។ អ៊ីចឹងគឺថា បញ្ហាមួយទៀត នៅពេលដែលកូនហ្នឹងកើត ថាតើ បញ្ហាដំបូង គាត់ស្រឡាញ់កូនហ្នឹងម្ដេចហ្នឹងកើត។ ទី២ ថាតើសម្រាលកូនហ្នឹងរបៀបម៉េចកើត។ តើកុមារ តើកូនហ្នឹងអាចរស់ បានដែរឬទេ? នេះជាការព្រួយបារម្ភធំណាស់របស់ស្ត្រី។ បញ្ហាទី១ ថាតើ គាត់អាចស្រឡាញ់កូនហ្នឹងដែរឬទេ? ពីព្រោះកូនហ្នឹងវាមិនកើតដោយសារប្ដីដែលឪពុកម្ដាយរបស់គាត់យល់ស្របនោះទេ។ <ដូច្នេះមានបទពិសោធន៍ឈឺចាប់ខាងផ្លូវចិត្តខ្លាំងចំពោះស្ត្រី>។ ចំពោះបុរសវិញ <>ខ្ញុំមិនបានសម្ភាសបុរសដែល<ប្រពន្ធគាត់មានផ្ទៃពោះដោយសារការរៀបការទាំងបង្ខំនោះ>ទេ ប៉ុន្តែខ្ញុំអាចយល់បានថា បុរសក៏មានការឈឺចាប់ដែរ ពីព្រោះគាត់យល់ថាដៃគូរបស់គាត់មានផ្ទៃពោះ ហើយវាមិនចេញពីចេតនារបស់គាត់ទេ គេបង្ខំឲ្យគាត់រំលោភ។ <ទោះបីជាគាត់មិនចង់ឲ្យដៃគូ ឬប្រពន្ធគាត់មានផ្ទៃពោះក៏ដោយ រឿងនេះវាត្រូវតែមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើភាពជា>បុរស <ដែល>គាត់ត្រូវទទួលយកកូនដែលគាត់មិនចង់បានដែរ។ អាហ្នឹងជាការទទួលខុសត្រូវមួយ ហើយអាហ្នឹងឯងជាការឈឺចាប់ផ្លូវចិត្តរបស់គាត់។

[១៥:៥៩:៤២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំនៅសល់សំណួរបន្ថែមបន្តិចទៀត ខ្ញុំត្រូវការប្រហែលជា ១០ ទៅ ១៥នាទី។ ដូច្នេះ សូមលោកប្រធានមេត្តាអនុញ្ញាតជូនខ្ញុំនៅព្រឹកស្អែក ១០ ទៅ ១៥នាទីទៀត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រមតាមសំណើ។

ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការនឹងលើកបន្តធ្វើនៅថ្ងៃពុធ ទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ កាស៊ូមិ បញ្ចប់ ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-854 ទាក់ទងនឹងអង្គហេតុមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង។ សូមភាគីជ្រាបនិងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណ កញ្ញា កាស៊ូមិ ដំណើរការស្តាប់សក្ខីកម្មនៅពេលនេះមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញកញ្ញាឱ្យមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូន កញ្ញា កាស៊ូមិ វិលត្រលប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ និងសូមអញ្ជើញគាត់ត្រលប់មកចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃពុធ ទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រលប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*